№ 3
23-1-97

ព្រះរាជាណាចក្រកម្ពុជា

ជាតិ សាសនា ព្រះមហាក្សត្រ

* * *

ឆ្នាំទី ៥ លេខ ៣ ថ្ងៃទី ២៣ ខែ មករា ឆ្នាំ ១៩៩៧

រាជកិច្ច

រួមមាន :

- ច្បាប់
- ក្រម-ក្រឹត្យ
- អនុក្រឹត្យ
- ប្រកាស
- សេចក្តីសំរេច
- សារាចរ

ផ្សាយចេញពីទីស្តីការគណៈរដ្ឋមន្ត្រីរៀងរាល់សប្តាហ៍

LAW.

ក

មាតិកា

I - ខុទ្ទកាល័យព្រះមហាក្សត្រ

ព្រះរាជក្រឹត្យ

២៣-០១-៩៦	ព្រះរាជក្រឹត្យលេខ នស.រកត ០១៩៧/០៦ តែងតាំងលោក **នុត សារអាន** ជាទីប្រឹក្សាឯកឧត្តម **ស ខេង** ឧបនាយករដ្ឋមន្ត្រី មានឋានៈស្មើអនុរដ្ឋលេខាធិការ ។	៨២
២៣-០១-៩៧	ព្រះរាជក្រឹត្យ នស/រកត/០១៩៧/០៧ តែងតាំងលោក **ឡើន សុវណ្ណ** ជាឧកញ៉ា	៨៣

II - ទីស្តីការគណៈរដ្ឋមន្ត្រី

១ - អនុក្រឹត្យ

១៧-០១-៩៧	អនុក្រឹត្យលេខ ០៣ អនក្រ.បក ស្តីពីការបង្កើតស្ថានឯកអគ្គរាជទូតនៃព្រះរាជាណាចក្រកម្ពុជា ប្រចាំសាធារណរដ្ឋ ហ្វីលីពីន ។	៨៤
១៧-០១-៩៧	អនុក្រឹត្យលេខ ០៤ អនក្រ.បក ស្តីពីការបង្កើតស្ថានឯកអគ្គរាជទូតនៃព្រះរាជាណាចក្រកម្ពុជាប្រចាំ សហព័ន្ធម៉ាឡេស៊ី ។	៨៦
១៧-០១-៩៧	អនុក្រឹត្យលេខ ០៥ អនក្រ.បក ស្តីពីការបង្កើតស្ថានឯកអគ្គរាជទូតនៃព្រះរាជាណាចក្រកម្ពុជាប្រចាំ សាធារណរដ្ឋសឹង្ហបុរី ។	៨៨
២០-០១-៩៧	អនុក្រឹត្យលេខ ០៦ អនក្រ.បក ស្តីពីការបែងចែកចំណូលថវិកាទូទៅរបស់រដ្ឋសំរាប់ការគ្រប់គ្រងឆ្នាំ ១៩៩៧ ។	៩០
២១-០១-៩៧	អនុក្រឹត្យលេខ ០៧ អនក្រ.បក ស្តីពីការរៀបចំឯកសណ្ឋាន ផ្លាកសញ្ញា និង ទង់ជ័យ នៃកងយោធពលខេមរភូមិន្ទ ។	៩៨
២២-០១-៩៧	អនុក្រឹត្យលេខ ០៨ អនក្រ.បក ស្តីពីការដាក់ឲ្យប្រើបណ្ណរតនាគារ	១៣០
២២-០១-៩៧	អនក្រឹត្យលេខ ០៥ អនក្រ.តត ស្តីពីការជូនមេដាយស្ថាបនាជាតិ	១៤៤

ខ

III.- ការងារបណ្ដាក្រសួង

១ - ទីស្ដីការរដ្ឋមន្ត្រី ក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ

ប្រកាស

ប្រកាសលេខ ០១៤ ប្រក.សហវ.រជ ស្ដីអំពីការកំរិតកំណត់ចំនួន ទឹកប្រាក់ចំណូលរបស់រដ្ឋដែលភ្នាក់ងារបើកផ្ដល់ ឬ អង្គភាព នីមួយៗ អាចរក្សាទុកនៅក្នុងបេឡារបស់ខ្លួន ។ ១៣៨

១ - ទីស្ដីការរដ្ឋមន្ត្រី ក្រសួងឧស្សាហកម្មរ៉ែ និង ថាមពល

ប្រកាស

១៦-០១-៩៧	ប្រកាសលេខ ២៨ ផក.ប្រក. អនុញ្ញាតអោយលោក **គាន់ អេងឆោ** ជនជាតិខ្មែរ សញ្ជាតិកម្ពុជា បន្តដំណើរការ ឧស្សាហកម្មតូចផលិតទឹកកកដើម ។	១៤០
១៦-០១-៩៧	ប្រកាសលេខ ២៩ ផក.ប្រក.អនុញ្ញាតអោយអ្នកស្រី **លី សុខខេង** ជនជាតិខ្មែរ សញ្ជាតិកម្ពុជា បន្តដំណើរការយានដ្ឋានជួសជុល និង លាងរថយន្ត ។	១៤១
១៧-០១-៩៧	ប្រកាសលេខ ៥៣ ក.ប្រក.អនុញ្ញាតអោយអ្នកស្រី **អាន់ សំឡាន** ផលិតទឹកកកដើម ។	១៤១
២១-០១-៩៧	ប្រកាសលេខ ៥៩ ផក.ប្រក.អនុញ្ញាតអោយលោក **ហុក ទ៊ា** ជនជាតិខ្មែរ សញ្ជាតិកម្ពុជា បន្តដំណើរការឡផលិតឥដ្ឋ ក្បឿង	១៤២
២១-០១-៩៧	ប្រកាសលេខ ៦០ ផក.ប្រក.អនុញ្ញាតអោយអ្នកស្រី **ខៃ ស៊ី** ជនជាតិខ្មែរ សញ្ជាតិកម្ពុជា បន្តដំណើរការសិប្បកម្មផលិត មីសួរសៃ ។	១៤២

២១-០១-៩៧	ប្រកាសលេខ ៦១ ផក. ប្រក. អនុញ្ញាតអោយលោក **ហុក សេង** ជនជាតិខ្មែរ សញ្ជាតិកម្ពុជា បន្តដំណើរការឡផលិតឥដ្ឋ-ក្បឿង ។	១៤៣
២១-០១-៩៧	ប្រកាសលេខ ៦២ ផក. ប្រក. អនុញ្ញាតអោយពលោក **ឱ ឈាង** ជនជាតិខ្មែរ សញ្ជាតិកម្ពុជា បន្តដំណើរការឡផលិតឥដ្ឋ ក្បឿង	១៤៣
២១-០១-៩៧	ប្រកាសលេខ ៦៣ ផក. ប្រក. អនុញ្ញាតអោយលោក **ស៊ឹម អ៊ុយតាំង** បន្តដំណើរការរោងម៉ាស៊ីនផលិតទឹកកកដើម	១៤៤
២១-០១-៩៧	បកាសលេខ ៦៤ ផក. ប្រក. អនុញ្ញាតអោយលោក **លី ហេង** ជនជាតិខ្មែរ សញ្ជាតិកម្ពុជា បន្តដំណើរការឡផលិតឥដ្ឋ-ក្បឿង ។	១៤៤
២១-០១-៩៧	បកាសលេខ ៦៥ ផក. ប្រក. អនុញ្ញាតអោយលោក **ស៊ឹម ស៊ុយតាំង** បន្តដំណើរការឡផលិតឥដ្ឋ-ក្បឿង ។	១៤៥
២១-០១-៩៧	ប្រកាសលេខ ៦៦ ផក. ប្រក. អនុញ្ញាតអោយលោក **វ៉ាន់ សាម** ជនជាតិខ្មែរ សញ្ជាតិកម្ពុជា បន្តដំណើរការរោងម៉ាស៊ីនកិនស្រូវ កំលាំង ១៨ សេះ ។	១៤៥
២១-០១-៩៧	ប្រកាសលេខ ៦៧ ផក. ប្រក. អនុញ្ញាតអោយលោក **សៀង ស្រ៊ុន** ជនជាតិខ្មែរ សញ្ជាតិកម្ពុជា បន្តដំណើរការរោងម៉ាស៊ីនកិនស្រូវ កំលាំង ៤០ សេះ ។	១៤៦
២១-០១-៩៧	ប្រកាសលេខ ៦៨ ផក. ប្រក. អនុញ្ញាតអោយលោក **សុខ លាង** ជនជាតិខ្មែរ សញ្ជាតិកម្ពុជា ត្រូវបានអនុញ្ញាតអោយផលិតបន្ថែមនូវមុខផលិតផលទឹកស៊ីអ៊ីវ សញ្ញា «ផ្កាកូឡាប» ។	១៤៧
២១-០១-៩៧	ប្រកាសលេខ ៦៩ ផក. ប្រក. អនុញ្ញាតអោយលោក **ង៉ូ សេងអាន** ជនជាតិខ្មែរ សញ្ជាតិកម្ពុជា បន្តដំណើរការផលិតកម្មផលិតស្លាបព្រា និង វែកអំពីអាលុយមីញ៉ូម «៩៩៩» ។	១៤៧

ឃ

២១-០១-៩៧	ប្រកាសលេខ ៧០ ផក.ប្រក. អនុញ្ញាតអោយរោងជាងដែកដែលមានលោក **ឃីន ហ៊ល** ជនជាតិខ្មែរ សញ្ជាតិកម្ពុជា ជាប្រធានបន្តដំណើរការផលិតកម្ម ។	១៤៨
២១-០១-៩៧	ប្រកាសលេខ ៧១ ផក.ប្រក. អនុញ្ញាតអោយលោក អ៊ុច ជូតេង ជនជាតិខ្មែរ សញ្ជាតិកម្ពុជា បន្តដំណើរការសិប្បកម្មផលិតឥដ្ឋ–ក្បឿង ។	១៤៨
៣១-០១-៩៧	ប្រកាសលេខ ៧២ ផក.ប្រក. អនុញ្ញាតអោយលោក **ឆែន ខេមិន** ជនជាតិខ្មែរ សញ្ជាតិកម្ពុជា បន្តដំណើរការឧស្សាហកម្មតូចផលិតទឹកកកដើម	១៤៩
៣១-០១-៩៧	ប្រកាសលេខ ៧៣ ផក.ប្រក. អនុញ្ញាតអោយលោក **ឡាយ សុខធ្វី** ជនជាតិខ្មែរ សញ្ជាតិកម្ពុជា បើកដំណើរការសិប្បកម្មស្រាកែច្នៃសញ្ញា «ហនុមាន»	១៤៩
៣១-០១-៩៧	ប្រកាសលេខ ៧៤ ផក.ប្រក. អនុញ្ញាតអោយលោក **អ៊ីច ជុំតេច** ជនជាតិខ្មែរ សញ្ជាតិកម្ពុជា បើកដំណើរការសិប្បកម្មផលិតទឹកស៊ីអ៊ីវ សញ្ញា «រូបឃ្មុំ»	១៥០
៣១-០១-៩៧	ប្រកាសលេខ ៧៥ ផក.ប្រក. អនុញ្ញាតជូនលោក **ឃួន ហៀក** ជនជាតិខ្មែរ សញ្ជាតកម្ពុជា បើកដំណើរការរោងម៉ាស៊ីនកិនស្រូវកំលាំង ៨០ សេះ	១៥១
៣១-០១-៩៧	ប្រកាសលេខ ៧៦ ផក.ប្រក. អនុញ្ញាតជូនលោក **លឹម ចាន់ សុគី** ជនជាតិខ្មែរ សញ្ជាតិកម្ពុជា បន្តដំណើរការឡផលិតឥដ្ឋ– ក្បឿង	១៥១
៣១-០១-៩៧	ប្រកាសលេខ ៧៧ ផក.ប្រក. អនុញ្ញាតជូនលោក **មួច យ៉ាដាច** ជនជាតិខ្មែរ សញ្ជាតិកម្ពុជា ផ្ទេរសិទ្ធិគ្រប់គ្រងឡផលិតឥដ្ឋ–ក្បឿងជូនលោក **ឡូ ម៉េង** គ្រប់គ្រងវិញ	១៥២

៣១-០១-៩៧	ប្រកាសលេខ ៧៨ ផក.ប្រក. អនុញ្ញាតជូនលោក **ឡុង ខ៉េត** ជនជាតិខ្មែរ សញ្ជាតិកម្ពុជា បន្តដំណើរការរោងម៉ាស៊ីនកិនស្រូវ កំលាំង ៦០ សេះ	១៥៣
៣១-០១-៩៧	ប្រកាសលេខ ៧៩ ផក.ប្រក. អនុញ្ញាតអោយលោក **ឃឹម ខួន** ជនជាតិខ្មែរ សញ្ជាតិកម្ពុជា បន្តដំណើរការឡផលិតឥដ្ឋ-ក្បឿង	១៥៣

៣ - **និស្តិការរដ្ឋន្រ្តី ក្រសួងសាធារណការ និង ដឹកជញ្ជូន**

សេចក្តីសំរេច

២១-០១-៩៧	សេចក្តីសំរេចលេខ ៥១ សក១.សសរ. ស្តីពីការតែងតាំងគណ:កម្មការមួយ ដើម្បីសិក្សាស្រាវជ្រាវ និងផ្តល់យោបល់លើឯកសារ Preliminasy Design Audit ព្រមជាមួយ Detailid Programme Plan. Preminary Desingn និងពង្រាងកិច្ចសន្យាបន្ថែម ស្តីពីការសាងសង់ព្រលានយន្តហោះអន្តរជាតិពោធិចិនតុង ។	១៥៤
២១-០១-៩៧	សេចក្តីសំរេចលេខ ០៥៦ សក.សសរ. ស្តីពីការបង្កើតគណ:កម្មការកម្មវិធីអនុវត្តន៍ធម្មការពិភពលោក ។	១៥៦

ប្រកាស

២១-០១-៩៧	ប្រកាសលេខ ០៥៣ ប្រក.សកហវ. ស្តីពីការកំរិតកំណត់ថ្លៃឈ្នួលអាជីវកម្ម- សេវាកម្ម និង ពន្ធផ្សេងៗ របស់កំពង់ផែក្រុងព្រះសីហនុ ។	១៥៩

៤ - **និស្តិការរដ្ឋន្រ្តី ក្រសួងពត៌មាន**

ប្រកាស

១៧-០១-៩៧	ប្រកាសលេខ ១១៩/៩៧ ពម.ប្រក. ស្តីពីការអនុញ្ញាតអោយលោក **លឹម អែលឡុវ៉ាដ្ឋ** ផ្ទេរសិទ្ធិនិពន្ធនាយកទស្សនាវដ្តី «ជីវជីវិតភាយ» ជូនទៅលោកស្រី **សរ សុរិយា** និពន្ធនាយិកា	

ជិនួសវិញ ។ ១៧៨

២១-០១-៩៧ ប្រកាសលេខ ០២០/៩៧ ពម. ប្រក. អនុញ្ញាតអោយចេញផ្សាយសារពត៌មាន «ព្រលឹងជាតិ» ចេញផ្សាយជាភាសាចិន ដោះពុម្ព ចែកផ្សាយ ដោយមានលោក **ខួច ម៉ុនធៀន** ជាចាងហ្វាងការផ្សាយ ។ ១៨០

២១-០១-៩៧ ប្រកាសលេខ ០២១/៩៧ ពម. ប្រក. អនុញ្ញាតអោយសារពត៌មាន «កុលបុត្រអង្គរ» បន្តការចេញផ្សាយឡើងវិញ ដោយមានលោក **គង្គ សុខណ្ណរ៉ុ** ជាចាងហ្វាងការផ្សាយ ។ ១៨១

៥ - ទីស្តីការរដ្ឋមន្ត្រី ក្រសួងអប់រំ យុវជន និង កីឡា

ប្រកាស

១៦-០១-៩៧ ប្រកាសលេខ ៤៧/ អយក. ប្រក. ស្តីពីការបើកអនុវិទ្យាល័យ សម្តេចក្រុមព្រះ **នរោត្តម រណឫទ្ធិ** ក្នុងឃុំអូរអំបិល ស្រុក សិរីសោភ័ណ ខេត្តបន្ទាយមានជ័យ ។ ១៨៣

១៦-០១-៩៧ ប្រកាសលេខ ៤៨ អយក. ប្រក. ស្តីពីការបើកអនុវិទ្យាល័យ **ម៉ិន រ៉ានី ហ៊ុន សែន** «ស្វាយម» ។ ១៨៥

១៦-០១-៩៧ ប្រកាសលេខ ៤៩ អយក. ប្រក. ស្តីពីការបើកអនុវិទ្យាល័យ **ហ៊ុន សែន** «ត្នោតជុំ» ក្នុងអូរសារាយ ស្រុកត្រាំកក់ ខេត្តតាកែវ។ ១៨៦

១៦-០១-៩៧ ប្រកាសលេខ ៥០ អយក. ប្រក. ស្តីពីការពង្រីកអនុវិទ្យាល័យ **បាធាយ** វិទ្យាល័យ **បាធាយ** ក្នុងស្រុកបាធាយ ខេត្តកំពង់ចាម ។ ១៨៨

១៦-០១-៩៧ ប្រកាសលេខ ៥១ អយក. ប្រក. ស្តីពីការផ្តាច់វិទ្យាល័យអង្គប្រិយ៍ ឧបសម្ព័ន្ធនៃវិទ្យាល័យ **សម្តេចឳ** ទៅជាវិទ្យាល័យ **អង្គប្រិយ៍** ក្នុងស្រុកសំរោង ខេត្តតាកែវ ។ ១៨៩

២១-០១-៩៧ ប្រកាសលេខ ៦៤ អយក. ប្រក. ស្តីពីការប្តូរឈ្មោះសាលាបឋម

	សិក្សាបណ្ឌុះវិជ្ជា មកជាសាលាបឋមសិក្សា សុធារស ។	១៩១
២២-០១-៩៧	ប្រកាសលេខ ៦៩ អយក.ប្រក.ស្តីពីការប្តូរឈ្មោះសាលាបឋមសិក្សាតានី មកជាសាលាបឋមសិក្សា **អេងមាសតានី** ឃុំតាន់ ស្រុកអង្គរជ័យ ខេត្តកំពត ។	១៩៣
២៣-០១-៩៧	ប្រកាសលេខ ៧០ អយក.ប្រក. ស្តីពីការប្តូរឈ្មោះ សាលាបឋមសិក្សា «អង្គរវ៉ៅឡុំរ៉េន» មកជាសាលាបឋមសិក្សា «**អង្គបរិច្ចាគ** »	១៩៤

៦ - ទីស្តីការ ក្រសួងធម្មការ និង សាសនា

សេចក្តីសំរេច

២០-០១-៩៧	សេចក្តីសំរេចលេខ ១០/៩៧ កធស.អនុញ្ញាតអោយសាងសង់វិហារឥស្លាម សាលារៀន អាគារសិក្សាស្នាក់នៅ និង ការិយាល័យមួយខ្នងក្នុងភូមិជ្រោយមេត្រី ឃុំឫស្សីជ្រោយ ស្រុកមុខកំពូល ខេត្តកណ្តាល ។	១៩៦

I- ខុទ្ទកាល័យព្រះមហាក្សត្រ

ព្រះរាជក្រឹត្យ

ព្រះរាជក្រឹត្យ នស/រកត/០១៩៧/០៦

យើង

ព្រះបាទសម្តេចព្រះ នរោត្តម សីហនុ

រាជហរិវង្ស ឧភតោសុជាត វិសុទ្ធពង្ស

អគ្គមហាបុរសរតន៍ និករោត្តម

ធម្មិកមហារាជាធិរាជ បរមនាថ បរមបពិត្រ

ព្រះចៅក្រុងកម្ពុជាធិបតី

* * *

– បានឃើញរដ្ឋធម្មនុញ្ញ នៃព្រះរាជាណាចក្រកម្ពុជា ឆ្នាំ ១៩៩៣

– បានឃើញព្រះរាជក្រឹត្យ ស្តីពីការតែងតាំងរាជរដ្ឋាភិបាលកម្ពុជា ចុះថ្ងៃទី ០១ ខែ វិច្ឆិកា ឆ្នាំ ១៩៩៣ ស្តីពីការតែងតាំងរាជរដ្ឋាភិបាលកម្ពុជា

– យោងតាមសំណើរបស់នាយករដ្ឋមន្ត្រីទី១ និងនាយករដ្ឋមន្ត្រីទី២ នៃរាជរដ្ឋាភិបាលជាតិកម្ពុជា ចុះថ្ងៃទី ២១ ខែ មករា ឆ្នាំ ១៩៩៧

ត្រាស់បង្គាប់

មាត្រា ១ : តែងតាំងលោក **នុត សារាន** ជាទីប្រឹក្សាឯកឧត្តម **ស ខេង** ឧបនាយករដ្ឋមន្ត្រី នៃរាជរដ្ឋាភិបាល មានឋានៈស្មើ អនុរដ្ឋលេខាធិការ ។

មាត្រា ២ : នាយករដ្ឋមន្ត្រីទី១ និងនាយករដ្ឋមន្ត្រីទី២ នៃរាជរដ្ឋាភិបាលកម្ពុជា ត្រូវទទួលបន្ទុកអនុវត្តអោយបានសំរេចនូវព្រះរាជក្រឹត្យនេះ ។

មាត្រា ៣ : ព្រះរាជក្រឹត្យនេះ ចូលជាធរមាន ចាប់ពីថ្ងៃឡាយព្រះហស្ថលេខានេះតទៅ ។

ធ្វើនៅរាជធានីភ្នំពេញ, ថ្ងៃទី ២៣ ខែ មករា ឆ្នាំ ១៩៩៧

ព្រះហស្ថលេខា

នរោត្តម សីហនុ

* * *

ព្រះរាជក្រឹត្យ នស/រកត/០១៩៧/០៧

យើង

ព្រះបាទសម្ដេចព្រះ នរោត្តម សីហនុ

ព្រះមហាក្សត្រ នៃព្រះរាជាណាចក្រកម្ពុជា

តែងតាំង

លោក ខៀវ សុវណ្ណ

ជា

ឧកញ៉ា

រាជធានីភ្នំពេញ , ថ្ងៃទី ២៣ ខែ មករា ឆ្នាំ ១៩៩៧

ព្រះហស្ថលេខា

នរោត្តម សីហនុ

* * *

II- ទីស្ដីការគណៈរដ្ឋមន្ត្រី

១— អនុក្រឹត្យ

រាជធានីភ្នំពេញ , ថ្ងៃទី ១៧ ខែ មករា ឆ្នាំ ១៩៩៧

អនុក្រឹត្យ

លេខ ០៣ អនក្រ.បក

ស្ដីពីការបង្កើតស្ថានឯកអគ្គរាជទូត

នៃព្រះរាជាណាចក្រកម្ពុជា ប្រចាំសាធារណរដ្ឋហ្វីលីពីន

* * *

រាជរដ្ឋាភិបាលកម្ពុជា

- បានឃើញរដ្ឋធម្មនុញ្ញ នៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រឹត្យ ចុះថ្ងៃទី ០១ ខែ វិច្ឆិកា ឆ្នាំ ១៩៩៣ ស្ដីពីការតែងតាំងរាជរដ្ឋាភិបាលកម្ពុជា
- បានឃើញព្រះរាជក្រឹត្យលេខ នស.រកត ១០៩៤.៩០ ចុះថ្ងៃទី ៣១ ខែ តុលា ឆ្នាំ ១៩៩៤ ស្ដីពីការ កែសំរួលសមាសភាពរាជរដ្ឋាភិបាលកម្ពុជា
- បានឃើញព្រះរាជក្រមលេខ ០២.នស.៩៤ ចុះថ្ងៃទី ២០ កក្កដា ១៩៩៤ ប្រកាសអោយប្រើច្បាប់ស្ដីពី ការរៀបចំ និងការប្រព្រឹត្តិទៅរបស់គណៈរដ្ឋមន្ត្រី
- បានឃើញព្រះរាជក្រមលេខ នស.រកម. ០១៩៦.១០ ចុះថ្ងៃទី ២៤ មករា ១៩៩៦ ប្រកាសអោយប្រើច្បាប់ស្ដីពីការបង្កើតក្រសួងការបរទេស និង សហប្រតិបត្តិការអន្តរជាតិ
- តាមសំណើរបស់រដ្ឋមន្ត្រីការបរទេស និងសហប្រតិបត្តិការអន្តរជាតិ

សម្រេច

មាត្រា ១ : បង្កើតស្ថានឯកអគ្គរាជទូតកម្ពុជាប្រចាំសាធារណរដ្ឋហ្វីលីពីន ដោយមាននិវេសនដ្ឋាននៅក្រុង ម៉ានីល ។

មាត្រា ២ : ស្ថានឯកអគ្គរាជទូតនេះ ត្រូវដឹកនាំដោយប្រធានបេសកកម្មទូតម្នាក់ ដែលមានឋានៈជាឯកអគ្គរាជទូត វិសាមញ្ញ និង ពេញសមត្ថភាព ។

មាត្រា ៣ : សមាសភាពមន្ត្រីការទូតផ្សេងទៀត យ៉ាងច្រើនបំផុតបួននាក់ នឹងត្រូវកំណត់តាមលក្ខការណ៍ការទូត នៃព្រះរាជាណាចក្រកម្ពុជា ។ រីឯបុគ្គលិកមិនមែនការទូតទាំងឡាយ នឹងត្រូវកំណត់ដោយរដ្ឋមន្ត្រីការបរទេស និង សហប្រតិបត្តិការអន្តរជាតិ ។

មាត្រា ៤ : មន្ត្រីការទូតតំណាងសេដ្ឋកិច្ច ពាណិជ្ជកម្ម ត្រូវជ្រើសតាំងយកអ្នកមានជំនាញពីមួយនាក់ទៅពីរនាក់ ។

មាត្រា ៥ : ប្រព័ន្ធហិរញ្ញកិច្ចសំរាប់មន្ត្រី និង បុគ្គលិក នៃស្ថានឯកអគ្គរាជទូតនេះ នឹងស្ថិតក្នុងប្រភេទ « ខ » ។

មាត្រា ៦ : សហរដ្ឋមន្ត្រីទទួលបន្ទុកទីស្តីការគណៈរដ្ឋមន្ត្រី រដ្ឋមន្ត្រីការបរទេស និង សហប្រតិបត្តិការអន្តរជាតិ រដ្ឋមន្ត្រីពាណិជ្ជកម្ម រដ្ឋមន្ត្រីសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ រដ្ឋលេខាធិការមុខងារសាធារណៈ ត្រូវទទួលបន្ទុករៀងៗ ខ្លួន អនុវត្តអនុក្រឹត្យនេះចាប់ពីថ្ងៃឡាយព្រះហស្តលេខា និង ចុះហត្ថលេខាតទៅ ។

នាយករដ្ឋមន្ត្រីទី១	**នាយករដ្ឋមន្ត្រីទី២**
ព្រះហស្តលេខា និង ត្រា	**ហត្ថលេខា និង ត្រា**
នរោត្តម រណឫទ្ធិ	**ហ៊ុន សែន**

* * *

រាជធានីភ្នំពេញ , ថ្ងៃទី ១៧ ខែ មករា ឆ្នាំ ១៩៩៧

អនុក្រឹត្យ

លេខ ០៤ អនក្រ.បក

ស្តីពីការបង្កើតស្ថានឯកអគ្គរាជទូតនៃព្រះរាជាណាចក្រកម្ពុជា ប្រចាំសហព័ន្ធម៉ាឡេស៊ី

* * *

រាជរដ្ឋាភិបាលកម្ពុជា

- បានឃើញរដ្ឋធម្មនុញ្ញ នៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រឹត្យចុះថ្ងៃទី ០១ វិច្ឆិកា ឆ្នាំ ១៩៩៣ ស្តីពីការតែងតាំងរាជរដ្ឋាភិបាលកម្ពុជា
- បានឃើញព្រះរាជក្រឹត្យលេខ នស.រកត ១០៩៤.៩០ ចុះថ្ងៃទី ៣១ ខែ តុលា ឆ្នាំ ១៩៩៤ ស្តីពីការ កែសម្រួលសមាសភាពរាជរដ្ឋាភិបាលកម្ពុជា
- បានឃើញព្រះរាជក្រមលេខ ០២នស.៩៤ ចុះថ្ងៃទី ២០ កក្កដា ១៩៩៤ ប្រកាសអោយប្រើច្បាប់ស្តីពី ការរៀបចំ និងការប្រព្រឹត្តទៅរបស់គណៈរដ្ឋមន្ត្រី
- បានឃើញព្រះរាជក្រមលេខ នស.រកម ០១៩៦.១០ ចុះថ្ងៃទី ២៤ មករា ១៩៩៦ ប្រកាសអោយប្រើច្បាប់ ស្តីពីការបង្កើតក្រសួងការបរទេសនិងសហប្រតិបត្តិការអន្តរជាតិ
- តាមសំណើរបស់រដ្ឋមន្ត្រីការបរទេស និងសហប្រតិបត្តិការអន្តរជាតិ

សម្រេច

មាត្រា ១ : បង្កើតស្ថានឯកអគ្គរាជទូតកម្ពុជាប្រចាំសហព័ន្ធម៉ាឡេស៊ី ដោយមានទីស្នាក់ការនៅក្រុងកូឡាឡាំពួរ ។

មាត្រា ២ : ស្ថានឯកអគ្គរាជទូតនេះ ត្រូវដឹកនាំដោយប្រធានបេសកកម្មទូតម្នាក់ ដែលមានឋានៈជាឯកអគ្គរាជ ទូតវិសាមញ្ញនិងពេញសមត្ថភាព ។

មាត្រា ៣ : សមាសភាពមន្ត្រីការទូតផ្សេងទៀត យ៉ាងច្រើនបំផុតបួននាក់ នឹងត្រូវកំណត់តាមលក្ខការណ៍ការទូត នៃព្រះរាជាណាចក្រកម្ពុជា ។ រីឯបុគ្គលិកមិនមែនការទូតទាំងឡាយនឹងត្រូវកំណត់ដោយរដ្ឋមន្ត្រីការបរទេសនិងសហប្រតិបត្តិការអន្តរជាតិ។

មាត្រា ៤ : មន្ត្រីការទូតតំណាងសេដ្ឋកិច្ច ពាណិជ្ជកម្ម ត្រូវជ្រើសតាំងយកអ្នកមានជំនាញពីមួយនាក់ទៅពីរនាក់ ។

មាត្រា ៥ : អនុព័ន្ធយោធាម្នាក់ ត្រូវជ្រើសតាំងដោយក្រសួងការពារប្រទេស ។

មាត្រា ៦ : ប្រព័ន្ធហិរញ្ញកិច្ចសំរាប់មន្ត្រីនិងបុគ្គលិកនៃស្ថានឯកអគ្គរាជទូតនេះ នឹងស្ថិតក្នុងប្រភេទ « ខ » ។

មាត្រា ៧ : សហរដ្ឋមន្ត្រីទទួលបន្ទុកទីស្តីការគណៈរដ្ឋមន្ត្រី រដ្ឋមន្ត្រីការបរទេស និងសហប្រតិបត្តិការអន្តរជាតិ រដ្ឋមន្ត្រីពាណិជ្ជកម្ម រដ្ឋមន្ត្រីការពារប្រទេស រដ្ឋមន្ត្រីសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ រដ្ឋលេខាធិការមុខងារសាធារណៈ ត្រូវទទួលបន្ទុករៀងៗខ្លួនអនុវត្តអនុក្រឹត្យនេះចាប់ពីថ្ងៃឡាយព្រះហស្តលេខា និងចុះហត្ថលេខាតទៅ ។

នាយករដ្ឋមន្ត្រីទី ១	**នាយករដ្ឋមន្ត្រីទី ២**
ព្រះហស្តលេខា និង ត្រា	**ហត្ថលេខា និង ត្រា**
នរោត្តម រណឫទ្ធិ	**ហ៊ុន សែន**

* * *

រាជធានីភ្នំពេញ , ថ្ងៃទី ១៧ ខែ មករា ឆ្នាំ ១៩៩៧

អនុក្រឹត្យលេខ ០៥ អនក្រ.បក.

ស្តីពីការបង្កើតស្ថានឯកអគ្គរាជទូតនៃ

ព្រះរាជាណាចក្រកម្ពុជាប្រចាំសាធារណរដ្ឋសិង្ហបុរី

* * *

រាជរដ្ឋាភិបាលកម្ពុជា

- បានឃើញរដ្ឋធម្មនុញ្ញ នៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រឹត្យ ចុះថ្ងៃទី ០១ ខែ វិច្ឆិកា ឆ្នាំ ១៩៩៣ ស្តីពីការតែងតាំងរាជរដ្ឋាភិបាលកម្ពុជា
- បានឃើញព្រះរាជក្រឹត្យលេខ នស.រកត ១០៩៤.៩០ ចុះថ្ងៃទី ៣១ ខែ តុលា ឆ្នាំ ១៩៩៤ ស្តីពីការកែ សំរួលសមាសភាពរាជរដ្ឋាភិបាលកម្ពុជា
- បានឃើញព្រះរាជក្រមលេខ ០២ នស.៩៤ ចុះថ្ងៃទី ២០ កក្កដា ១៩៩៤ ប្រកាសអោយប្រើច្បាប់ស្តីពី ការរៀបចំនិងការប្រព្រឹត្តិទៅរបស់គណៈរដ្ឋមន្ត្រី
- បានឃើញព្រះរាជក្រមលេខ នស.រកម ០១៩៦.១០ ចុះថ្ងៃទី ២៤ មករា ១៩៩៦ ប្រកាសអោយប្រើច្បាប់ ស្តីពីការបង្កើតក្រសួងការបរទេស និង សហប្រតិបត្តិការអន្តរជាតិ
- តាមសំណើរបស់រដ្ឋមន្ត្រីការបរទេស និងសហប្រតិបត្តិការអន្តរជាតិ

សំរេច

មាត្រា ១ : បង្កើតស្ថានឯកអគ្គរាជទូតកម្ពុជាប្រចាំសាធារណរដ្ឋសិង្ហបុរី ដោយមានទិវេសនដ្ឋាន់នៅក្រុងសិង្ហបុរី ។

មាត្រា ២ : ស្ថានឯកអគ្គរាជទូតនេះ ត្រូវដឹកនាំដោយប្រធានបេសកកម្មទូតម្នាក់ ដែលមានឋានៈជាឯកអគ្គរាជទូតវិសាមញ្ញ និង ពេញសមត្ថភាព ឬ ជាអគ្គទីប្រឹក្សា និង ជាភារ ធារី ។

មាត្រា ៣ : សមាសភាពមន្ត្រីការទូតផ្សេងទៀត យ៉ាងច្រើនបំផុតបួននាក់ នឹងត្រូវកំណត់តាមលក្ខការណ៍ការទូត នៃព្រះរាជាណាចក្រកម្ពុជា ។ រីឯបុគ្គលិកមិនមែនការទូតទាំងឡាយ នឹងត្រូវកំណត់ដោយរដ្ឋមន្ត្រីការបរទេស និង សហប្រតិបត្តិការអន្តរជាតិ ។

មាត្រា ៤ : មន្ត្រីការទូតតំណាងសេដ្ឋកិច្ច ពាណិជ្ជកម្ម ត្រូវជ្រើសតាំងយកអ្នកមានជំនាញពីមួយ នាក់ទៅពីរនាក់ ។

មាត្រា ៥ : ប្រព័ន្ធហិរញ្ញកិច្ចសំរាប់មន្ត្រី និងបុគ្គលិកនៃស្ថានឯកអគ្គរាជទូតនេះ នឹងស្ថិតក្នុងប្រភេទ « ខ » ។

មាត្រា ៦ : សហរដ្ឋមន្ត្រីទទួលបន្ទុកទីស្តីការគណៈរដ្ឋមន្ត្រី រដ្ឋមន្ត្រីការបរទេស និងសហប្រតិបត្តិការអន្តរជាតិ រដ្ឋមន្ត្រីពាណិជ្ជកម្ម រដ្ឋមន្ត្រីសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ រដ្ឋលេខាធិការមុខងារសាធារណៈ ត្រូវទទួលបន្ទុករៀងៗ ខ្លួន អនុវត្តអនុក្រឹត្យនេះចាប់ពីថ្ងៃឡាយព្រះហស្តលេខា និង ចុះហត្ថលេខាតទៅ ។

នាយករដ្ឋមន្ត្រីទី ១	**នាយករដ្ឋមន្ត្រីទី ២**
ព្រះហស្តលេខា និង ត្រា	**ហត្ថលេខា និងត្រា**
នរោត្តម រណឫទ្ធិ	**ហ៊ុន សែន**

* * *

រាជធានីភ្នំពេញ ,ថ្ងៃទី ២០ មករា ឆ្នាំ ១៩៩៧

អនុក្រឹត្យ

លេខ ០៦ អនក្រ.បក

ស្តីពីការបែងចែកចំណូលថវិកាទូទៅ របស់រដ្ឋសំរាប់ការគ្រប់គ្រងឆ្នាំ ១៩៩៧

* * *

រាជរដ្ឋាភិបាល

– បានឃើញរដ្ឋធម្មនុញ្ញ នៃព្រះរាជាណាចក្រកម្ពុជា

– បានឃើញព្រះរាជក្រឹត្យរបស់ព្រះករុណាព្រះបាទសម្តេចព្រះនរោត្តម សីហនុ ព្រះមហាក្សត្រ នៃព្រះរាជាណាចក្រកម្ពុជា ចុះថ្ងៃទី ០១ ខែ វិច្ឆិកា ឆ្នាំ ១៩៩៣ ស្តីពីការតែងតាំងរាជរដ្ឋាភិបាលកម្ពុជា

– បានឃើញច្បាប់ស្តីពីការរៀបចំ និង ការប្រព្រឹត្តិទៅនៃគណៈរដ្ឋមន្ត្រី ដែលប្រកាសអោយប្រើដោយ ព្រះរាជក្រម ចុះថ្ងៃទី ២០ ខែ កក្កដា ឆ្នាំ ១៩៩៤

– បានឃើញព្រះរាជក្រឹត្យ នស/រកត/១០៩៤/៨៣ ចុះថ្ងៃទី ២៤ ខែ តុលា ឆ្នាំ ១៩៩៤ ស្តីពីការសំរួលសមាសភាពរាជរដ្ឋាភិបាល

– បានឃើញច្បាប់ស្តីពីអំពីប្រព័ន្ធហិរញ្ញវត្ថុ ដែលប្រកាសអោយប្រើដោយ ព្រះរាជក្រមលេខ ០១ នស៩៣ ចុះថ្ងៃទី ២៨ ខែ ធ្នូ ឆ្នាំ ១៩៩៣

– បានឃើញច្បាប់ស្តីពីហិរញ្ញវត្ថុសំរាប់ការគ្រប់គ្រង ឆ្នាំ ១៩៩៧ ដែលរដ្ឋសភាបានអនុម័តនៅថ្ងៃទី ៣០ ខែ ធ្នូ ឆ្នាំ ១៩៩៦

– តាមសំណើរបស់រដ្ឋមន្ត្រីក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ

សំរេច

មាត្រា ១ : ចំណូលជាប្រចាំ និង ជាមូលធននៃថវិកាទូទៅរបស់រដ្ឋ ដែលបានគ្រោងទុក និង អនុញ្ញាតដោយច្បាប់ ស្តីពីហិរញ្ញវត្ថុសំរាប់ការគ្រប់គ្រងឆ្នាំ ១៩៩៧ ដែលរដ្ឋសភា

អនុម័តនៅថ្ងៃទី ៣០ ខែ ធ្នូ ឆ្នាំ ១៩៩៦ ត្រូវបានបែងចែកតាមក្រសួង និង ស្ថាប័នប្រហាក់ប្រហែលនីមួយៗ ដែលមានប្រភពចំណូល និងតាមជំពូក នៃចរិកា ដោយអនុលោមទៅតាមតារាងដូចមានភ្ជាប់នឹងអនុក្រឹត្យនេះ ។

មាត្រា ២ : ចំណូលត្រូវប្រមូលដើម្បីជាគុណប្រយោជន៍ដល់ចរិកាទូទៅរបស់រដ្ឋ និង ស្ថិតនៅក្រោមការត្រួតពិនិត្យរបស់រដ្ឋមន្ត្រីក្រសួងសេដ្ឋកិច្ច និង ហិរញ្ញវត្ថុ ។ ការបែងចែកចំណូលនៃជំពូកទាំងនេះតាមប្រការ កថាខ័ណ្ឌ និង វាក្យខ័ណ្ឌ ត្រូវកំណត់ដោយប្រកាសរបស់រដ្ឋមន្ត្រីក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ ។

មាត្រា ៣ : សហរដ្ឋមន្ត្រីទទួលបន្ទុកទីស្តីការគណៈរដ្ឋមន្ត្រី រដ្ឋមន្ត្រីក្រសួងសេដ្ឋកិច្ច និង ហិរញ្ញវត្ថុ រដ្ឋមន្ត្រីគ្រប់ក្រសួង រដ្ឋលេខាធិការ គ្រប់រដ្ឋលេខាធិការដ្ឋាន អភិបាលគ្រប់ខេត្ត - ក្រុង ត្រូវទទួលអនុវត្តអនុក្រឹត្យនេះចាប់ពីថ្ងៃទី ០១ ខែ មករា ឆ្នាំ ១៩៩៧ តទៅ ។

បានយកសេចក្តីក្រាបទូល និង ជំរាប សម្តេចនាយករដ្ឋមន្ត្រី ដើម្បីឡាយព្រះហស្តលេខា និង ចុះហត្ថលេខា	នាយករដ្ឋមន្ត្រីទី ១	នាយករដ្ឋមន្ត្រីទី ២
រដ្ឋមន្ត្រីក្រសួងសេដ្ឋកិច្ច និង ហិរញ្ញវត្ថុ	ព្រះហស្តលេខា និង ត្រា	ហត្ថលេខា និង ត្រា
គាត ឈន់	**នរោត្តម រណឫទ្ធិ**	**ហ៊ុន សែន**

* * *

ការគ្រប់គ្រង ឆ្នាំ ១៩៩៧

តារាងបែងចែកចំណូលជាប្រចាំ និង ជាមូលធន

ឯកតា : លានរៀល

ជំពូក	បរិយាយ	ចំនួនទឹកប្រាក់
	០១ ព្រះបរមរាជវាំង	
២១	ចំណូលផ្សេងៗពុំមែនសារពើពន្ធ	៦០
	សរុប ០១	៦០
	០៣– គណៈរដ្ឋមន្ត្រី	

	ផ្នែក១– ទីស្ដីការគណៈរដ្ឋមន្ត្រី	
២០	ផលខុនផ្សេងៗនៃទ្រព្យសម្បត្តិរដ្ឋ	៥.៤៨០
២១	ចំណូលផ្សេងៗពុំមែនសារពើពន្ធ	៧៣០
	សរុបផ្នែក ១	៦.២១០
	ផ្នែក៧ –អាកាសចរស៊ីវិល	
២០	ផលខុនផ្សេងៗ នៃទ្រព្យសម្បត្តិរដ្ឋ	១៦.៥០០
	សរុបផ្នែក ៧	១៦.៥០០
	សរុប ០៣	២២.៧១០
	០៤– ក្រសួងការបរទេស	
២០	ផលខុនផ្សេងៗនៃទ្រព្យសម្បត្តិរដ្ឋ	១.១៥០
២១	ចំណូលផ្សេងៗពុំមែនសារពើពន្ធ	២.៦០០
	សរុប ០៤	៣.៧៥០
	០៥– ក្រសួងការពារជាតិ	
២០	ផលខុនផ្សេងៗនៃទ្រព្យសម្បត្តិរដ្ឋ	១.៦០០
	សរុប ០៥	១.៦០០
	០៦– ក្រសួងមហាផ្ទៃ	
	ផ្នែក ១ សន្តិសុខសាធារណៈ	
២០	ផលខុនផ្សេងៗ នៃទ្រព្យសម្បត្តិរដ្ឋ	២០
២១	ចំណូលផ្សេងៗ ពុំមែនសារពើពន្ធ	១១.៥០០
	សរុបផ្នែក ១	១១.៥២០
	ផ្នែក ៩ – ខេត្ត ក្រុងនានា	
២០	ផលខុនផ្សេងៗនៃទ្រព្យសម្បត្តិរដ្ឋ	១២.៤៨៦
២១	ចំណូលផ្សេងៗពុំមែនសារពើពន្ធ	៥
	សរុបផ្នែក ៩	១២.៤៩១
	សរុប ០៦	២៤.០១១
	០៧– ក្រសួងសេដ្ឋកិច្ច និង ហិរញ្ញវត្ថុ	
ជំពូក	បរិយាយ	ចំនួនទឹកប្រាក់

	ផ្នែក ១— រដ្ឋបាលកណ្តាល	
	ពន្ធដារ	១០០.០០០
១០	ពន្ធលើផលទុនប្រាក់ចំណេញ និងកំរៃទុន	៤០.៣០០
១១	ពន្ធលើបេតិកភ័ណ្ឌ	៤.០០០
១២	ពន្ធផ្ទៃក្នុងលើទ្រព្យសម្បត្តិ និង សេវាកម្ម	៥០.២៦០
១៤	ចំណូលសារពើពន្ធផ្សេងៗទៀត	៥.៤០០
២១	ចំណូលផ្សេងៗពុំមែនសារពើពន្ធ	៤០
	គយ និង រដ្ឋាករ	៥៧៥.០៦០
១២	ពន្ធផ្ទៃក្នុងលើទ្រព្យសម្បត្តិ និង សេវាកម្ម	១៣៥.៣០០
១៣	ពន្ធលើពាណិជ្ជកម្មក្រៅប្រទេស	៤៣៧.៨០០
១៤	ចំណូលសារពើពន្ធផ្សេងៗ ទៀត	២៤០
២០	ផលទុនផ្សេងៗនៃទ្រព្យសម្បត្តិរដ្ឋ	៥០០
២១	ចំណូលផ្សេងៗពុំមែនសារពើពន្ធ	១.២២០
	ចំណូលជាមូលធន	៦០០.១០០
៣១	អំណោយពីបរទេស	៥៥១.៤៥០
៣២	ប្រភពទ្រព្យសម្បត្តិបានមកពីការខ្ចីបុល	៤៨.៦៥០
	សរុបផ្នែក ១	១.២៧៥.១៦០
	ផ្នែក ៩ - ខេត្ត ក្រុងនានា	
២០	ផលទុនផ្សេងៗនៃទ្រព្យសម្បត្តិរដ្ឋ	៥.៣៨២
២១	ចំណូលផ្សេងៗពុំមែនសារពើពន្ធ	៥៩០
	សរុបផ្នែក ៩	៥.៩៧២
	សរុប ០៧	១.២៨១.១៣២
	០៨ ក្រសួងពាណិជ្ជកម្ម	
	ផ្នែក ១ រដ្ឋបាលកណ្តាល	
២០	ផលទុនផ្សេងៗនៃទ្រព្យសម្បត្តិរដ្ឋ	៣០០
២១	ចំណូលផ្សេងៗពុំមែនសារពើពន្ធ	៤៧៣
	សរុបផ្នែក ១	៧៧៣
	ផ្នែក ៩ ខេត្ត ក្រុងនានា	

២១	ចំណូលផ្សេងៗពុំមែនសារពើពន្ធ	២០
	សរុបផ្នែក ៩	២០
	សរុប ០៨	៧៩៣
	០៩ ក្រសួងសាធារណការ និងដឹកជញ្ជូន	
	ផ្នែក ១ - រដ្ឋបាលកណ្តាល	
២០	ផលទុនផ្សេងៗនៃទ្រព្យសម្បត្តិរដ្ឋ	២.២១៥
២១	ចំណូលផ្សេងៗពុំមែនសារពើពន្ធ	៥១៥
	សរុបផ្នែក ១	២.៧៣០
	ផ្នែក ៩ - ខេត្ត ក្រុងនានា	
២០	ផលទុនផ្សេងៗនៃទ្រព្យសម្បត្តិរដ្ឋ	២០៥៦,១
២១	ចំណូលផ្សេងៗពុំមែនសារពើពន្ធ	៩០
	សរុបផ្នែក ៩	២.១៤៦,១
	សរុប ០៩	៤.៨៧៦,១
	១០- ក្រសួងកសិកម្ម	
	ផ្នែក ១ - រដ្ឋបាលកណ្តាល	
២០	ផលទុនផ្សេងៗនៃទ្រព្យសម្បត្តិរដ្ឋ	៣៩.៣៥៤,៧
២១	ចំណូលផ្សេងៗពុំមែនសារពើពន្ធ	១.១៥០
	សរុបផ្នែក ១	៤០.៥០៤,៧
	ផ្នែក ៩ -ខេត្ត ក្រុងនានា	
២០	ផលទុនផ្សេងនៃទ្រព្យសម្បត្តិរដ្ឋ	៣៥៦,៣
២១	ចំណូលផ្សេងៗពុំមែនសារពើពន្ធ	៤៥
	សរុបផ្នែក ៩	៤០១,៣
	សរុប ១០	៤០.៩០៦,០
	១១- ក្រសួងយុត្តិធម៌	
	ផ្នែក ២ - តុលាការជាន់ខ្ពស់	
២១	ចំណូលផ្សេងៗពុំមែនសារពើពន្ធ	៦០
	សរុបផ្នែក ២	៦០
	ផ្នែក៣- សាលាឧទ្ធរណ៍	

២៧	ចំណូលផ្សេងៗពុំមែនសារពើពន្ធ	១០
	សរុបផ្នែក ៣	១០
	សរុប ១១	៧០
	១២- ក្រសួងអប់រំ យុវជន និងកីឡា	
	ផ្នែក ១- អប់រំ	
២០	ផលទុនផ្សេងៗនៃទ្រព្យសម្បត្តិរដ្ឋ	៦៩
២៧	ចំណូលផ្សេងៗពុំមែនសារពើពន្ធ	២៤១
	សរុបផ្នែក ១	៣១០
	ផ្នែក ៩- ខេត្ត ក្រុងនានា	
២០	ផលទុនផ្សេងៗនៃទ្រព្យសម្បត្តិរដ្ឋ	២០
២៧	ចំណូលផ្សេងៗពុំមែនសារពើពន្ធ	៥៥
	សរុបផ្នែក ៩	៧៥
	សរុប ១២	៣៨៥
	១៣- ក្រសួងពាណិជ្ជកម្ម	
	ផ្នែក ១ - រដ្ឋបាលកណ្ដាល	
២០	ផលទុនផ្សេងៗនៃទ្រព្យសម្បត្តិរដ្ឋ	៥៩០
២៧	ចំណូលផ្សេងៗពុំមែនសារពើពន្ធ	៨៣០
៣០	ចំណូលផ្ទេរក្នុងជាមូលធន	៨.១០០
	សរុបផ្នែក ១	៩.៥២០
	ផ្នែក ៩- ខេត្ត ក្រុងនានា	
២០	ផលទុនផ្សេងៗព្រទ្យសម្បត្តិរដ្ឋ	១៦០
	សរុបផ្នែក ៩	១៦០
	សរុប ១៣	៩.៦៨០
	១៤- ក្រសួងឧស្សាហកម្មរ៉ែ និង ថាមពល	
	ផ្នែក ១ - រដ្ឋបាលកណ្ដាល	
២០	ផលទុនផ្សេងៗនៃទ្រព្យសម្បត្តិរដ្ឋ	១២.៦៩៥
៣០	ចំណូលផ្ទេរក្នុងជាមូលធន	៣.៣០០

		សរុបផ្នែក១	១៥.៩៩៥
	ផ្នែក៩ - ខេត្ត ក្រុងនានា		
២០	ផលទុនផ្សេងៗនៃទ្រព្យសម្បត្តិរដ្ឋ		៤០៤,៩
២១	ចំណូលផ្សេងៗពុំមែនសារពើពន្ធ		៥
		សរុបផ្នែក ៩	៤០៩,៩
		សរុប ១៤	១៦.៤០៤,៩
	១៥- ក្រសួងផែនការ		
	ផ្នែក ១– រដ្ឋបាលកណ្តាល		
២០	ផលទុនផ្សេងៗនៃទ្រព្យសម្បត្តិរដ្ឋ		១១៥
		សរុប ១៥	១១៥
	១៦- ក្រសួងសុខាភិបាល		
	ផ្នែក ១ - រដ្ឋបាលកណ្តាល		
២០	ផលទុនផ្សេងៗនៃទ្រព្យសម្បត្តិរដ្ឋ		២៥
២១	ចំណូលផ្សេងៗពុំមែនសារពើពន្ធ		១០០
		សរុបផ្នែក ១	១២៥
	ផ្នែក ៩- ខេត្តក្រុងនានា		
២១	ចំណូលផ្សេងៗពុំមែនសារពើពន្ធ		៥
		សរុបផ្នែក ៩	៥
		សរុប ១៦	១៣០
	១៧- ក្រសួងទេសចរណ៍		
	ផ្នែក ១ រដ្ឋបាលកណ្តាល		
២០	ផលទុនផ្សេងៗនៃទ្រព្យសម្បត្តិរដ្ឋ		៣.៦៧៣
២១	ចំណូលផ្សេងៗពុំមែនសារពើពន្ធ		៣០
		សរុបផ្នែក ១	៣.៧០៣
	ផ្នែក ៩ - ខេត្ត ក្រុងនានា		
២០	ផលទុនផ្សេងៗនៃទ្រពសម្បត្តិរដ្ឋ		១៣០
		សរុបផ្នែក ៩	១៣០
		សរុប ១៧	៣.៨៣៣

	១៩- ក្រសួងប្រៃសណីយ៍ និងទូរគមនាគមន៍	
	ផ្នែក ១ - រដ្ឋបាលកណ្ដាល	
២០	ផលទុនផ្សេងៗនៃទ្រព្យសម្បត្តិរដ្ឋ	៧៥
២១	ចំណូលផ្សេងៗពុំមែនសារពើពន្ធ	៨១.០០០
	សរុបផ្នែក ១	៨១.០៧៥
	ផ្នែក៩ - ខេត្តក្រុងនានា	
២១	ចំណូលផ្សេងពុំមែនសារពើពន្ធ	២២០
	សរុបផ្នែក ៩	២២០
	សរុប ១៨	៨១.២៩៥
	២០- ក្រសួងវប្បធម៌ និង វិចិត្រសិល្បៈ	
	ផ្នែក ១ - រដ្ឋបាលកណ្ដាល	
២០	ផលទុនផ្សេងៗនៃទ្រព្យសម្បត្តិរដ្ឋ	៣៣០
២១	ចំណូលផ្សេងៗពុំមែនសារពើពន្ធ	១៨៣
	សរុបផ្នែក ១	៥១៣
	ផ្នែក ៩ - ខេត្តក្រុងនានា	
២០	ផលទុនផ្សេងៗនៃទ្រព្យសម្បត្តិរដ្ឋ	១១
	សរុបផ្នែក ៩	១១
	សរុប ១៩	៥២៤
	២១- ក្រសួងសង្គមកិច្ចការងារ និង អតីតយុទ្ធជន	
២១	ចំណូលផ្សេងៗពុំមែនសារពើពន្ធ	៤៥
	សរុប ២១	៤៥
	២២- ក្រសួងបរិស្ថាន	
២០	ផលទុនផ្សេងៗនៃទ្រព្យសម្បត្តិរដ្ឋ	១៨០
	សរុប ២២	១៨០
	សរុបចំណូលថ្នាក់រដ្ឋបាលកណ្ដាល	១.៤៧៤.៤៥៨,៧
	សរុប ចំណូលខេត្តក្រុង	២២.០៤១,៣
	សរុបរួម	**១.៤៩៦.៥០០**

រាជធានីភ្នំពេញ, ថ្ងៃទី ២១ ខែ មករា ឆ្នាំ ១៩៩៧

អនុក្រឹត្យ

អនុក្រឹត្យលេខ ០៧ អនក្រ.បក
ស្តីពីការរៀបចំឯកសណ្ឋាន ផ្លាកសញ្ញា
និងទង់ជ័យ នៃកងយោធពលខេមរភូមិន្ទ

* * *

រាជរដ្ឋាភិបាល

- បានឃើញរដ្ឋធម្មនុញ្ញ នៃព្រះរាជាណាចក្រកម្ពុជា
- យោងតាមព្រះរាជក្រឹត្យ ចុះថ្ងៃទី ០១ ខែ វិច្ឆិកា ឆ្នាំ ១៩៩៣ ស្តីពីការតែងតាំងរាជរដ្ឋាភិបាលនៃ ព្រះរាជាណាចក្រកម្ពុជា ។
- យោងតាមអនុក្រឹត្យលេខ ០៤ អ.ន.ក្រ ចុះថ្ងៃទី ២៥ ខែ កក្កដា ឆ្នាំ ១៩៩៣ ស្តីពីឯកសណ្ឋាន និងផ្លាកសញ្ញា កងទ័ពជាតិកម្ពុជា ។
- យោងតាមអនុក្រឹត្យលេខ ១៨ អ.ន.ក្រ. ចុះថ្ងៃទី ២០ ខែ មករា ឆ្នាំ ១៩៩៤ ស្តីអំពីឯកសណ្ឋាន បច្ចេកទេស និង ទង់ជ័យ កងយោធពលខេមរភូមិន្ទ ។
- យោងតាមអនុក្រឹត្យលេខ ១៩ អ.ន.ក្រ ចុះថ្ងៃទី ២០ ខែ មេសា ឆ្នាំ១៩៩៤ ស្តីពីការកែតម្រូវ និង បំពេញបន្ថែមអនុក្រឹត្យលេខ ០៤ អ.ន.ក្រ ចុះថ្ងៃទី ២៥ ខែ កក្កដា ឆ្នាំ ១៩៩៣ របស់ រាជរដ្ឋាភិបាលបណ្តោះអាសន្ន ។
- យោងតាមសំណើរបស់សហរដ្ឋមន្ត្រី ក្រសួងការពារជាតិ ចុះថ្ងៃទី ២០ ខែ ៦ ឆ្នាំ ១៩៩៦ ។
- យោងតាមសំណើរបស់អគ្គសេនាធិការ នៃកងយោធពលខេមរភូមិន្ទ ចុះថ្ងៃទី ២៥ ខែ ៥ ឆ្នាំ ១៩៩៦ ។

សំរេច

មាត្រា ១ : ត្រូវបានរៀបចំឯកសណ្ឋានរបស់កងយោធពលខេមរភូមិន្ទ ជាថ្មីដូចខាងក្រោម ÷

រូបភាព ម៉ូត និង ប្រភេទឯកសណ្ឋាន

ក–ឯកសណ្ឋានសំរាប់ថ្នាក់ឧត្តមសេនីយ៍ ជើងគោក :

១–ឯកសណ្ឋានលេខ ១ : (អាវកុដ ស)

អាវកុដស គ្រង់ ខោពណ៌ក្រមៅ មានឆ្នូតក្រហមពីរ មួយធំខ្មៅ ជើងមួក ពណ៌ក្រហម ។

– អាវកុដស ក គ្រង់ កាត់រាង អាវធំ គ្មានផែកខ្នង ក អាវមានប៉ាក់ ដូចធ្មេញរណា ពណ៌មាស ជុំវិញលើស្មា ទាំងសងខាង មានប៉ូល ហោប៉ៅបួន (ហោប៉ៅពីរខាងលើ ដេរប៉ះចំកណ្តាល មានគាប់ផ្ចិតមួយគំរបរាងស្លឹកពោធិ ហោប៉ៅពីរខាងក្រោម ដេរបង្កប់ គំរបរាងចតុកោណកែង) អាវដៃវែង កាត់ម៉ូតដៃបំពង់ លើថ្នេរបត់ចុងដៃអាវ មានប៉ានក្រណាត់ពណ៌មាស ទំហំ ៨ម.មឡេវអាវមានរូបព្រះសង្ហារពណ៌មាស (ឡេវធំ ពី ក មកដល់ក្រោមចំនួន ៦ ឡេវហោប៉ៅ៤ ឡេវប៉ូលស្មាទាំងសងខាង និងដាក់បញ្ឆោត នៅចុងដៃអាវនីមួយៗ ម្ខាងបី) ។

–ខោជើងវែងចង្កេះត គ្មានក្ជី នៅខាងក្រោយមានហោប៉ៅមួយដេរបង្កប់ គ្មានគំរប ហោមៅពីរនៅចំហៀងដេរបង្កប់តាមបណ្តោយថ្នេរខោទាំងសងខាង ពីចង្កេះដល់ជើងខោមានឆ្នូតក្រហមពីរ ឆ្នូតនីមួយៗ មានទទឹង ២ ស.ម ឃ្លាតគ្នា ៥ ម.ម ។

–មួកកាស្កេត ពណ៌ក្រមៅ ក្រណាត់កាំម្ចី ជើងមួកពណ៌ក្រហម ហាមមួកធ្វើអំពីកៅស៊ូរឹង ពណ៌ខ្មៅ នៅខាងលើហាមមួកប៉ាក់ក្បាច់ភ្ញីទេសឌិន ដល់ជើងមួក វិន្ទខាងមុខ និងឡេវ (រូបព្រះសង្ហារ) ពណ៌មាស ។

–ស្បែកជើង ឃុប ពណ៌ខ្មៅ ធ្វើអំពីស្បែក ក ខ្ចី ។

–ស្រោមជើង ពណ៌ខ្មៅ ស្រោមដៃពណ៌ស ។

–ខ្សែរំយោល ពណ៌មាស វេញចូលគ្នា រាងសំប៉ែត ខ្សែអមបី មានម្ភុលបុរទ្ភោក ពីរ ពណ៌មាស មានក្បាច់ភ្ញីផ្កា ។

–ខ្សែក្រវាត់ ពណ៌ត្រែអ៊ី ក្បាលខ្សែក្រវាត់ ធ្វើអំពីលោហធាតុលាត ហើយពណ៌ មាស (ប្រើគ្រប់ឯកសណ្ឋានទាំងអស់) ។

–ចំពោះនារី អាវមានតំរូវដូចបុរស តែកាត់រាងតាមផងខ្លួននារី សំពត់ស៊ីប ក្រោមជង្គង់ពណ៌ខ្មៅ មានឆ្នូតក្រហមសង្ខាងដូចគ្នា ។

២– ឯកសណ្ឋានធំលេខ ២ : (អាចទ័រី)

ឯកសណ្ឋានធំលេខ២នេះ ពណ៌កាគី អាវសឹមីក្នុងមានពីរ មួយពណ៌កាគី មួយទៀតពណ៌ស ក្រវាត់ ក ពណ៌ខ្មៅ ។

– អាវកាត់រាវអាវរ៉ាំ មានផែកខ្នងមួយ ក បើក ប៉ូលស្មាទាំងសង្ខាង មានហោប៉ៅបួន (ហោប៉ៅពីរ ខាងលើដេរប៉ះ ចំកណ្ដាលមានចាប់ផ្នត់មួយ គំរបរាងស្លឹកពោធិ ហោប៉ៅពីរខាងក្រោមដេរបង្កប់ មានគំរបរាងចតុកោណកែង) ដៃអាវវែង កាត់រាងដៃបំពង់ ។ ឡេវអាវ មានរូបព្រះសង្ហារ ឡេវធំបួន ឡេវហោប៉ៅបួន ឡេវតូច ប៉ូលស្មាពីរ និងឡេវបញ្ចោតនៅចុងដៃអាវម្ខាង ៣ ។

– ខោជើងវែង ពណ៌កាគី ថ្នេរបង្កប់ ចង្កេះត គ្មានភ្លី មានហោប៉ៅបួន (ហោប៉ៅពីរខាងក្រោយ ដេរបង្កប់ មានគំរបរាងស្លឹកពោធិ នៅចំហៀងពីរ ដេរបង្កប់តាមថ្នេរខោ) ។

– មួកកាស្កេត ពណ៌កាគី ជើងមួកពណ៌ខ្មៅ ហាមមួកធ្វើអំពីជ័រវែង ពណ៌ខ្មៅ រឹត្ត និង ឡេវ មួក (រូបព្រះសង្ហារ) ពណ៌មាស លើហាមមួក មានប៉ាក់ក្បាច់ភ្ញីទេសឱន ដល់ជើងមួកទាំងសង្ខាង ។

– អាវសឹមី ខាងក្នុងពីរ មួយពណ៌ស មួយទៀតពណ៌ កាគី កាត់ស្រុងវែង ដាក់ក្នុងខោ មានហោប៉ៅមួយនៅខាងឆ្វេង គ្មានគំរប ដៃអាវកាត់ផែក ដាក់ឡេវបិទ ។

– ក្រវាត់ ក ពណ៌ខ្មៅ ស្រោមដៃ ពណ៌ ស ។

– ស្បែកជើងឃ្មុប ពណ៌ខ្មៅ ធ្វើពីស្បែក ក ខ្ចី ។

– ខ្សែក្រវាត់ ពណ៌ត្រែអ៊ី ក្បាលខ្សែក្រវាត់ លោហធាតុលាត ពណ៌មាស ។

- ចំពោះនារី អាវដូចខាងលើ តែជីបចង្កេះ និង ក អាវតាមរាងដងខ្លួននារី សំពត់ហ៊ីបក្រោម ជង្គង់ ។

- ឯកសណ្ឋាននេះ អាវ ពណ៌កាគី ខោ ពណ៌ត្រែអ៊ី ហោប៉ៅបួន ។

៣– ឯកសណ្ឋានលេខ ៣ : (សាហារីយ៉េន)

- អាវ ដៃខ្លី ក បើក ខាងក្រោយមានផែក និង មានប៉ានចង្កេះ ផ្នែកខាងមុខ ហោប៉ៅបួន (ពីរខាងលើដេរប៉ះ មានគំរប និងពីរខាងក្រោមដេរយោគមកក្រៅមានគំរបដូចគ្នា) ប៉ូលស្មា ទាំងសង្ខាង ឡេវរូបព្រះសង្ការ ពណ៌មាស ។
- ខោជើងវែង ពណ៌ត្រែអ៊ី (កាត់ម៉ូតដូចឯកសណ្ឋានលេខ ២) ។
- មួក–ស្បែកជើង និងស្រោមជើង (ដូចឯកសណ្ឋានលេខ ២) ។
- ចំពោះនារី អាវដូចបុរស តែជីបចង្កេះតាមរាងនារី ហើយសំពត់ហ៊ីបពណ៌ត្រែអ៊ីក្រោមជង្គង់ ។

៤– ឯកសណ្ឋានការងារ (លេខ ៤) : គំរូឯកសណ្ឋាននេះមានតែមួយ សំរាប់គឺ :

- ឯកសណ្ឋាន ការងារ អាវ ពណ៌កាគី ដៃខ្លី ហើយខោពណ៌ត្រែអ៊ី ។
- អាវដៃខ្លី ពណ៌កាគី ក ឧប ប៉ូលស្មាទាំងសង្ខាង កាត់ស្រុងវែងដាក់ក្នុងខោ ហោប៉ៅពីរដេរប៉ះ ចំកណ្ដាល ដេរបត់ផ្នត់មួយ មានគំរបរាងស្នឹកពោធិ ឡេវធម្មតា ពណ៌កាគី ។
- ខោ ជើងវែង (ដូចឯកសណ្ឋានលេខ ៣) ពណ៌ត្រែអ៊ី ។
- មួក បេរេ ពណ៌ត្រែអ៊ី នៅស្រទាប់មួក មានចំពណ៌មាស តាមបណ្ដោយ ទំហំ ៨ ម.ម ។
- ខ្សែក្រវ៉ាត់ ពណ៌ត្រែអ៊ី (ដូចខ្សែក្រវ៉ាត់ឯកសណ្ឋានលេខ១)
- ចំពោះនារី អាវដូចបុរស ខោជើងវែង កាត់ដូចបុរស តែខុសចំពោះនារី ផែកឡេវចំហៀងឬ សំពត់ហ៊ីប ពណ៌ត្រែអ៊ី ក្រោមជង្គង់ ។

៥— ឯកសណ្ឋានប្រយុទ្ធ :

–គំរូឯកសណ្ឋានប្រយុទ្ធមានតែមួយសំរាប់ អាវដៃវែង ហោប៉ៅបួន ខោជើងវែង ហោប៉ៅ៦ ជើងខោចងខ្សែ ឬដាក់ខ្សែយឺត រឹតជើង ពណ៌ត្រែអ៊ីជើងគោក (ទ័ពពិសេស ស៊ើបការ ទ័ពការពារព្រំដែន និងឆ័ត្រយោង ពណ៌កាំម៉ូតផ្កា) ដោយឡែក ថ្នាក់ឧត្តមសេនីយ៍ ជាអត្ថិភាព អាចពាក់បានទាំងអស់ ។

–អាវដៃវែង កបើក ថ្នេរខុប ហោប៉ៅបួន ដេរយោតមកក្រៅទាំងអស់ មានគំរបរាងចតុកោណកែង ឡេវទាំងអស់ ដាក់បង្កប់ ពណ៌ត្រែអ៊ី ដៃអាវវែង កាត់ដៃបំពង់ នៅចុងដៃអាវមានក្រវ៉ាត់ និង ឡេវ លើស្មាមានប៉ូលពីរសង្ខាង ។

–ខោជើងវែងថ្នេរខុប ហោប៉ៅក្រោយពីរ ដេរបង្កប់ មានគំរបរាង ចតុកោណកែង នៅចំហៀង តាមថ្នេរខោដេរបង្កប់ មាត់ហោប៉ៅបញ្ឆិត ប៉ានជង្គង់ នៅសង្ខាងភ្លៅមានហោប៉ៅធំពីរ នៅជើងម្ខាងមួយ ផ្នែកខាងក្រៅ ហោប៉ៅដេរយោតមកក្រៅ នៅកណ្តាលហោប៉ៅ មានបត់ផ្នត់ពីរជាន់ គំរបរាងចតុកោណកែង ដាក់ឡេវពីរ ជើងខោចងខ្សែ ឬ ខ្សែយឺត ។

–មួកដែក និងមួក ហ៊្សកកី ពណ៌ត្រែអ៊ី (ទ័ពពិសេស ស៊ើបការ ទ័ពការពារព្រំដែន និងឆ័ត្រយោង ពណ៌កាំម៉ូផ្កា) ហើយមួកហ៊្សកកី នៅលើហាមមួករបស់ឧត្តមសេនីយ៍ មានប៉ាក់ភ្ញីទេសឱន ដូចមួក កាស្កេតដែរ ។

–ស្បែកជើងស្បែក ក វែង ពណ៌ខ្មៅ ។

–ស្រោមជើងវែង ពណ៌ត្រែអ៊ី ។

–កន្សែងរុំ (ហ្វូឡា) ពណ៌ត្រែអ៊ី ក្រណាត់នីឡុង ។

–ប៉េរ៉េ ពណ៌ត្រែអ៊ី ជើងគោក–ទ័ពពិសេស–ឆ័ត្រយោង ពណ៌ក្រហម ។

១— ឯកសណ្ឋានថ្នាក់ឧត្ដមសេនីយ៍ :

ខ— ឯកសណ្ឋានលេខ ១ : ដូចថ្នាក់ឧត្តមសេនីយ៍ដែរ តែមានចំណុចមួយចំនួនខុសគ្នា ដូចខាងក្រោម ÷

មួក : នៅហាមមួកក្បាច់ភ្ញីទេសឱន នៅចុងហាមមួក ទុកចន្លោះពីជើងមួកសង្ខាងប្រវែង ៤ស.ម។

ខ្សែរំយោល : វេញចូលគ្នាបីខ្សែដែរ តែទំហំតូចជាងថ្នាក់ឧត្តមសេនីយ៍ ។

-ខោជើងវែងពណ៌ក្រមៅ ថ្នាក់វរសេនីយ៍ មានឆ្នូតពីរ ឆ្នូតនីមួយៗគិតទូសទទឹង ១ ស.ម ។

២- **ឯកសណ្ឋានលេខ ២+៣** : រូបភាព-មួក-ពណ៌ដូចថ្នាក់ឧត្តមសេនីយ៍ តែខុសគ្នា នៅហាមមួកក្បាច់ភ្ញីទេសឌិន ទុកចន្លោះ ពីជើងមួកសង្ខាង ៤ ស.ម ។

៣- **ឯកសណ្ឋានលេខ ៤** : (អាវការងារ) ដូចគ្នាឧត្តមសេនីយ៍ តែខុសគ្នា មួក បេរ៉េ នៅស្រ ទាប់មួក ថ្មេរមានចំពណ៌ក្រហម ទំហំ ៥ ម.ម ។

ឯកណ្ឋានប្រយុទ្ធ : ដូចឧត្តមសេនីយ៍ តែខុសគ្នា មួកហ៊្សកកី ក្បាច់ភ្ញីទេសឌិន នៅហាមមួក ទុកចន្លោះ ៤ ស.ម ពីជើងមួក ។

គ- ថ្នាក់អនុសេនីយ៍ :

១- **ឯកសណ្ឋានលេខ ១** ដូចគ្នាថ្នាក់ឧត្តមសេនីយ៍ដែរ តែមានចំណុចខុសគ្នា សំរាប់សំគាល់ថ្នាក់ដូច ខាងក្រោម ÷

-មួកកាស្កេត នៅហាមគ្មានក្បាច់ភ្ញីទេសឌិនទេ តែមានចំជាឆ្នូតពណ៌មាស នៅចុងហាម ប្រវែងទទឹងឆ្នូតចំនួន ៦ម.ម និងប៉ាតលើ ក អាវដូចធ្មេញរណា និងប៉ាននៅដៃអាវពណ៌ប្រាក់ ។

-ខោជើងវែង ពណ៌ក្រមៅ ឆ្នូតមានតែមួយ ប្រវែងទទឹងឆ្នូត ២ ស.ម ។

២- **ឯកសណ្ឋានលេខ២+៣** : ដូចគ្នាថ្នាក់ឧត្តមសេនីយ៍ដែរ តែខុសគ្នា មួកកាស្កេត លើហាមមួកគ្មានក្បាច់ភ្ញីទេសឌិនទេ មានចំឆ្នូតពណ៌មាស នៅហាមដូចមួកកាស្កេត ឯកសណ្ឋានធំលេខ១ដែរ។

៣- **ឯកសណ្ឋានការងារ** : ដូចគ្នាថ្នាក់ឧត្តមសេនីយ៍ដែរ តែមួកបេរ៉េ ចំពណ៌ ទឹកប្រាក់ ។

៤- **ឯកសណ្ឋានប្រយុទ្ធ** : ដូចគ្នាថ្នាក់ឧត្តមសេនីយ៍ដែរតែមួយមួកហ៊្សកកី នៅហាមមួកមានចំ ឆ្នូតដូចមួកកាស្កេតដែរ ។

ឃ — ថ្នាក់នាយទាហានរង និងពលទាហាន :

ក្នុងលក្ខណៈ ដែលក្រសួងការពារជាតិ និងអគ្គសេនាធិការពិនិត្យឃើញថា : ត្រូវបំពេញបេសក កម្មនៅក្រៅប្រទេស ឬក្នុងពិធីការជាតិធំៗ នាយទាហានរង និងពលទាហាន អាចមានឯកសណ្ឋានធំលេខ២ ឬលេខ៣ដែរ ។ ចំពោះឯកសណ្ឋានទាំងនោះ ដូចគ្នាថ្នាក់ អនុសេនីយ៍ដែរ តែមួកកាស្កេត គ្មានក្បាច់ភ្ញីទេសនិន ឬឆ្នូតអ្វីទាំងអស់ ។

ចំពោះនាយទាហានរង និងពលទាហាន មានគោលរបប តែឯកសណ្ឋានការងារ និងឯកសណ្ឋានប្រយុទ្ធតែប៉ុណ្ណោះ ។ ចំពោះឯកសណ្ឋានការងារ និងប្រយុទ្ធ ដូចគ្នាថ្នាក់អនុសេនីយ៍ដែរ តែមួកបេរេ និងមួកហ៊្សកកី គ្មានឆ្នូតអ្វីទាំងអស់ ។

មាត្រា២ : ត្រូវរៀបចំឯកសណ្ឋាន កងនាវាចរភូមិន្ទ និងអាកាសចរភូមិន្ទ ដូចខាងក្រោមនេះ ÷

ក — ឯកសណ្ឋានកងនាវាចរភូមិន្ទកម្ពុជា :

ឯកសណ្ឋានកងនាវាចរភូមិន្ទកម្ពុជា គ្រប់ឯកសណ្ឋាន និងគ្រប់ថ្នាក់ នាយទាហាន នាយទាហានរង និងពលទាហាន ដូចទ័ពជើងគោក តែខុសគ្នាពណ៌តែប៉ុណ្ណោះ ។ ពណ៌ឯកសណ្ឋាន កងនាវាចរភូមិន្ទ ត្រូវបានកំណត់ដូចខាងក្រោម ÷

–ឯកសណ្ឋានលេខ ១-២-៣-៤ (អាវកុងស អាវវ៉ារី សាហារីយ៉ែន និងការងារ) មួកគ្រប់ប្រភេទ ស្បែកជើង និងស្រោមជើង ពណ៌សទាំងអស់ ។ ចំពោះអាវសឺមីក្នុង របស់ឯកសណ្ឋានលេខ ២ មានតែមួយ ពណ៌ស តែប៉ុណ្ណោះ ។ ដោយឡែក ឯកសណ្ឋានការងារមាន ២សំរាប់ (១សំរាប់ពណ៌ស) ខ្សែក្រវ៉ាត់ ពណ៌ស ក្បាលខ្សែក្រវ៉ាត់លាត ពណ៌មាស ។ ចំពោះនាយទាហានរង និងពលទាហាន អាវការងារ ពណ៌ស ក អាវទំលាក់មកក្រោមរាងជាកន្សែងវែង ប្រវែង ២៥ស.ម ជុំវិញ ក អាវនេះមានឆ្នូតបីពណ៌ខៀវ ឆ្នូតនីមួយៗមានទំហំ ៨ម.ម ។ ហើយពាក់មួក ម៉ាតឺឡូ ពណ៌ស ជើងមួក ពណ៌ខៀវ លើជើងមួកសរសេរអក្សរពណ៌សថា

(កងនាវាចរភូមិន្ទ កម្ពុជា) កំពស់អក្សរ ១៥ ម.ម។ ជើងម្កុកខាងក្រោយពែក មានខ្សែពីរសំរាប់ ចងកន្ទុយខ្សែមានរាងកន្ទុយត្រី ។

–ឯកសណ្ឋានប្រយុទ្ធដូចទ័ពជើងគោក តែប៉េរ៉េ ពណ៌ខៀវ ទឹកសមុទ្រហើយ កន្សែងរុំក (ហ៊្វូឡា) ពណ៌ខៀវទឹកសមុទ្រ (ខៀវទឹកប៊ិច) ។

ខ– ឯកសណ្ឋានអាកាសចរភូមិន្ទកម្ពុជា :

–គ្រប់ប្រភេទនៃឯកសណ្ឋាន និងគ្រប់បណ្ដាថ្នាក់នាយទាហាន នាយទាហានរង និងពលទាហាន មានឯកសណ្ឋានដូចគ្នាជើងគោក តែឯកសណ្ឋានអាកាសចរ ភូមិន្ទកម្ពុជា ត្រូវបានកំណត់ពណ៌ដូចខាង ក្រោម ÷

–ឯកសណ្ឋានលេខ ១ : អាវកុងស ពណ៌ស ខោពណ៌ខៀវក្រម៉ៅ និងម្កុកកាស្កេត ពណ៌ខៀវក្រម៉ៅ ជើងម្កុកពណ៌ក្រហម ។

–ឯកសណ្ឋានលេខ២–៣–៤ : ពណ៌ខៀវក្រម៉ៅ ស្បែកជើងពណ៌ខ្មៅ ដូចទ័ពជើងគោក ដោយឡែកអាវ សឺមីក្នុងរបស់ឯកសណ្ឋានធំលេខ ២ កាត់ដូចជើងគោកតែមួយ ពណ៌ផ្ទៃមេឃ មួយទៀតពណ៌ស ។ ហើយ ឯកសណ្ឋានការងារ មានមួយសំរាប់ អាវពណ៌ខៀវផ្ទៃមេឃ ខោពណ៌ខៀវ ក្រម៉ៅ ម្កុកបេរ៉េពណ៌ខៀវក្រម៉ៅ កាត់ដូចទ័ពជើងគោក និងខ្សែក្រវ៉ាត់តូច ពណ៌ខៀវទឹកប៊ិច ក្បាលលាត ពណ៌មាស ។

–ឯកសណ្ឋានប្រយុទ្ធ : ដូចទ័ពជើងគោក តែប៉េរ៉េ និងកន្សែងរុំក ពណ៌ខៀវ (ខៀវផ្ទៃមេឃ) ។

មាត្រា ៣ : ត្រូវបានរៀបចំ ឯកសណ្ឋានត្រៃទ័ព និងកងកិត្តិយសដូចខាងក្រោម ÷

ក– ឯកសណ្ឋានត្រៃទ័ព : ឯកសណ្ឋានត្រៃទ័ពមានពីរសំរាប់ មួយពណ៌ស មួយទៀតពណ៌កាគី ម៉ូតរូបភាពឯកសណ្ឋាន និង ម្កុកកាស្កេត ដូចឯកសណ្ឋានលេខ ២ តែម្កុកកាស្កេត ធ្វើតាមឋានៈដូចទ័ពជើងគោក ស្បែកជើងស្បែកកវែង ពណ៌ខ្មៅ ខ្សែក្រវ៉ាត់ធំពណ៌ខ្មៅ ក្រវ៉ាត់ពី លើអាវ អាវសឺមីក្នុង ពណ៌កាគីមួយ ពណ៌សមួយ ខ្សែរំយោល ពណ៌មាស និងកន្សែងរុំក ពណ៌លឿង ស្រោមដៃពណ៌ស ។

ខ– ឯកសណ្ឋានកងកិត្តិយស :

១– ឯកសណ្ឋាន មេបញ្ជាការ កងកិត្តិយស និងអ្នកកាន់ទង់ : ត្រូវពាក់ឯកសណ្ឋានលេខ២ របស់ទ័ពជើងគោក តាមឋានន្តរសក្តិជាក់ស្តែង ។ ចំពោះមេបញ្ជាការកងកិត្តិយស តាមបណ្តាផែនជើងគោក–នាវាចរ–អាកាសចរ ត្រូវបានពាក់ឯកសណ្ឋានធំលេខ២ តាមឋានន្តរសក្តិជាក់ស្តែង និង តាមប្រភេទទ័ព ។

២– ឯកសណ្ឋានកងកិត្តិយសជើងគោក : ឯកសណ្ឋានមានមួយសំរាប់ ពណ៌កាគី ដូចគ្រប់ទ័ព តែខុសគ្នាកងកិត្តិយសជើងគោក ពាក់មួកស្ទីកាស ពណ៌ខ្មៅ ក្សែងរ៉ុក ពណ៌លឿង ។

៣– ឯកសណ្ឋានកងកិត្តិយសនាវាចរ : ឯកសណ្ឋានពណ៌ស មួកស្ទីកាស ពណ៌ស និងក្សែងរ៉ុកពណ៌ស(កាត់ម៉ូតឯកសណ្ឋានលេខ២ កងនាវាចរភូមិន្ទកម្ពុជា)។

៤– ឯកសណ្ឋានកងកិត្តិយសអាកាសចរ : ឯកសណ្ឋានពណ៌ខៀវក្រមៅ មួកស្ទី កាសពណ៌ខៀវ ក្សែងរ៉ុក ពណ៌ផ្ទៃមេឃ កាត់ដូចឯកសណ្ឋានលេខ ២ កងអាកាសចរភូមិន្ទកម្ពុជា ។

៥– ឯកសណ្ឋានកងកិត្តិយសជាន : ពាក់ឯកសណ្ឋានលេខ ១ ថ្នាក់អនុសេនីយ៍ ប្រើដាវមានស្រោម ពណ៌ស ខ្សែរំយោលដាវពណ៌មាស ផងដាវឆ្លាក់រូបព្រហ្ម មុខបួន ផ្ទៃដាវពណ៌ទឹកប្រាក់ ចង្កឹនិងផង ដាវក្បាច់ពណ៌មាស ។

មាត្រា ៤ : ត្រូវបានរៀបចំឯកសណ្ឋានសំរាប់បំរើការរបស់ទ័ពបច្ចេកទេសជំនាញ ដូចខាងក្រោម ÷

ក– ឯកសណ្ឋានបច្ចេកទេសទ័ពរថក្រោះ រថពាសដែក :

ឯកសណ្ឋានពណ៌ខ្មៅ អាវដៃវែង ខោជើងវែង ថ្ងៃខ្នុប ខ្សែរបង្កប់ កាត់ម៉ូតឯកសណ្ឋានប្រយុទ្ធទ័ព ជើងគោក ប៉េរ៉េ ពណ៌ខ្មៅ ស្បែកជើងស្បែកកវែង និងស្រោមជើង ពណ៌ខ្មៅ ។

២– ឯកសណ្ឋានបច្ចេកទេស គ្រឿងយន្តវិស្វកម្ម និង អ្នកបំរើការងារខាង ជួសជុលឬសិប្បកម្ម យោធា :

–ឯកសណ្ឋានពណ៌ខៀវ អាវដៃវែង ខោជើងវែង ចង្កេះត ជីបភ្លី ហោប៉ៅក្រោយពីរ ដេរបង្កប់ គំរបរាងស្លឹកពោធិ និងហោប៉ៅចំហៀងពីរ ដេរបង្កប់តាមថ្នេរខោ ឡេវបង្កប់ ថ្នេរឌុប ពាក់មួកហ៊្សកកីពណ៌ខៀវ ។

៣– ឯកសណ្ឋានបច្ចេកទេសពេទ្យយោធា :

–ឯកសណ្ឋាន ពណ៌ស អាវដៃខ្លី កបើក ហោប៉ៅបី (មួយនៅលើឆ្វេងគ្មានគំរប និងពីរនៅខាងក្រោម ធំគ្មានគំរប) កាត់ស្រុងវែងដល់ជង្គង់ ខោជើងវែង ពណ៌ស ចង្កេះរឹត មានហោប៉ៅក្រោយ មួយគ្មានគំរប ។

៤– ឯកសណ្ឋានកងជីវពល :

–ឯកសណ្ឋានកងជីវពលគ្រប់ប្រភេទ មាន១សំរាប់ អាវដៃវែង ពណ៌ខៀវទឹកប៊ិច កបើក ហោប៉ៅលើពីរដេរប៉ះ មានគំរបដូចស្លឹកពោធិ ដៃអាវវែង ឡេវបង្កប់ ប៉ូលស្មាសម្លាងកាត់ស្រុងវែង ដាក់ក្នុងខោ ។ ខោជើងវែង មានប៉ានជង្គង់ ពណ៌ត្រែអ៊ី (កាត់ម៉ូត ខោការងារទំពជើងគោក) មួកហាម ធំពណ៌ទឹកប៊ិច ស្បែកជើង សំពត់ និងស្រោមជើងពណ៌ត្រែអ៊ី និងខ្សែក្រវាត់ ដូចទំពជើងគោក ។

៥– ឯកសណ្ឋានបច្ចេកទេសនាវាចរខេមរភូមិន្ទកម្ពុជា :

–ឯសណ្ឋានបច្ចេកទេស កងនាវាចរខេមរភូមិន្ទ សំរាប់ក្រុម នាវិកនៅលើកប៉ាល់ម៉ារីន និងរោងជួសជុល ពេលធ្វើការងារបច្ចេកទេស ដូចជាថែទាំបច្ចេកទេស និងជួសជុលមិនបានពាក់ចេញ ក្រៅកងឯកភាពឡើយ ។

រូបរាង និង ម៉ូត : ឯកសណ្ឋានក្រណាត់កាគី ពណ៌ទឹកប៊ិច អាវដៃវែង ខោជើងខ្លី និង វែង ។

–អាវកបើក ថ្នេរឌុប អាវដៃបំពុង មានក្រវាត់ឡេវ ហោប៉ៅពីរ ដេរយោ គំរបរាងចតុកោណ កែង ឡេវបង្កប់ ក្រាត់ចង្កេះ ទំហំ ៦ ស.ម ។

–ខោជើងខ្លីលើជង្គង់ ចង្កេះត ជីបភ្ជិ ហោប៉ៅក្រោយពីរ ដេរបង្កប់ តំបរាង ស្លឹកពោធិ ហោប៉ៅ ចំហៀងពីរ បង្កប់តាមថ្នេរខោ ។

–ខោជើងវែង ពាក់ដូចខោជើងខ្លី តែខុសត្រង់មួយជើងវែង មួយជើងខ្លី ។

–ខ្សែក្រវាត់ពណ៌ទឹកប៊ិច ក្បាលខ្សែក្រវាត់ ពណ៌មាសលាត ។

–មួកហ៊្វូកកី ពណ៌ខៀវ ស្បែកជើង ប៉ាតង់កៅស៊ូ កវែង ពណ៌ខ្មៅ ស្រោម ជើងខ្មៅ ស្រោមដៃ ពណ៌ខ្មៅ ។

គ– ឯកសណ្ឋានបច្ចេកទេស អាកាសចរភូមិន្ទកម្ពុជា :

–ឯកសណ្ឋានបច្ចេកទេស កងអាកាសចរភូមិន្ទ សំរាប់ក្រុមបច្ចេកទេសយន្ត ហោះ និង អ្នកឯកទេស ជួសជុលយន្តហោះគ្រប់ប្រភេទ ពេលធ្វើការងារ បច្ចេកទេស ដូចជាថែទាំ ធានាបច្ចេកទេស និងជួសជុលមិនបានពាក់ពេញ ក្រៅអង្គភាពឡើយ ។

–**រូបភាព និង ម៉ូត :** ឯកសណ្ឋានទាំងអស់ដូចឯកសណ្ឋានបច្ចេកទេស កងនាវាខេមរភូមិន្ទ តែគ្មាន ខោ ជើងខ្លីទេ ។

–ចំពោះឯកសណ្ឋានអ្នកបើកយន្តហោះគ្រប់ប្រភេទ ត្រូវរៀបចំតាមប្រភេទយន្ត ហោះ និងតាមលក្ខណៈបច្ចេកទេសជាក់ស្តែង ។

មាត្រា៥ : ត្រូវរៀបចំផ្លាកសញ្ញា សំរាប់ជាទូទៅក្នុងកងយោធពលខេមរភូមិន្ទដូចខាងក្រោម ÷

ក– រូបព្រះសង្ហារ :

–រូបព្រះសង្ហារយកតាមសម័យសង្គមរាស្ត្រនិយម ធ្វើពីលោហធាតុ ពណ៌មាស នៅលើខ្នែព្រះសង្ហារមានសរសេរអក្សរ **ព្រះរាជាណាចក្រកម្ពុជា** ។ សំរាប់ពាក់លើ មួកកាស្កេត និង មួកស៊ូកាស ទំហំ កំពស់ ៧.៨ ស.ម ទទឹង ៦.៥ ស.ម ។ សំរាប់លើមួកហ៊្វូកកី បោននេ មួកហាមធំ និងប៉េរ៉េ ទំហំ កំពស់ ៥ស.ម និងទទឹង ៤ស.ម ។

ខ– ផ្លាកសញ្ញាកងយោធពលខេមរភូមិន្ទ :

១– ផ្លាកសញ្ញាពាក់នៅលើដៃអាវស្តាំ ចុះពីថ្នេរស្មា ៥ស.ម មានរាងមូល បន្ទាត់ ផ្ចិត ៨ស.ម ស្រទាប់ខាងក្រៅ ពណ៌ស ទទឹងស្រទាប់នេះ ៣ម.ម ផ្ទៃខាងលើ

១/៤ នៃវង្វង់ពណ៌ខៀវ ហើយសរសេរអក្សរ ពណ៌ស ផ្នែកខាងលើកោងតាមរង្វង់ថា (**ព្រះរាជាណាចក្រកម្ពុជា**) កំពស់អក្សរ ៥ស.ម ផ្នែកកណ្តាល ១/២ នៃរង្វង់ពណ៌ក្រហម ហើយមានប្រាសាទអង្គរវត្ត កំពូលបី ពណ៌ស កំពស់ប្រាសាទ ២.៥ ស.ម ផ្នែខាងក្រោម ១/៤ នៃរង្វង់ពណ៌ខៀវ សរសេរអក្សរកាត់ពណ៌ខៀវថា (ខ.ត.ម) កំពស់អក្សរ ៧ ស.ម។ ចំពោះការផលិតធ្វើពីក្រណាត់ អាចបោះពុម្ព ឬ ចាក់ ។

២– ផ្លាកសញ្ញារូបហនុមាន ធ្វើរាងជាមេដៃ ពាក់រាងជាមេដៃ ពាក់បន្តោងនៅខ្សែរហោប៉ៅអាវស្តាំ ។ ផ្លាកសញ្ញាធ្វើអំពីលោហធាតុ ផ្នែកខាងលើមានមកុដពណ៌មាស សង្វាងមានរំយោលម្ខាង ៣ ពណ៌មាស (តំណាងអោយទង់ជាតិ) ផ្នែកកណ្តាល ពណ៌ខៀវទឹកប៊ិច លើផ្ទៃកណ្តាល មានរូបហនុមានកាន់ព្រះខ័ន្ធកំពុងសំដែងរិទ្ធពណ៌ស្វាទុំ នៅផ្នែកខាងក្រោមមានជើងពានរាង ដូចស្នែងក្របីផ្ទៃពណ៌ក្រហម រឹមជុំវិញពណ៌មាស នៅលើផ្ទៃនោះ សរសេរអក្សរកាត់ថា (ខ.ក.ម) ពណ៌ស ។

ខ្នាត : កំពស់រូបភាព ៦០ម.ម ទទឹង ៤៥ ស.ម ។

កំពស់មកុដ ២៧ម.ម បាតក្រោមមកុដ ៣៤ ម.ម ។

–ផ្ទៃពណ៌ខៀវកណ្តាលកំពស់ ៣២ ម.ម ទទឹង៣០ ម.ម ហនុមានកំពស់ ២៤ម.ម ទទឹង ២៤ម.ម។

–រំយោលសង្វាង ប្រវែងទី ១ = ១៦ម.ម ទី២= ១៤ម.ម ទី៣ = ១២ ម.ម ។

–ជើងពានផ្នែកខាងក្រោមមានរាងដូចស្នែងក្របី បណ្តោយប្រវែង ៣៤ម.ម ទទឹង ៦ម.ម អក្សរកំពស់ ៤ម.ម ។

–សញ្ញាដាក់លើស្បែក សំរាប់ពាក់ពីខ្សែរ ហោប៉ៅស្តាំ ប្រវែងស្បែកពីលើមកក្រោម ១០ ស.ម ។

គ– **ផ្លាកឈ្មោះរបស់នាយទាហាន នាយទាហានរង និង ពលទាហាន នៃកងយោធពលខេមរភូមិន្ទ :**

១– ផ្លាកឈ្មោះធ្វើពីជ័រផ្លាស្ទិច ផ្ទៃពណ៌ខ្មៅ គួសបន្ទាត់ជុំវិញពណ៌មាស បណ្តោយផ្លាក ១០ ស.ម ទទឹង ២ស.ម កំពស់អក្សរ ៧ម.ម ពណ៌មាស សរសេរជាអក្សរខ្មែរ ។ ហើយអាចធ្វើផ្លាកឈ្មោះដែលមានផ្ទៃ និងទំហំដូចគ្នាជាអក្សរឡាតាំង មួយទៀតមិនបានសរសេរ ក្នុងផ្លាកតែមួយអក្សរខ្មែរផង និងអក្សរឡាតាំងផងឡើយ ឬ ដាក់ផ្លាកសញ្ញាផ្សេងៗទៀតលើ ផ្លាកឈ្មោះទេ ។ នៅខាងដើម នាមត្រកូលនិងនាមខ្លួន ត្រូវសរសេរកាត់ពី ឋានន្តរសក្តិរបស់យោធិនម្នាក់ៗ គឺយកតែអក្សរទី១ នៃឈ្មោះសក្តិ ចំពោះអក្សរឡាតាំងភាសាអង់គ្លេស ឬបារាំង ត្រូវយកតាមការសរសេរកាត់ ដែលគេបានកំណត់ជាទូទៅ នៃអន្តរជាតិ ។ ចំពោះឯកសណ្ឋានប្រយុទ្ធ ដាក់ផ្លាកឈ្មោះធ្វើពីក្រណាត់ ពណ៌គ្រែអ៊ី ស្មើហោប៉ៅ ទទឹង២ស.ម សរសេរអក្សរពណ៌ខ្មៅដេរភ្ជាប់អាវលើហោប៉ៅស្តាំ កំពស់អក្សរ និងកន្លែងពាក់ដូចផ្លាកខាងលើ។

មាត្រា ៦ : ត្រូវបានរៀបចំផ្លាកសញ្ញាបណ្តាថ្នាក់ និងបណ្តាទ័ពជំនាញនៃប្រភេទទ័ពដូចខាងក្រោមនេះ ÷

១– ផ្លាកសញ្ញាសំរាប់ថ្នាក់ដឹកនាំ អគ្គមេបញ្ជាការ ថ្នាក់ដឹកនាំក្រសួង និងអគ្គសេនាធិការដែលមាន សិទ្ធិបញ្ជាកងយោធពលខេមរភូមិន្ទ ទាំងបីប្រភេទទ័ព ។

រូបភាព : នៅផ្នែកខាងលើមានមកុដ តំណាងអោយប្រជាជាតិខ្មែរ និងផ្នែកខាងក្រោម មានលំពែង ស្ទាបសត្វ និងយុត្ថា តំណាងអោយបីប្រភេទទ័ពសញ្ញា មានរាងដូចស្លែងក្របី ផលិតពីលោហធាតុ ពណ៌មាសអាចប៉ាក់ជាក្រណាត់ពណ៌ខ្មៅ រូបពណ៌មាស តែនៅលើឯកសណ្ឋានប្រយុទ្ធមួយប៉ុណ្ណោះ។

ខ្នាត : កំពស់រូបភាព ៤ស.ម ទទឹង ៣ស.ម ។

–កំពស់មកុដ ១.៨ស.ម បាតក្រោមមកុដ ១.៣ស.ម ។

–កំពស់យុត្ថា ១.៦ស.ម ចុងផ្ទៃយុត្ថា ពីម្ខាងទៅម្ខាង ២ ស.ម ។

–កំពស់លំពែង ដោយគិតពីដងយុត្ថា ០.៦ស.ម ។

–ស្លាបសត្វរាងដូចស្លែងក្របី ម្ខាងៗមានស្លាបបីជាន់ (ជាន់ទី១ = ១១ ស្លាប ទី២ = ៩ស្លាប ទី៣ = ៧ ស្លាប) កំពស់ ២៤ ម.ម ពីចុងម្ខាង ទៅម្ខាងទៀត ៣៥ម.ម ។

–សំរាប់ពាក់នៅលើ កអាវ នៃឯកសណ្ឋានយោធា (ចំពោះការណែនាំពាក់នៅមាត្រាខាងក្រោយ) ។

២– សំរាប់ថ្នាក់ឧត្តមសេនីយ៍ :

រូបភាព : នៅចំកណ្តាលមានរូបយុត្តាបញ្ឈរ និងមានឈើពែងមានផ្លែបីបញ្ឈរទៅលើ ខាងក្រោមយុត្តា នៅសង្ខាងមានស្លាបសត្វ មានរាងដូចស្លែងក្របី ។ ផលិតពីលោហធាតុ ពណ៌មាស កំរាស់១.៥០ ម.ម ពាក់នៅលើអាវទាំងសង្ខាង ឯកសណ្ឋានប្រយុទ្ធប៉ាក់ដាក់ កអាវ ពណ៌មាស ។

ខ្នាត : កំពស់រូបភាព ៣៦ម.ម ទទឹង ៣៥ម.ម ។

–កំពស់យុត្តា ២៥ម.ម ចុងផ្លែយុត្តា ពីម្ខាងទៅម្ខាង ២២ម.ម ផ្លែព្រះខ័នគិតពីចុងយុត្តាខាងទៅ ១១ ម.ម ។ ស្លាបសត្វរាងដូចស្លែងក្របី ម្ខាងៗមានស្លាបបីជាន់ ជាន់ទី១ មាន១១ ស្លាប ជាន់ទី ២ មាន៩ស្លាប ជាន់ទី៣មាន៧ស្លាប កំពស់២៤ម.ម ពីចុងស្លាបខាងលើ ម្ខាងទៅម្ខាង ៣៥ម.ម។

៣– សញ្ញាកងថ្មើរជើង :

រូបភាព : មានកាំភ្លើងពីសម័យដើម ២ខ្វែងគ្នា រាងសញ្ញាលេខគុណ កាំភ្លើងខាងស្តាំ ខ្វែងលើកាំភ្លើងខាងឆ្វេង ផលិតពីលោហធាតុ ពណ៌មាស កំរាស់ ១.៥០ម.ម ឯកសណ្ឋានប្រយុទ្ធ ប៉ាក់ដាក់ ក អាវ ពណ៌មាស ។

ខ្នាត : ប្រវែងកាំភ្លើងនីមួយៗ ៣៥ម.ម ស្ពាយកាំភ្លើងនីមួយៗប្រវែង ៤ម.ម ចុងកាំភ្លើង ១.៥០ ម.ម ចំណុចខ្វែងគ្នាចំពាក់កណ្តាល មុំខាងលើ ១២៥អង្សារ មុំចំហៀង ៥៥ អង្សារ ។

–សំរាប់នាយទាហាន នាយទាហានរង និង ពលទាហានថ្មើរជើង ពាក់នៅលើកអាវយោធា ។

៤— សញ្ញាកងនាវាចរខេមរភូមិន្ទ :

រូបភាព : មានរូបសញ្ញាយុថ្កាពីរខ្វែងគ្នា ចំណុចប្រសព្វជាម៉ុំកែងនៅពាក់កណ្តាល រំលេចដោយខ្សែព្ររពីរព័ទ្ធជុំវិញ យុថ្កានីមួយៗ ផលិតពីលោហធាតុពណ៌មាស មានកំរាស់ ១.៥ម.ម ឯកសណ្ឋានប្រយុទ្ធ ចាក់ដាក់ ករអាវពណ៌មាស ។

ខ្នាត : ទំហំរូបភាព សញ្ញាទទឹង ២៩ម.ម កំពស់ ២៦ម.ម ។

–ប្រវែងយុថ្កានីមួយៗ ៣៤ម.ម ។

–ទំហំដងយុថ្កាប្រវែងទទឹង ២ម.ម ។

–រង្វង់កង់ដងយុថ្កាដែលមានបន្ទាត់ផ្ចិតខាងក្រៅ ៤ម.ម និងបន្ទាត់ផ្ចិតខាងក្នុង ២ម.ម ។

–ទំហំខ្សែ ២ម.ម ។

–ប្រវែងដែកខ្វែងយុថ្កា ១០ម.ម ទំហំ ១.៥ម.ម ឃ្លាតពីកង់យុថ្កា ៣ម.ម ។

–ចុងផ្លែយុថ្កា ម្ខាងទៅម្ខាងប្រវែង ១៦ម.ម ។

–សំរាប់នាយទាហាន នាយទាហានរង និងពលទាហាន កងនាវាចរខេមរភូមិន្ទ ពាក់លើ ករអាវ យោធា ។

៥— សញ្ញាកងនាវាចរខេមរភូមិន្ទ សំរាប់ដាក់លើមួកសក្តិ :

រូបភាព : រូបយុថ្កាពីរ ប្រសព្វជាម៉ុំកែង នៅចំកណ្តាលដង ដែលមានព័ទ្ធជុំវិញដោយខ្សែ ។ ហើយមានមកុដនៅលើ យុថ្កាទាំងពីរ ផលិតពីលោហធាតុពណ៌មាស កំរាស់ ១.៥ ម.ម ។

ខ្នាត : កំពស់រូបភាព ៣៤ម.ម ទទឹង ២០ម.ម ។

–មកុដមានបាតទទឹងខាងក្រោម ១៦ម.ម កំពស់មកុដ ២៨ម.ម ។

–យុថ្កានីមួយៗប្រវែង ២៧ម.ម ទទឹង ១៣ម.ម នៅចុងដងយុថ្កាមានរង្វង់មូលមានបន្ទាត់ផ្ចិត ខាងក្រៅ ៣ម.ម ខាងក្នុង ១.៥ម.ម ។

–នៅលើដងយុថ្កា មានដែកកាត់ទទឹងប្រវែង ០៧ម.ម ទំហំ ០១ម.ម ឃ្លាតពីរង្វង់ប្រវែង ០៥ម.ម។

–ទំហំខ្សែបូរ វ៉ៃយុត្តា ០១ម.ម ។
–ផ្ទៃយុត្តានីមួយៗ ពីចុងម្ខាងទៅចុងម្ខាង ១៥ ម.ម ។
–សំរាប់ដាក់នៅលើហ្មុងសត្តិគ្រប់ប្រភេទរបស់កងនាវាចរខេមរភូមិន្ទ លើកលែងតែសត្តិប្រយុទ្ធ ។

៦– សញ្ញាកងអាកាសចរខេមរភូមិន្ទដាក់លើមោតផ័រស្នា :

រូបភាព : រូបស្លាបសត្វ នៅពីលើរូបស្លាបសត្វ ចំពាក់កណ្តាលមានរូបម្កុដធ្វើពីលោហធាតុ ពណ៌មាស កំពស់ ១ម.ម ចំពោះឯកសណ្ឋានប្រយុទ្ធ ចាក់ដាក់ជាប់អាវពណ៌មាស ។

ខ្នាត : រូបភាពមានកំពស់ ៣២ ម.ម ទទឹង ៥៥ម.ម ។
–មានបាតក្រោមប្រវែង១៤ម.ម កំពស់ គិតពីរូបស៊ែងរបស់ម្កុដដល់ចុងខាងលើមានប្រវែង ២៥ម.ម។
– ស្លាបសត្វម្ខាងៗមានពីរជាន់ ។ ជាន់ទីមួយមានស្លាប៩ ទីពីរមានស្លាប៧ ។
– សំរាប់នាយទាហាន នាយទាហានរង និងពលទាហាន អាកាសចរភូមិន្ទពាក់លើហោប៉ៅស្តាំ ហើយខាងលើផ្លាកឈ្មោះទៀត ។

៧– សញ្ញាអាកាសចរខេមរភូមិន្ទដាក់លើហ្មុងសត្តិ :

រូបភាព : មានរូបស្លាបសត្វ និងរូបម្កុដដាក់ពីលើចំកណ្តាល ផលិតពីលោហធាតុពណ៌មាស កំពស់១ម.ម ។

ខ្នាត : រូបភាពមានកំពស់ ២៥ម.ម ទទឹង ៣០ម.ម ។
–រូបម្កុដមានបាតក្រោមប្រវែង ១០ម.ម កំពស់ពីរូបស៊ែងម្កុដទៅលើប្រវែង ២១ម.ម ។
–ស្លាបសត្វនីមួយៗ មានមួយជាន់ មានស្លាបចំនួន ៥ ។
–រូបភាពនេះដាក់លើហ្មុងសត្តិប្រប់ប្រភេទរបស់កងអាកាសចរខេមរភូមិន្ទ លើកលែងតែសត្តិ ប្រយុទ្ធ ។

៨– សញ្ញាអាកាសចរខេមរភូមិន្ទ ពាក់លើ កអាវ :

រូបរាង : (ដូចរូបអាកាសចរខាងលើ) ផលិតពីលោហធាតុ ពណ៌មាស កំរាស់ ១ម.ម ឯកសណ្ឋានប្រយុទ្ធ និងឯកសណ្ឋានបច្ចេកទេស អ្នកបើកបរយន្តហោះ ចាក់ដាក់ កអាវ ពណ៌មាស។

ខ្នាត : រូបភាពមានកំពស់ ៣០ម.ម ទទឹង ៣៥ម.ម ។

នៅចំកណ្តាលស្លាបសត្វ ប្រវែងបណ្តោយ ១៦ម.ម កំពស់ ១០ម.ម ស្លាបមានពីរជាន់ មួយជាន់ៗ មាន ៦ ស្លាប ។

–សំរាប់នាយទាហាន នាយទាហានរង និង ពលទាហាន កងអាកាសចរខេមរភូមិន្ទ ពាក់កអាវយោធា លើលែងតែកងការពារដែនអាកាស និងកងដឹកជញ្ជូនអាកាសចរ ចេញប្ញជិនាញមួយចំនួនទៀត ។

៩– សញ្ញាអាកាសយានិកសំគាល់សញ្ញាបត្រហោះហើរ និងសំរាប់ពាក់លើ ផ្ទៃហោះចើងឆ្វេង :

៩–១ អ្នកបើកបរយន្តហោះ :

រូបរាង :មានរូបសត្វហង្សកំពុងត្រដាងស្លាបឈរក្នុងរង្វង់មូល មានក្បាច់ផ្កាភ្ញីពីសម័យអង្គរ ចំនួនបីជាន់ ខាងក្រោមមានចងខ្សែបូ រូបភាព ពណ៌មាស ផលិតពីលោហធាតុ ពណ៌មាស ។

ខ្នាត :កំពស់សត្វហង្សប្រវែង ២៨ម.ម ទទឹងពីចុងស្លាប ម្ខាងទៅម្ខាងប្រវែង ៦០ម.ម ហើយរូបហង្ស ឈរត្រដាងស្លាប កំពុងប្រុងប្រៀបហើរ ។

–រង្វង់ក្បាច់ផ្កាភ្ញី ខាងក្នុងមានបន្ទាត់ផ្ចិតប្រវែង ៣០ម.ម ខាងក្រៅមានបន្ទាត់ផ្ចិត ៤០ម.ម ។

–រូបភាពនេះសំរាប់ដាក់លើសញ្ញាបត្ររបស់អាកាសយានិក អ្នកបើកបរយន្តហោះ និង ដាក់លើផ្ទៃហៅថៅឆ្វេង អ្នកបើកយន្តហោះ គ្រប់ប្រភេទ ។

៩—២ សញ្ញាសំគាល់សញ្ញាប័ត្រហោះហើរយន្តការី និង សំរាប់ពាក់លើផ្ទៃហោះចំរង់ខ្វេង :

រូបភាព : ខ្នាត និងពណ៌ដូចរូបភាពទី១ តែខុសគ្នា នៅជើងសត្វហង្សមានរូបសញ្ញាគ្រឿងចក្រ មានបន្ទាត់ផ្ចិតខាងក្រៅប្រវែង ៨ម.ម ខាងក្នុង ៣ម.ម ។

- សំរាប់ដាក់លើសញ្ញាប័ត្រហោះហើររបស់យន្តការី និងសំរាប់ពាក់លើផ្ទៃហោះចំរៀង ។

៩—៣— សញ្ញាសំគាល់សញ្ញាប័ត្រហោះហើរ បុគ្គលិកបង្ហាញនាំផ្លូវ និង ពាក់លើផ្ទៃហោះចំរង់ខ្វេង

- រូបភាព ខ្នាត និងពណ៌ ដូចរូបភាពខាងលើ តែខុសគ្នានៅលើជើងសត្វហង្ស មានរូបសញ្ញា ផែនដី មានបន្ទាត់ផ្ចិត ៨ម.ម ។
- សំរាប់ដាក់លើសញ្ញាប័ត្រហោះហើររបស់បុគ្គលិកបង្ហាញផ្លូវ និង សំរាប់ដាក់លើផ្ទៃហោះចំរៀង ។

៩—៤ សញ្ញាសំគាល់សញ្ញាប័ត្រហោះហើរបុគ្គលិកវិទ្យុទាក់ទង និង ពាក់លើផ្ទៃហោះចំរង់ខ្វេង ៖

- **រូបភាព ខ្នាត និងពណ៌** : ដូចរូបភាពខាងលើ តែខុសគ្នា នៅជើងសត្វហង្ស មានរូបសញ្ញាផែនដី និង សញ្ញារលកធាតុអាកាសនៅចំកណ្ដាល ។ បន្ទាត់ផ្ចិតរង្វង់រូបផែនដីប្រវែង ៨ម.ម ។
- ដាក់លើសញ្ញាប័ត្រហោះហើររបស់បុគ្គលិកវិទ្យុទាក់ទង និងបង្ហាញផ្លូវ និង សំរាប់ពាក់លើផ្ទៃ ហោះចំរៀង ។

១០—សញ្ញាអាចចលនគុណ្ណ និង សំភារៈ :

រូបភាព : មានរូបកួមនៅខាងលើ មានអណ្ដាតភ្លើងនៅលើកួម មានគួររង្វង់រាងពងក្រពើ ផលិតពីលោហធាតុ ពណ៌មាស កំរាស់ ១.៥ម.ម ឯកសណ្ឋានប្រយុទ្ធប៉ាក់ដាក់ កអាវ ពណ៌មាស ។

ខ្នាត : កួមមានរាងជារង្វង់ បន្ទាត់ផ្ចិត ១៥ម.ម មាត់កួម ៨ម.ម កំពស់កួម ១ម.មអណ្ដាតភ្លើង មានកំពស់អណ្ដាតទីមួយ១៨ម.ម ទីពីរ ១៦ម.ម

ទីបី ១៤ម.ម អណ្ដាត ភ្លើងទីបួន១២ម.ម អណ្ដាត ភ្លើងនីមួយៗ ប្រវែង ទទឹង ២ម.ម ស្រួចកណ្ដាលជាអណ្ដាតភ្លើង ។

-សំរាប់នាយទាហាន នាយទាហានរង និង ពលទាហានកងឯកភាពបូជនីយដ្ឋាន ភស្តុភារ [illegible] ពាក់លើ កអាវ យោធា ។

១១—សញ្ញាសម្គាល់កងឯកភាពសុខាភិបាល :

រូបរាង : មានរូបសញ្ញាលេខបូក នៅសញ្ញាលេខបូក ត្រង់ទៅលើមានពស់រុំ [illegible] ធ្វើពីលោហធាតុ សញ្ញាលេខបូក ពណ៌ក្រហមពស់ពណ៌ប្រាក់ ឯកសណ្ឋានប្រយុទ្ធចាក់ដាក់កអាវ ពណ៌មាស ។

ខ្នាត : សញ្ញាលេខបូកនីមួយៗប្រវែង ២៨ម.ម ទទឹង [illegible]ម.ម នៅលើ សញ្ញាលេខបូកត្រង់ទៅលើ មានឆ្នូតបណ្ដោយប្រវែង ៦ម.ម ពស់រុំបីជាន់ ក្បាល ពស់ដាក់ពីលើ កន្ទុយពស់ចុះមកក្រោម ២ម.ម ទទឹងពស់ ២ម.ម ។

-សំរាប់នាយទាហាន នាយទាហានរង និងពលទាហាន កងឯកភាពសុខាភិបាល កងយោធពល ខេមរភូមិន្ទពាក់លើ កអាវ យោធា ។

១២—សញ្ញាសម្គាល់កងឯកភាពភូមិសាស្ត្រយោធា :

រូបរាង : មានរូបផែនទីព្រះរាជាណាចក្រកម្ពុជា ពណ៌មាស ក្នុងនោះមាន ទន្លេសាប ទន្លេមេគង្គ នៅលើផែនទីមានរូបកុំប៉ាបញ្ឈរពណ៌ប្រាក់ ផលិតពីលោហធាតុ ឯកសណ្ឋានប្រយុទ្ធចាក់ដាក់ កអាវពណ៌ស ។

ខ្នាត : ទំហំផែនទីមានប្រវែង ៣០ម.ម កំពស់ ២៤ម.ម កំពស់កុំប៉ា ៣០ ម.ម មុំរបស់ចុងកុំប៉ាបើកចេញពីគ្នា ៥០ អង្សារ មុំកុំប៉ាមួយទៅមួយ ២០ ម.ម កល់កុំប៉ាលើលៀនហួសផែនទី ៤ម.ម ចុង ខាងក្រោមលៀនហួស ផែនទី ២ម.ម ។

-សំរាប់នាយទាហាន នាយទាហានរង និងពលទាហាន កងឯកភាពភូមិសាស្ត្រ យោធា ពាក់លើ ក អាវ យោធា ។

១៣–សញ្ញាកងកាំភ្លើងធំ និង ការពារដែនអាកាស :

រូបភាព : មានកាំជ្រួចមួយបញ្ឈរត្រង់ទៅលើ ហើយមានកាណុងកាំភ្លើងធំពីសម័យដើមពីរខ្វែងគ្នាដាក់ពីលើរូបកាំជ្រួច ។ កាណុងខាងឆ្វេង ខ្សែលើខាងស្តាំ ផលិតពីលោហធាតុ ពណ៌មាស កំរាស់ ១.៥ម.ម ឯកសណ្ឋានប្រយុទ្ធ ប៉ាក់ដាក់ កអាវ ពណ៌មាស ។

ខ្នាត : កំពស់កាំជ្រួច ៣៤ម.ម កាណុងកាំភ្លើងធំនីមួយៗប្រវែង ៣៤ម.ម មុំកាណុងកាំភ្លើងធំ ខ្វែងគ្នា មានទំហំមុំខាងលើ និងខាងក្រោម ១១០អង្សារ មុំចំហៀង ៧០ អង្សារ ។

–សំរាប់នាយទាហាន នាយទាហានរង និង ពលទាហានកងកាំភ្លើងធំ កាំជ្រួច និងកងការពារដែន អាកាស ពាក់នៅលើ កអាវ យោធា ។

១៤–សញ្ញាកងរថក្រោះ រថពាសដែក :

រូបភាព : រូបដាវពីរខ្វែងគ្នា នៅចំកណ្តាលមានរូបរថក្រោះ មើលពីមុខ និងក្រវចកសេះ ផលិតពីលោហធាតុ ពណ៌មាស កំរាស់ ១.៥ម.ម ឯកសណ្ឋានប្រយុទ្ធប៉ាក់ដាក់ កអាវ ពណ៌មាស ។

ខ្នាត : ដាវនីមួយៗប្រវែង ៤២ម.ម(ក្នុងនោះដងដាវ ៨ម.ម)ទទឹងរថក្រោះ ២០ម.ម កំពស់ទាំងកាណុង ១៤ម.ម កំពស់ក្រវចកសេះ ១៧ម.ម ចុងក្រវចកសេះ ខាងលើពីមួយទៅមួយ ៩ម.ម លើក្រវចកសេះ មានស្នាមបោះដែកគោលចំនួន ៥កន្លែង ។

–សំរាប់នាយទាហាន នាយទាហានរង និងពលទាហានរថក្រោះ រថពាសដែក ពាក់លើ កអាវ យោធា ។

១៥–សញ្ញាកងឯកភាពបញ្ជូនសារ :

រូបភាព : រូបកងចក្រមានស្លាបខាងក្រៅចំនួន ១៦ នៅលើរូបកងចក្រមានរូប សញ្ញាលេកធាតុអាកាស មុខឡើងទៅលើ ចុងងាកមកស្តាំ ២៥អង្សារ ផលិតពីលោហធាតុពណ៌មាស កំរាស់ ១.៥ម.ម ឯកសណ្ឋានប្រយុទ្ធប៉ាក់ដាក់ កអាវ ពណ៌មាស ។

ខ្នាត : បន្ទាត់ផ្ចិតខាងក្រៅ ២៥ម.ម រង្វង់ខាងក្នុង ទីមួយប្រវែង ១៥ម.ម និងទីពីរប្រវែង ១០ម.ម សញ្ញាឈកធាតុអាកាស បណ្តោយប្រវែង ២៦ម.ម ទទឹងតល់សញ្ញា ៦ម.ម ។

–សំរាប់នាយទាហាន នាយទាហានរង និង ពលទាហានបញ្ជូនសារ ពាក់លើកអាវយោធា ។

១៦–សញ្ញាកងវិស្វកម្ម :

រូបភាព : មានរូបវិមានឯករាជ្យបញ្ឈរ ខាងក្រោមមានតាំងជណ្តើរបីតន្លាក់ ប្រាសាទខាងលើមានតន្លាក់ ៧ ជាន់ ផលិតពីលោហធាតុពណ៌មាស កំរាស់ ១.៥ម.ម ឯកសណ្ឋានប្រយុទ្ធ ប៉ាក់ដាក់ កអាវពណ៌មាស ។

ខ្នាត : កំពស់ ៣២ម.ម បាតក្រោម ១៦ម.ម តួកណ្តាល ១២ម.ម តន្លាក់ក្បាច់ទីមួយ បន្ទាប់ពី តួកណ្តាល ១៤.ម.ម ។

–សំរាប់នាយទាហាន នាយទាហានរង និង ពលទាហានវិស្វកម្មពាក់នៅលើកអាវយោធា ។

១៧–សញ្ញាកងឯកភាពសាលានិងហ្វឹកហ្វឺន :

រូបភាព : មានរូបភាពព្រះខ័នខ្មែរជាមួយស្លាបសត្វមួយ ពណ៌មាស នៅកណ្តាលមានសៀវភៅ មួយបើកពណ៌ប្រាក់ ផលិតពីលោហធាតុ កំរាស់ ១.៥ម.ម ឯកសណ្ឋានប្រយុទ្ធ ប៉ាក់ដាក់កអាវពណ៌មាស ។

ខ្នាត : ព្រះខ័នប្រវែង៣៤ម.ម ស្លាបសត្វមួយ ៣៥ម.ម កំពស់សៀវភៅ ១០ម.ម បណ្តោយ ១៥ម.ម ផ្ទៃកណ្តាលសៀវភៅ ១២ម.ម ។

–សំរាប់នាយទាហាន នាយទាហានរង និង ពលទាហាន កងឯកភាពសាលាគ្រប់ថ្នាក់ ពាក់លើ កអាវ យោធា ។

១៨–សញ្ញាកងឯកភាពតុលាការយោធា :

រូបភាព : រូបក្បាច់ចម្លាក់អង្គរព័ទ្ធជុំវិញរាងស្វែងក្របី ចំកណ្តាលជើងពានជញ្ជីង និងសន្លឹក សៀវភៅច្បាប់ផលិតពីលោហធាតុ ពណ៌មាស កំរាស់ ១.៥ម.ម ឯកសណ្ឋានប្រយុទ្ធប៉ាក់ដាក់ កអាវ ពណ៌មាស ។

ខ្នាត : បន្ទាត់ផ្ចិតរង្វង់ ក្បាច់ចម្លាក់អង្គរខាងក្រៅ ២៥ម.ម ខាងក្នុង ២០ម.ម ជើងពាន និង ដងជញ្ជីងប្រវែង ១៧ម.ម ដងឆ្លងជញ្ជីង ១៣ម.ម សន្លឹកសៀវភៅ ច្បាប់រៀបរាងកោង ពីលើដងកំពស់ ៥ម.ម ជញ្ជីងបន្តោកចុះ ៦ម.ម ។

-សំរាប់នាយទាហាន នាយទាហានរងនិងពលទាហានតុលាការយោធាគ្រប់ថ្នាក់ ពាក់ លើកអាវយោធា ។

១៩—សញ្ញាកងឯកភាពអយ្យការយោធា :

រូបភាព : មានរូបជើងពានចំនួនបីថ្នាក់ ទ្រជញ្ជីងផលិតពីលោហធាតុពណ៌មាស កំពស់ ១.៥ម.ម ឯកសណ្ឋានប្រយុទ្ធ ប៉ាក់ដាក់កអាវពណ៌មាស ។

ខ្នាត : កំពស់រូបភាព ៣០ម.ម បាតជើងពានខាងក្រោម ១៦ម.ម បាតជើងពានទីពីរប្រវែង ១០ម.ម មាត់ជើងពានទីពីរប្រវែង ២០ម.ម បាតជើងពានទីពីរប្រវែង ១១ម.ម មាត់លើ ប្រវែង ១៥ម.ម បង្គោល ជញ្ជីងរាងកោងចុង មានក្បាច់ប្រវែង ១៧ម.ម ជញ្ជីងបន្តោកចុះ ៦ម.ម កំពស់ជញ្ជីងទីមួយនិងទីពីរ ប្រវែង ១៥ម.ម ជើងពានទី ៣៦ ម.ម ។

-សំរាប់នាយទាហាន នាយទាហានរង និងពលទាហានអយ្យការយោធាពាក់លើកអាវយោធា ។

២០—សញ្ញាត្រែទំព និងសិល្បៈ កងយោធពលខេមរភូមិន្ទ :

រូបភាព : មានរូបអក្សរភ្លេងពីសម័យដើម ផលិតចេញពីលោហធាតុ ពណ៌មាស ។

ខ្នាត : កំពស់រូបភាព ២៦ម.ម បាតក្រោម ១២ម.ម ទទឹងរូបភាពកណ្ដាល ២០ម.ម កំនួស កាត់ខាង លើ១៦ម.ម កំរាស់ ១.៥ម.ម ឯកសណ្ឋានប្រយុទ្ធ ប៉ាក់ដាក់ កអាវពណ៌មាស ។

-សំរាប់នាយទាហាន នាយទាហានរង និងពលទាហានត្រែទ័ព និង សិល្បៈកងយោធពលខេមរភូមិន្ទ ពាក់លើ កអាវ យោធា ។

២១—សញ្ញាអាចឯកភាពចំរូត្រយោធា :

សញ្ញាអាចឯកភាពចំរូត្រយោធមាន ៣ ប្រភេទ :

ទី១—រូបភាព :មានរូបប្រាសាទអង្គរវត្តកំពូលបីនៅចំកណ្តាលស្លាបសត្វ នៅពីលើ នៅចំកណ្តាលមានរូបព្រះខ័ន មុខចុះក្រោម នៅកណ្តាលព្រះខ័នមានរូបតួអក្សរ (ឆ) ខាងក្រោមកណ្តាល មាន បន្ទោកចុង ស្រួចរាងត្រីកោណ ។ ធ្វើពីលោហធាតុ ប្រាសាទអង្គរ ពណ៌មាស ព្រះខ័ន និង ស្លាប ពណ៌ប្រាក់ រំយោលចុងស្រួច ចំកណ្តាលចុះក្រោម ពណ៌ក្រហម (ឆ) ពណ៌ខៀវ កំរាស់ ១.៥ម.ម ឯកសណ្ឋាន ប្រយុទ្ធ ប៉ាក់ដាក់លើហោប៉ៅស្តាំ ពណ៌ខ្មៅ ។

ខ្នាត : កំពស់រូបភាព ៣៧ម.ម ទទឹង ៧០ម.ម ។

–បាតប្រាសាទអង្គរវត្តប្រវែង ៣២ម.ម កំពស់ប្រាសាទ ១៥ម.ម ព្រះខ័នប្រវែង ២២ម.ម កំពស់អក្សរ (ឆ) ១០ម.ម កំពស់ស្លាបសត្វ ១៥ ម.ម រំយោលចុះក្រោម ១៤ម.ម សាបសត្វមានពីរជាន់ ជាន់ទីមួយ មាន១១ ស្លាប ជាន់ទីពីរមាន ១០ ស្លាប ។

–សំរាប់នាយទាហាន នាយទាហានរង និង ពលទាហានកងឆ័ត្រយោង ពាក់នៅលើហោប៉ៅខាងស្តាំ និង ដាក់លើសញ្ញាប័ត្រកងឆ័ត្រយោង (ពាក់បានតែចំពោះយោធិនដែលបានឆ្លងកាត់ការហ្វឹកហាត់ ឆ័ត្រយោងរួច) ។

ទី ២—រូបភាព : មានឆ័ត្រយោងស្លាបសត្វ និងខាងក្រោមក្បាច់ភ្ញីផ្កា ទ្រពីខាងក្រោម ផលិតពី លោហធាតុ ឆ័ត្រយោង និងស្លាបសត្វ ពណ៌ទឹកប្រាក់ ផ្កាភ្ញី ពណ៌មាស កំរាស់ ១.៥ម.ម ។

ខ្នាត : កំពស់រូបភាព ៤៥ម.ម ទទឹង ៨២ម.ម ។

–កំពស់ឆ័ត្រយោង ៣៥ម.ម ខ្សែឆ័ត្រ ២១ម.ម ឆ័ត្រវែង ១៤ម.ម ទទឹងឆ័ត្រខាងក្រោមចុងឆ័ត្រ និង ខ្សែចន្លោះគល់ស្លាបខាងលើទាំងពីរប្រវែង ៣០ម.ម គល់ស្លាបខាងលើ ទៅចុងស្លាបម្ខាងៗ ប្រវែង ២៥ម.ម ក្បាច់ផ្កាភ្ញីខាងក្រោមរង្វង់ស្នែងក្របី ខាងក្រោមផ្កាមួយមានបន្ទាត់ផ្ចិត ១២ម.ម ផ្កាភ្ញីសងខាងប្រវែង ២២ម.ម ។

ទី៣–រូបរាង : រូបភាពនិងខ្នាត ពណ៌មានដូចរូបទីពីរ តែបន្ថែមនៅចំកណ្ដាលចំណុចតល់ស្លាប ខាងក្រោមមានគងបីរុំចូលគ្នា ខាងលើពណ៌ក្រហម ខាងឆ្វេងពណ៌លឿង ខាងស្ដាំពណ៌ខៀវ រៀរាងមុំចង្ក្រានបន្ទាត់ ធ្នឹកខាងក្រៅ ៨ម.ម ខាងក្នុង ៦ម.ម ។

–សំរាប់នាយទាហាន នាយទាហានរង ជាគ្រូបង្ហាត់ធំត្រយោធ ពាក់នៅលើហោប៉ៅខាងស្ដាំ ដាក់លើ សញ្ញា បំគ្រូធំត្រយោធ ។

២២–ផ្លាកសញ្ញាកងឯកភាពបច្ចេកទេស :

–ផ្លាកសញ្ញាបច្ចេកទេសរូបមានពីរប្រភេទ គឺប្រភេទទីមួយ សំរាប់នាយទាហាន នាយទាហានរង និងពល ទាហានជំនាញបច្ចេកទេសនៅនាយកដ្ឋានក្រសួង និង ចំណុះទីបញ្ជាការ អគ្គសេនាធិការ និងប្រភេទទីពីរ សំរាប់នាយទាហាន នាយទាហានរង និងពលទាហាន នៅតាមបណ្ដាកង ឯកភាពចំណុះ ផ្លាកសញ្ញាទាំងអស់ពាក់នៅលើ កអាវ យោធា ចំពោះឯកសណ្ឋានប្រយុទ្ធ ចាក់ដាក់ កអាវ ពណ៌មាស ។

សញ្ញាបច្ចេកទេសទី ១ :

រូបរាង : មានរូបកុំប៉ា ស្លាបសត្វ នាវា កាំភ្លើងធំ និងសញ្ញាគ្រឿងចក្រ ផលិតពីលោហធាតុ ពណ៌មាស ឯកសណ្ឋានប្រយុទ្ធចាក់ដាក់ កអាវ ពណ៌មាស ។

ខ្នាត : កំពស់កុំប៉ា (កំពស់រូបភាព) ៣ស.ម ចន្លោះចុងកុំប៉ា ម្ខាងទៅម្ខាង ១.៨ស.ម ចុងស្លាប សត្វម្ខាង ២ស.ម ស្លាបសត្វម្ខាងៗមានស្លាប ៩ជាន់ ហើយស្លាបសត្វដាក់នៅចំកណ្ដាលកុំប៉ា នៅចន្លោះ កណ្ដាលស្លាបសត្វមានរូបនាវាធុនតូច ជាបីបណ្ឌូរបណ្ដោយកុំប៉ា ដែលមានមុខស្រួច បណ្ដោយ ១ស.ម ទទឹងតួចនាវា ០.៣៥ស.ម នៅផ្នែកខាងក្រោយនាវា មានក្បាច់ចតុកោណកែងបួនជាន់ត្រួតលើគ្នា ផ្នែកខាង មុខនាវា មានដាក់រូបកាំភ្លើងធំ បណ្ដោយ ០៣ស.ម នៅខាងក្រោមស្លាបសត្វ មានរូបសញ្ញាគ្រឿងចក្រ ខាងក្រោម ២ស.ម បណ្ដោយខាងលើ ១.៥ស.ម ទទឹង សញ្ញាគ្រឿងចក្រ ០.៤០ស.ម ។

សញ្ញាបច្ចេកទេសទី ២ :

រូបភាព : មានរូបកាំភ្លើងពីសម័យបុរាណ ខ្វែងជាមួយកូនសោ (កាំភ្លើងនៅឆ្វេងលើកូនសោនៅស្តាំ)និង មានរូបសញ្ញាគ្រឿងចក្រដាក់លើកាំភ្លើង និងកូនសោផ្នែកខាងក្រោមផលិតពី លោហធាតុ ពណ៌មាស(ឯក សណ្ឋានប្រយុទ្ធ ចាក់ករអាវពណ៌មាស ។

ខ្នាត : កំពស់កាំភ្លើង ៣ស.ម កំពស់កូនសោ ២.៥ស.ម មុំខ្វែងគ្នារវាងកាំភ្លើងនិងកូនសោ១៨ អង្សារ សញ្ញាចក្ររាងកោងឡើងលើ បណ្តោយ ខាងក្រោម ២ស.ម បណ្តោយខាងលើ ១.២ស.ម ទទឹង សញ្ញាគ្រឿងចក្រ ០.៤ស.ម ។

២៣–ផ្លាកសញ្ញាដាក់ករអាវរបស់កងទ័ពពិសេសទ័ពត្រយោង :

រូបភាព : មានរូបកាំភ្លើងពីបុរាណ២ដាក់ខ្វែងគ្នា(ខាងឆ្វេងគងលើខាងស្តាំ) និងរូបធ្មត្រយោងនៅចន្លោះខ្វែងគ្នារវាងកាំភ្លើងទាំងពីរផ្នែកខាងលើ ផលិតពីលោហធាតុពណ៌មាស ពាក់លើករអាវ យោធា ឯកសណ្ឋានប្រយុទ្ធចាក់លើករអាវ ពណ៌មាស ។

ខ្នាត : កំពស់កាំភ្លើងធំមួយ ៣.២ស.ម មុំខ្វែងគ្នា របស់កាំភ្លើង ៨០អង្សារ ។

–កំពស់ធ្នូត្រគីតទាំងខ្សែ ១.៤ស.ម និងខ្សែធ្នូត្រចំនួន៥(ធ្នូត្រខាងលើ កំពស់ ០.៧ស.ម) ។

២៤–ផ្លាកសញ្ញាកងឯកភាពដឹកជញ្ជូនគ្រប់ប្រភេទ :

រូបភាព : មានរាងជារង្វង់មូល ដែលជានិមិត្តរូបចង្កូតកប៉ាល់ និងចង្កូតរថយន្តដាក់ត្រួតពីលើគ្នា ហើយមានកាំចំនួន ៨ ពណ៌មាស នៅចំកណ្តាលមានរូបស្លាបសត្វ ពណ៌ប្រាក់ តំណាងអោយកង ដឹកជញ្ជូន អាកាសចរ ឯកសណ្ឋានប្រយុទ្ធ ចាក់ដាក់ ករអាវ ពណ៌មាស ។

ខ្នាត : រង្វង់ខាងក្រៅ មានបន្ទាត់ផ្ចិតប្រវែង ២៨ម.ម រង្វង់ខាងក្នុងមានបន្ទាត់ផ្ចិត ២០ម.ម ។

–នៅផ្នែករង្វង់ខាងក្រៅ មានធ្មេញជាតន្ទាក់ដូចសញ្ញាគ្រឿងចក្រ ។

-កាំនៃរង្វង់ មាន៨ ចង្កូលទាំង ៨ទិស ។

-ស្លាបសត្វនៅខាងក្នុង ចំកណ្តាលនៃរង្វង់ដាក់គល់ស្លាបមកក្រោម ចុងស្លាបឡើងលើ ។

-ស្លាបមានចំនួន ២ជាន់ ស្លាបនីមួយៗមានស្រទាប់ស្លាប ចំនួន ៦ ។ កំពស់រូបភាពស្លាបប្រវែង ១២ម.ម និងទទឹងប្រវែង ៨ម.ម ។

ផ្លាកសញ្ញានេះ សំរាប់កងឯកភាពដឹកជញ្ជូនគ្រប់ប្រភេទ ដូចជា ដឹកជញ្ជូនជើងគោក នាវាចរ និង អាកាស ចរ ។

២៥–ផ្លាកសញ្ញាកងជីវពល :

-ផ្លាកសញ្ញាដេរភ្ជាប់នៅលើដៃអាវស្តាំ ចុះពីថ្នេរស្មា ៥ស.ម មានរាងមូលបន្ទាត់ផ្ចិត ៧ស.ម ស្រទាប់ខាងក្រៅពណ៌មាស ទទឹងស្រទាប់ ៣ម.ម ផ្ទៃលើ ១/៤ នៃរង្វង់ពណ៌ខៀវ ហើយសរសេរ អក្សរ (**ព្រះរាជាណាចក្រកម្ពុជា**) កំពស់អក្សរ៥ម.មផ្ទៃកណ្តាល ១/២ នៃរង្វង់ពណ៌ក្រហម ហើយមានធ្នូកំពុងយឺតដាក់គ្រាប់ព្រួញ ដើម្បីប្រុងប្រៀបបាញ់ ពណ៌ស កំពស់ធ្នូប្រវែង ៥ម.ម ទទឹងតិតទាំងព្រួញប្រវែង ៥ ស.ម មុខព្រួញត្រូវតំបញ្ច្រាស់ទិស មានសរសេរអក្សរខាងក្រោមមាន ១/៤ នៃរង្វង់ ពណ៌ខៀវ ហើយសរសេរ អក្សរ (កងជីវពល) កំពស់អក្សរ ៧ម.ម ។ ចំពោះការផលិតធ្វើពីក្រណាត់អាចបោះពុម្ព ឬ ប៉ាក់ ។

មាត្រា ៧ : **ទង់កងយោធពលខេមរភូមិន្ទ ត្រូវបានកំណត់ដូចខាងក្រោម :**

១–ទង់កងយោធពលខេមរភូមិន្ទ :

-យកតំរូទង់ជាតិព្រះរាជាណាចក្រកម្ពុជា មានប្រាសាទកំពូលបី បណ្តោយ ១.៩៥ម. ទទឹង ១.៨៦២៥ម. ដងទង់ ២,៨៥ម. នៅផ្ទៃខាងលើជ្រុងខាងដើម មានរូបហនុមានកាន់ព្រះខ័ន ពណ៌មាស កំពស់រូប ហនុមាន ២៥ស.ម ទទឹង ២២ស.ម នៅក្រោមប្រាសាទ សរសេរអក្សរ ពណ៌មាស(កងយោធពលខេមរភូមិន្ទ) កំពស់ អក្សរ១៥ស.ម នៅក្បាលដងទង់ស្រួច ខាងលើឆ្លាក់រូប

មកុដមាន ព្រះខ័នទ្រ ពណ៌មាសធ្វើពីលោហធាតុ នៅក្បាលដងទង់មាន រំយោលពីរ ពណ៌មាស មួយប្រវែង ១ម មួយទៀតប្រវែង ១.២៥ម ។

២—ទង់អគ្គសេនាធិការ កងយោធពលខេមរភូមិន្ទ :

–យកទង់ជាតិព្រះរាជាណាចក្រកម្ពុជា មានប្រាសាទអង្គរវត្តកំពូលបី មានបណ្តោយ ១.៩៥ម ទទឹង ១.៤៦២៥ម. ដងទង់ ២.៨៥ម. ។ នៅជ្រុងខាងលើ ផ្នែកខាងដើមទង់មានសញ្ញាហនុមាន មានទំហំ កំពស់រូបភាព ២៥ម. ទទឹង ២២ស.ម ។

–នៅខាងក្រោមប្រាសាទ លើផ្ទៃពណ៌ខៀវ មានសរសេរអក្សរ ពណ៌មាស (អគ្គសេនាធិការកងយោធពលខេមរភូមិន្ទ)កំពស់អក្សរ ១៥ស.ម ។

–នៅក្បាលដងទង់ស្រួច ខាងលើឆ្លាក់រូបមកុដមានព្រះខ័នទ្រ ធ្វើពីលោហធាតុ ពណ៌មាស នៅក្បាល ដងទង់ មានរំយោល២ ពណ៌មាស មួយប្រវែង ១ម មួយទៀតប្រវែង ១.២៥ម ។

៣—ទង់ជ័យយោធភូមិភាគ ឬកងពលធំ ថ្នាក់ឬឋាក់ឬវរសេនា :

–យកទង់ជាតិព្រះរាជាណាចក្រកម្ពុជា មានប្រាសាទអង្គរវត្តកំពូលបី មានបណ្តោយ ១.៧០ម ទទឹង ១.៣៥ម ដងទង់ ២.៨០ម នៅជ្រុងខាងដើមផ្នែកខាងលើមានរូបសញ្ញាទំពជំនាញកំពស់ ២៥ម.ម ទទឹង ២២ស.ម ពណ៌មាស នៅខាងក្រោមប្រាសាទ សរសេរអក្សរ ពណ៌មាស ឈ្មោះកងឯកភាពនីមួយៗ កំពស់ អក្សរ ១៥ស.ម ។ នៅក្បាលដងទង់ស្រួច ខាងលើឆ្លាក់រូបមកុដ មានព្រះខ័នទ្រ ធ្វើពីលោហធាតុ ពណ៌មាស នៅក្បាលដងទង់មានរំយោល ២ពណ៌មួយប្រវែង១ម មួយទៀតប្រវែង ១.២៥មដោយខ្សែកអាកាសចរ រូបមកុដមានស្លាបសត្វទ្រ និងនាវាចររូបមកុដ មានយុថ្កាទ្រពីក្រោម ។ ដោយខ្សែកអាកាសចរ មានរូបស្លាបសត្វមកុដ និង កងនាវាចររូបយុថ្កា ទ្រមកុដនៅខាងក្បាលដងទង់ ។

៤–ទង់ជ័យថ្នាក់កងពលធំ និងថ្នាក់ប្រហាក់ប្រហែល :

–យកទង់ជាតិព្រះរាជាណាចក្រកម្ពុជា ប្រាសាទអង្គរវត្តកំពូលបី បណ្តោយ ១.៧០ម ទទឹង ១.២៧៥ម ដងទង់ ២.៥៥ម នៅជ្រុងខាងដើម ផ្នែកខាងលើ មានរូបទំពជំនាញកំពស់ ២៥ស.ម ទទឹង ២២ស.ម ពណ៌មាស ខាងក្រោម ប្រាសាទសរសេរអក្សរ ពណ៌មាស ឈ្មោះកងឯកភាពនីមួយៗ កំពស់អក្សរ ១៥ស.ម ។ នៅក្បាលដងទង់ស្រួច ខាងលើឆ្លាក់រូបម្កុដមានព្រះខ័នទ្រ ធ្វើពីលោហធាតុពណ៌មាសនៅកក្បាលដងទង់មានរំយោល ២ ពណ៌មាស មួយប្រវែង ១ម មួយទៀតប្រវែង ១.២៥ម ។ ដោយខ្សែក អាកាសចរ រូបម្កុដមានស្លាបសត្វទ្រ និង នាវាចរមានយុថ្កាទ្រពីក្រោម ។

៥–ទង់ជ័យថ្នាក់កងពលតូច តំបន់ប្រតិបត្តិការសឹក ទ័ពសេនាធំ និងថ្នាក់ប្រហាក់ប្រហែល :

–យកទង់ជាតិព្រះរាជាណាចក្រកម្ពុជា មានប្រាសាទកំពូលបី មានបណ្តោយ ១.៦០ម ទទឹង ១.២០ម ដងទង់ ២.៤០ម ។ នៅជ្រុងខាងដើមផ្នែកខាងលើ មានរូបសញ្ញាទំពជំនាញ ពណ៌មាសមានកំពស់ ដូចខាងលើ ខាងក្រោម ប្រាសាទ អង្គរវត្តសរសេរអក្សរពណ៌មាស ឈ្មោះកងឯកភាពនិមួយៗ (កំពស់អក្សរ ១៥ស.ម) ។ នៅក្បាលដងទង់ស្រួច ខាងលើឆ្លាក់រូបព្រះខ័ន ធ្វើពីលោហធាតុ ពណ៌មាស នៅក្បាល ដងទង់មានរំយោល២ ពណ៌មាស ប្រវែង ១ម មួយទៀត ប្រវែង ១.២៥ម ។ ដោយខ្សែកអាកាសចរ រូបម្កុដមានស្លាបសត្វទ្រពីក្រោមម្កុដ និងនាវាចរ មានរូប យុថ្កាទ្រពីក្រោម ។

មាត្រា ៨ : ត្រូវបានកំណត់អំពីរបៀបប្រើប្រាស់ និង ពាក់ឯកសណ្ឋាន ផ្លាកនានា នៃកងយោធពលខេមរភូមិន្ទដូចខាងក្រោមនេះ ÷

ការស្លៀកពាក់ឯកសណ្ឋាន គឺជាច្បាប់របស់កងយោធពលខេមរភូមិន្ទ ដែល នាយទាហាន នាយទាហានរង និង ពលទាហានគ្រប់រូប ត្រូវអនុវត្តន៍យ៉ាងម៉ឺងម៉ាត់បំផុតមិនអាចខ្វះបានឡើយ សំដៅធ្វើអោយយោធិនគ្រប់រូបទូទាំងកងយោធពលខេមរភូមិន្ទ បានឯកភាពគ្នា ។ ហើយការស្លៀកពាក់ឯក

សណ្ឋានត្រូវអនុវត្តន៍អោយត្រឹមត្រូវតាមការកំណត់ នៃអនុក្រឹត្យនេះ មិនអនុញ្ញាតិអោយយោធិនណាម្នាក់ ស្លៀកពាក់ខុសពីការកំណត់ឡើយ ហើយការស្លៀកពាក់ឯកសណ្ឋាន ត្រូវតែពាក់សក្តិ តាមឋានន្តរសក្តិរបស់ខ្លួនព្រមទាំងផ្លាកសញ្ញាផ្សេងៗ ដែលកងយោធពលខេមរភូមិន្ទ បានកំណត់ ។

ការប្រើប្រាស់ និងពាក់ឯកសណ្ឋាន ផ្លាកសញ្ញានានា :

១—ឯកសណ្ឋានធំលេខ ១ (អាវកុដស)

–ឯកសណ្ឋានធំលេខ ១ សំរាប់ពាក់ក្នុងពិធី ក្នុងព្រះបរមរាជវាំង និងព្រះរាជពិធីដូចជា(ច្រត់ព្រះ នង្គ័ល អុំទូក បុណ្យឯករាជ្យជាតិ ។ល។

–ស្លៀកពាក់ឯកសណ្ឋានធំ អាវកុដស ខោពណ៌ក្រមៅ ឆ្នូតក្រហម មួកកាស្កេតខ្មៅ មានរូបព្រះសង្ហារ ស្បែកជើងឃ្លុបស្បែក កខ្ចីពណ៌ខ្មៅ ស្រោមជើងខ្មៅ ពាក់សក្តិលើស្មា ដែលមានផ្ទៃហ៊ុងសក្តិក្រណាត់កាំម្ចី ពណ៌មាស ពាក់ខ្សែរិយោលលើស្មាស្តាំ កន្ទុយខ្សែថ្នក់ឡេវអាវទី២ និង ពាក់គ្រឿងឥស្សរិយយសនៅខាងឆ្វេង (បើមាន)ហើយស្រោមដៃតាមពិធីការកំណត់ ។ ចំពោះផ្លាកឈ្មោះ រូបហនុមាន និងសញ្ញាប្រភេទទ័ពនៅកអាវ ឬ សញ្ញាផ្សេងៗទៀតមិនត្រូវពាក់ជាមួយឯកសណ្ឋានធំ លេខ ១ នេះឡើយ ។

–ចំពោះកងនាវាចរ និងអាកាសចរ ត្រូវពាក់ឯកសណ្ឋានធំលេខ ១ របស់ខ្លួនរបៀបស្លៀកពាក់និង ពាក់សំភារៈរួមផ្សំដូចទ័ពជើងគោកដែរ ។

២—ឯកសណ្ឋានធំលេខ ២ (អាវទ័រី)

–ឯកសណ្ឋានធំលេខ២នេះ ពាក់សំរាប់ចូលរួមពិធីការជាតិ និង អន្តរជាតិធំ ។ (តាមការកំណត់របស់ពិធីការ) ព្រមទាំងការចេញទៅបំពេញបេសកម្ម ក្រៅប្រទេស ។

–ស្លៀកពាក់ឯកសណ្ឋានធំលេខ ២ ពេលថ្ងៃពាក់អាវសឺមី ពណ៌កាគី ពេលយប់ និងពិធីបុណ្យសពអាវសឺមីពណ៌ស ក្រវ៉ាត់កពណ៌ខ្មៅ ខោជើង វែងពណ៌កាគី មួកកាស្កេតពណ៌កាគី មានរូបព្រះសង្ហារ ស្បែកជើងកខ្ចី ពណ៌ខ្មៅ ស្រោម

ជើង ពណ៌ខៀវ ពាក់សក្តិស្មា ផ្ទៃហ៊ុងពណ៌ខៀវ ក្បាលស្រួច ពាក់ខ្សែរ៉ៃដោយលើស្មាស្តាំ កន្ទុយខ្សែពាក់ឡេវអាវទី១ ពាក់សញ្ញានៅ កអាវ ពាក់ផ្លាកឈ្មោះលើ ហោប៉ៅអាវស្តាំ បន្ទោក្សរូបហនុមានលើហោប៉ៅស្តាំ ពាក់ស្រោមដៃ តាមពិធីការកំណត់ និង គ្រឿងឥស្សរិយយសនៅខាងឆ្វេង (លក្ខណៈចាំបាច់ គួរពាក់មេដៃ និង លក្ខណៈធម្មតា ពាក់ក្បាលមេដៃ) ។ ចំពោះការចេញទៅបំពេញបេសក កម្មក្រៅប្រទេស មិនបានពាក់ខ្សែរ៉ៃយោលឡើយ ។

–ចំពោះកងនាវាចរ និង អាកាសចរ ត្រូវស្លៀកពាក់ឯកសណ្ឋានធំលេខ២របស់ខ្លួន និង ពាក់គ្រឿង រួមផ្សេងៗទៀត ព្រមទាំងរបៀបពាក់ដូចទ័ពជើងគោកដែរ ។ តែកងអាកាសចរឆ័ត្រយោង ត្រូវពាក់សញ្ញារបស់ខ្លួនលើផ្លាកឈ្មោះថែមទៀត។ ការចេញទៅក្រៅប្រទេសមិនបានពាក់ខ្សែរ៉ៃយោលឡើយ ។ ចំពោះនៅដៃអាវ មិនបានពាក់ផ្លាកកងយោធពលខេមរភូមិន្ទ និង ផ្លាកអ្វីទៀតឡើយ ។

៣–ឯកសណ្ឋានលេខ ៣ (សាហារីយ៉ែន)

–ឯកសណ្ឋាននេះពាក់សំរាប់ចូលរួមក្នុងពិធីជាតិ អន្តរជាតិដែល មានលក្ខណៈធម្មតា និង ពិធីការយោធាផ្សេងៗ ដូចជាទទួលភ្ញៀវជាតិ អន្តរជាតិ ពិធីបិទវគ្គបើកវគ្គ ។ ល ។

–ការស្លៀកពាក់ : ពាក់អាវសាហារីយ៉ែន នៅដៃអាវស្តាំ មានផ្លាកកងយោធពលខេមរភូមិន្ទ ខោជើងវែង ពណ៌គ្រែអី មួកកាស្កេត ពណ៌កាគីមានរូបព្រះសង្ហារ ស្បែកជើងស្បែក កខ្លីពណ៌ខៀវ ពាក់សញ្ញាក ពាក់សក្តិស្មាដែលមានផ្ទៃហ៊ុងសក្តិពណ៌ខៀវក្បាលស្រួច ពាក់ផ្លាកឈ្មោះ សញ្ញាហនុមាន និងក្បាលមេដៃ (បើមាន) ។

–ចំពោះកងនាវាចរ និងអាកាសចរ ត្រូវស្លៀកពាក់ឯកសណ្ឋានលេខ៣របស់ខ្លួន ហើយពាក់គ្រឿងរួមផ្សេងៗទៀត និងរបៀបប្រើប្រាស់ដូចទ័ពជើងគោក តែកងអាកាសចរឆ័ត្រយោង ឬ កងឯកភាពដែលមានសញ្ញាពាក់លើហោប៉ៅស្តាំ លើផ្លាកឈ្មោះត្រូវពាក់ថែមទៀត ។

៤—ឯកសណ្ឋានលេខ ៤ (ឯកសណ្ឋានការងារ)

–ឯកសណ្ឋាននេះសំរាប់ពាក់ធ្វើការងារធម្មតាក្នុងការិយាល័យ ឬក្នុងបន្ទាយ និង ទំនាក់ទំនងការងារធម្មតា ។

–**ការស្លៀកពាក់** : ពាក់អាវដៃខ្លី ពណ៌កាគី នៅដៃអាវស្ដាំដាក់ផ្លាក កងយោធពលខេមរភូមិន្ទ និង នៅដៃអាវឆ្វេង ពាក់ផ្លាកកងឯកភាព(បើមាន) ខោជើងវែងពណ៌គ្រែអ៊ី ខ្សែក្រវាត់តូច ពណ៌គ្រែអ៊ី មួកបេរេ ពណ៌គ្រែអ៊ី មានរូបព្រះសង្ហារនៅខាងផ្នែកខាងស្ដាំ ស្បែកជើងស្បែក កខ្លីពណ៌ខ្មៅ និង ស្រោមជើងខ្មៅ ពាក់សញ្ញាប្រភេទទ័ពនៅកអាវ ផ្លាកឈ្មោះលើហោប៉ៅស្ដាំ សញ្ញាឋានៈមានពាក់នៅខ្សែហោប៉ៅស្ដាំ សក្តិស្មាដែលមានហ្គុង សក្តិខ្មៅ ក្បាលស្រួច និងពាក់ក្បាលមេដៃ (បើមាន)អាវជានិច្ចត្រូវដាក់ក្នុងខោ ។

–ចំពោះកងនាវាចរ និងអាកាសចរត្រូវស្លៀកពាក់ឯកសណ្ឋាន ការងារតាមការកំណត់ខាងលើ ហើយពាក់គ្រឿងរូបផ្សេងៗទៀត និងរបៀបប្រើប្រាស់ ដូចទ័ពជើងគោក តែកងអាកាសចរ និងបណ្ដាកងឯកភាព ដែលមានសញ្ញាលើហោប៉ៅស្ដាំ លើផ្លាកឈ្មោះត្រូវពាក់ថែមទៀត ។

៥—ឯកសណ្ឋានលេខ៥(ឯកសណ្ឋានប្រយុទ្ធ)

–ឯកសណ្ឋានប្រយុទ្ធនេះ ពាក់សំរាប់ចេញប្រតិបត្តិការ ឬបេសកកម្មក្រៅបន្ទាយ ចំពោះនៅក្នុងបន្ទាយអាចពាក់បាន តែត្រូវមានការកំណត់ពីមេបញ្ជាការ ហើយអោយបានឯកភាពគ្នាទូទាំងកងឯកភាព ។

–**ការស្លៀកពាក់** : ពាក់អាវដៃវែង ហោប៉ៅបួន អាចមូរដៃបាន តែត្រូវឯកភាពគ្នា(បើសិនជាមូរត្រូវមូរទាំងអស់គ្នា) នៅដើមដៃអាវស្ដាំ ដាក់ផ្លាកកងយោធពលខេមរភូមិន្ទ និង ដើមដៃអាវ ឆ្វេងដាក់ផ្លាកកងឯកភាព (បើមាន) ខោជើងវែងមានហោប៉ៅ៦ ជើងខោចងខ្សែ ពាក់មួកហ៊្សកកី មានរូបព្រះសង្ហារ ឬ ពាក់ប៉េរ៉េដាក់រូបព្រះសង្ហារស្ដាំ ទាញបញ្ចិតមកឆ្វេង នៅពេលចេញប្រតិបត្តិការសឹក អាចពាក់មួកដែក (ចំពោះការពាក់មួកគ្រប់ប្រភេទ ត្រូវអនុវត្តតាមការកំណត់របស់កងឯកភាពនីមួយៗ បើសិនពាក់មួយណា ត្រូវពាក់មួយនេះ

អោយបានឯកត្តាទាំងអស់ ហើយហាមការស្លៀកពាក់ដោយគ្មានមួក ពាក់សក្តិប្រយុទ្ធនៅកអាវឆ្វេង នៅកអាវស្តាំពាក់ផ្លាកសញ្ញាប្រភេទទ័ព ឬ ជំនាញនៅកអាវ (អាចប៉ាក់ដេរភ្ជាប់កអាវពណ៌មាស) ផ្លាកឈ្មោះត្រូវដេរភ្ជាប់អាវលើហោប៉ៅស្តាំ អក្សរពណ៌ខ្មៅ ពាកកន្សែងរុំក អាចមិនពាក់បានតាមការកំណត់របស់កងឯកភាព ពាក់សាំងទៀរ៉ុង (ខ្សែក្រវាត់ធំ) និងពាក់ស្បែកជើងកវែង ពណ៌ខ្មៅ ឬស្បែកជើង ម៉ៃហ្វុកកវែង ។

–ចំពោះកងអាកាសចរ និង នាវាចរពាក់ឯកសណ្ឋានប្រយុទ្ធរបស់ខ្លួន ហើយពាក់គ្រឿងរួមផ្សំ និងរបៀបប្រើប្រាស់ដូចទ័ពជើងគោក ។ តែងកងអាកាសចរ និងបណ្តាកងឯកភាពដែលមានសញ្ញា លើហោប៉ៅស្តាំ លើផ្លាកឈ្មោះត្រូវប៉ាក់ដាក់ភ្ជាប់អាវរូបសញ្ញាពណ៌មាស ។

៦–ឯកសណ្ឋានបច្ចេកទេសជំនាញ :

–ការស្លៀកពាក់ឯកសណ្ឋានបច្ចេកទេសជំនាញដែលបានកំណត់ខាងលើ ចំពោះបណ្តាកងឯកភាពដែលមានឯកសណ្ឋាននេះ ត្រូវពាក់នៅពេលធ្វើការបច្ចេកទេសជាមួយគ្រឿងចក្រ និង ឧបករណ៍បច្ចេកទេសពេលចប់ត្រូវផ្លាស់ប្តូរវិញ មិនបានពាក់ឯកសណ្ឋាននេះ ដើរចេញក្រៅកងឯកភាព ឬ ក្រៅម៉ោងធ្វើការងារបច្ចេកទេសឡើយ លើកលែងតែកងជីវពល អ្នកបើកបរយន្តហោះ ។ ហើយឯកសណ្ឋាននេះមិនចាំបាច់ពាក់សក្តិសញ្ញាផ្សេងៗ របស់យោធពលខេមរភូមិន្ទទេ ។ តែអ្នកបើកបរយន្តហោះត្រូវដាក់រាល់សញ្ញាដែលមាន (ប៉ាក់ភ្ជាប់ និង សក្តិ) ។

៧– ចំពោះទង់កងយោធពលខេមរភូមិន្ទ គ្រប់បណ្តាថ្នាក់ ត្រូវរក្សាទុកកន្លែងដែលមានសុវត្ថិភាពថ្លៃថ្នូរ និង ការពារយ៉ាងហ្មត់ចត់បំផុត ។ ក្នុងរយៈពេលមួយឆមាស ត្រូវប្រារព្ធពិធីសច្ចាប្រណិធាន ចំពោះមុខទង់របស់ខ្លួនម្តង ។ ពេលយកចេញមកក្រៅ ត្រូវធ្វើអោយបានត្រឹមត្រូវតាមភូមិបទយោធា ។

–នាយទាហាន នាយទាហានរង និង ពលទាហានទូទាំងកងយោធពលខេមរភូមិន្ទ ត្រូវស្លៀកឯកសណ្ឋានតាមការកំណត់ខាងលើ ក្នុងអនុក្រឹត្យនេះ ។ ចំពោះ បុគ្គលណាមួយដែលមិនបានស្លៀកពាក់អោយបានគ្រប់គ្រាន់តាមការ

កំណត់នេះ ត្រូវចាត់ទុកជាការល្មើសនិងវិន័យរបស់កងយោធពលខេមរភូមិន្ទ ។

–ចំពោះការផលិត ត្រូវធ្វើតាមការកំណត់របស់អនុក្រឹត្យនេះ និងមានគុណភាពខ្ពស់ ។

–ក្នុងករណីមានការជំនួយពីបណ្ដាលប្រទេសជាមិត្ត អំពីឯកសណ្ឋាន ឬ យោធបរិក្ខារផ្សេងៗ ហើយខុសពីការកំណត់នេះ អាចប្រើប្រាស់បាន លុះត្រាតែមានការអនុញ្ញាតជាផ្លូវការពីក្រសួងការពារជាតិ និងអគ្គសេនាធិការ នៃកងយោធពលខេមរភូមិន្ទ ។

មាត្រា ៩ : រាល់អនុក្រឹត្យណា ឬ សេចក្ដីសំរេច ដែលផ្ទុយពីអនុក្រឹត្យ ត្រូវទុកជានិរាករណ៍ ។

មាត្រា ១០ : សហរដ្ឋមន្ត្រី ទីស្ដីការរដ្ឋមន្ត្រី រដ្ឋមន្ត្រីក្រសួងការពារជាតិ អគ្គមេបញ្ជាការ និងអគ្គសេនាធិការនៃកងយោធពលខេមរភូមិន្ទ ត្រូវអនុវត្តន៍អនុក្រឹត្យនេះ ។

មាត្រា ១១ : អនុក្រឹត្យនេះចូលជាធរមាន ចាប់ពីថ្ងៃឡាយព្រះហស្ថ និងចុះហត្ថលេខាតទៅ ។

នាយករដ្ឋមន្ត្រីទី ១	**នាយករដ្ឋមន្ត្រីទី ២**
ព្រះហស្ថលេខានិងត្រា	**ហត្ថលេខា និងត្រា**
នរោត្តម រណឫទ្ធិ	**ហ៊ុន សែន**

* * *

រាជធានីភ្នំពេញ, ចុះថ្ងៃទី ២៣ ខែ មករា ឆ្នាំ ១៩៩៧

អនុក្រឹត្យលេខ ០៨ អនក្រ.បក

ស្ដីពី

ការដាក់ឲ្យប្រើបំណ្ណរតនាគារ

* * *

រាជរដ្ឋាភិបាល

–បានឃើញរដ្ឋធម្មនុញ្ញ នៃព្រះរាជាណាចក្រកម្ពុជា

- បានឃើញព្រះរាជក្រឹត្យ ចុះថ្ងៃទី ២៤ ខែកញ្ញា ឆ្នាំ ១៩៩៣ ស្តីពីការតែងតាំងនាយក រដ្ឋមន្ត្រីទី១ និង នាយករដ្ឋមន្ត្រីទី ២
- បានឃើញព្រះរាជក្រឹត្យ ចុះថ្ងៃទី ០១ ខែ វិច្ឆិកា ឆ្នាំ ១៩៩៣ ស្តីពីការតែងតាំងរាជរដ្ឋាភិបាលកម្ពុជា
- បានឃើញព្រះរាជក្រមលេខ ០១ នស ចុះថ្ងៃទី ២៨ ខែ ធ្នូ ឆ្នាំ ១៩៩៣ ស្តីពីប្រព័ន្ធហិរញ្ញវត្ថុ
- បានឃើញព្រះរាជក្រមលេខ ០២ នស/៩៤ ចុះថ្ងៃទី ២០ ខែ កក្កដា ឆ្នាំ ១៩៩៤ ស្តីពីការ រៀបចំ និង ការប្រព្រឹត្តិទៅនៃគណៈរដ្ឋមន្ត្រី
- បានឃើញព្រះរាជក្រឹត្យលេខ នស រកត ១០៩៤ ៨៣ ចុះថ្ងៃទី២៤ ខែតុលា ឆ្នាំ១៩៩៤ និង ព្រះរាជក្រឹត្យលេខ នស រកត ១០៩៤ ៩០ ចុះថ្ងៃទី ៣១ ខែ តុលា ឆ្នាំ ១៩៩៤ ស្តីពីការតែងតាំងសម្រួលសមាសភាពរាជរដ្ឋាភិបាលកម្ពុជា
- បានឃើញព្រះរាជក្រមលេខ ជស រកម ០៩៩៥ ០១ ចុះថ្ងៃទី ០១ ខែ កញ្ញា ឆ្នាំ ១៩៩៥ ស្តីពីការកែតំរូវនៃច្បាប់ហិរញ្ញវត្ថុ សំរាប់ការគ្រប់គ្រងឆ្នាំ ១៩៩៥
- បានឃើញរាជក្រមលេខ នស រកត ០១៩៦ ១៨ ចុះថ្ងៃទី ២៤ ខែ មករា ឆ្នាំ ១៩៩៦ ស្តីពីបង្កើតក្រសួងសេដ្ឋកិច្ច និង ហិរញ្ញវត្ថុ
- បានឃើញព្រះរាជក្រមលេខ ០៦៩៦/០៣ ចុះថ្ងៃទី១៧ ខែ មិថុនា ឆ្នាំ ១៩៩៦ ស្តីពីលក្ខន្តិកៈទូទៅ នៃសហគ្រាសសាធារណៈ
- បានឃើញសេចក្តីសំរេចរបស់រាជរដ្ឋាភិបាល លេខ ៨៦ សសរ ចុះថ្ងៃទី ១២ ខែ ធ្នូ ឆ្នាំ ១៩៩៥ ស្តីពីពីការបង្កើតគណៈកម្មការអន្តរក្រសួងទទួលបន្ទុកការរៀបចំ និង ការផ្សាព្វផ្សាយបណ្ណរតនាគារ
- តាមសំណើរបស់ទេសរដ្ឋមន្ត្រីទទួលបន្ទុកនីតិសម្បទា និង អភិវឌ្ឍន៍ និង ជារដ្ឋមន្ត្រី ក្រសួងសេដ្ឋកិច្ច និង ហិរញ្ញវត្ថុ
- គណៈរដ្ឋមន្ត្រីយល់ព្រមផង

សំរេច

មាត្រា ១ : បោះផ្សាយជាសាធារណៈនូវប័ណ្ណរតនាគារ សំរាប់ជំនួសអោយការខ្ចីប្រាក់រៀល ដែលមានរយៈពេលកំណត់ស្មើ ឬ តិចជាង ២ ឆ្នាំ ។

មាត្រា ២ : ចំនួនទឹកប្រាក់នៃការលក់ប័ណ្ណរតនាគារដែលដាក់អោយចរាចរ ត្រូវបញ្ចូលទៅក្នុងច្បាប់ហិរញ្ញវត្ថុប្រចាំឆ្នាំ ។

មាត្រា ៣ : ប័ណ្ណរតនាគារត្រូវបានបោះផ្សាយតាមរូបភាពពីគឺ :

- ប័ណ្ណរតនាគារជារូបមន្ត
- ប័ណ្ណរតនាគារគណនីចរន្ត

មាត្រា ៤ : ប័ណ្ណរតនាគារជារូបមន្ត គឺជាសិទ្ធិរូបីនៃឥណទេយ្យលើរតនាគារជាតិ ។ ប័ណ្ណនេះអាចផ្ទេរ លក់ បញ្ចាំ ឬ អោយខ្ចីទៅម្ចាស់ថ្មីប្រសិនជាប័ណ្ណគ្មាននាមចារឹក ឬ មួយដោយចារខ្នងប្រសិនជាប័ណ្ណមាននាមចារឹក ។

មាត្រា ៥ : ប័ណ្ណរតនាគារគណនីចរន្ត គឺជាសិទ្ធិអរូបីនៃឥណទេយ្យលើរតនាគារជាតិ ។ ប័ណ្ណនេះអាចផ្ទេរឈ្មោះ អាចលក់ អាចដាក់ជាការធានា ឬ អាចអោយខ្ចីដោយការបង្វែរពីគណនីមួយទៅគណនីផ្សេងទៀត ។

មាត្រា ៦ : ប័ណ្ណរតនាគារជារូបមន្ត គឺសំរាប់លក់ (ចុះឈ្មោះ) អោយឯកជន និង សហគ្រាស ឬ អង្គភាពផ្សេងៗទៀត ដែលមិនមែនជាអង្គភាពហិរញ្ញវត្ថុ ។
អត្រាការប្រាក់នៃការដាក់ផ្សាយ ត្រូវបានសំរេចដោយរដ្ឋមន្ត្រីក្រសួងសេដ្ឋកិច្ច និង ហិរញ្ញវត្ថុ ហើយអត្រាការប្រាក់នេះអាចមិនប្រែប្រួល និង ផ្តល់ការប្រាក់មុន ឬ ការប្រាក់កើនឡើង ។

មាត្រា ៧ : ប័ណ្ណរតនាគារជារូបមន្ត អាចទូទាត់សងវិញតាមតំលៃដែលបានកំណត់លើសន្លឹកប័ណ្ណដោយរតនាគារជាតិ ឬ ស្ថាប័នដែលមានការប្រគល់សិទ្ធិពីរតនាគារជាតិ ដោយគិតពីថ្ងៃផុតកំណត់រហូតដល់ ៣០ ឆ្នាំ ។

មាត្រា ៨ : ប័ណ្ណរតនាគារគណនីចរន្ត សំរាប់ការចុះឈ្មោះនៃធនាគារ នៃក្រុមហ៊ុនធានារ៉ាប់រង និង នៃអន្តរការីហិរញ្ញវត្ថុផ្សេងៗ ។

អត្រាការប្រាក់នៃការដាក់ផ្សាយ ត្រូវបានសំរេចដោយរដ្ឋមន្ត្រីក្រសួងសេដ្ឋកិច្ច និង ហិរញ្ញវត្ថុ ឬ តាមរយៈការដេញថ្លៃរបស់អ្នកចុះឈ្មោះទិញ ។

មាត្រា ៩ : រូបវន្តបុគ្គល និតិបុគ្គល ឬ អង្គភាពផ្សេងៗទៀតដែលមិនមែនជាអង្គភាពហិរញ្ញវត្ថុ អាចចុះឈ្មោះទិញប័ណ្ណរតនាគារតាមរយៈធនាគាររបស់ខ្លួន ។

មាត្រា ១០ : ធនាគារទាំងឡាយ អាចបង់ចូលក្នុងគណនីចរន្តនៃប័ណ្ណរតនាគាររបស់ខ្លួន នូវប័ណ្ណ តនាគារជារូបមន្តមិនទាន់ដុតកាលកំណត់ ដែលបានរក្សាទុកបន្ទាប់ពីការទិញទិញ ឬបន្ទាប់ជាក់ធានាពីអ្នកទិញទៀតទាត់ក្រៅពីចុះឈ្មោះទិញផ្ទាល់ ។

មាត្រា ១១ : រដ្ឋមន្ត្រីក្រសួងសេដ្ឋកិច្ច និង ហិរញ្ញវត្ថុ ត្រូវទទួលបន្ទុកគ្រប់គ្រងការដាក់ផ្សាយប័ណ្ណរតនាគារ ទោះបីស្ថិតក្នុងទ្រង់ទ្រាយណាក៏ដោយ ។ ផ្នែកសំណើរបស់គណៈកម្មការចំរុះអន្តរក្រសួង ទទួលបន្ទុករៀបចំដាក់ផ្សាយប័ណ្ណ រតនាគាររដ្ឋមន្ត្រីក្រសួងសេដ្ឋកិច្ច និង ហិរញ្ញវត្ថុ ត្រូវកំណត់ដោយប្រកាសនូវ បរិមាណដែលត្រូវដាក់ផ្សាយរយៈកាលវសាន្ត អត្រាការប្រាក់ ឬ ការដាក់អោយដេញថ្លៃ លក្ខខ័ណ្ឌនៃការចុះឈ្មោះទិញ និង លក្ខខ័ណ្ឌនៃការទូទាត់សងក៏ដូចជាលក្ខខ័ណ្ឌពិសេសផ្សេងៗ ទៀត ។

មាត្រា ១២ : ក្រសួងសេដ្ឋកិច្ច និង ហិរញ្ញវត្ថុ មានសិទ្ធិក្នុងការប្តូរ ឬ ប្រមូលទិញឡើងវិញពីលើទីផ្សារនូវប័ណ្ណរតនាគារ ដែលបានដាក់ផ្សាយហើយ ។ ការប្តូរ និង ការទិញមកវិញទាំងនេះត្រូវបានធ្វើដោយឥតបង្ខំ ចំពោះអ្នកដែលបានទិញប័ណ្ណ ។ ប័ណ្ណរតនា គារដែលបានប្តូរ ឬ បានទិញជាថ្មីឡើងវិញ ត្រូវបានលុបចោលភ្លាមនូវប័ណ្ណចាស់ដែលបានទូទាត់រួច ។ ការប្រាក់ដែលជាកាតព្វកិច្ចរបស់រដ្ឋលើប័ណ្ណប្តូរ ឬ ទិញមកវិញត្រូវបានទូទាត់តាមចំនួនប្រាក់ដែលបានជំពាក់រហូតដល់ថ្ងៃកំណត់ សង ឬ ថ្ងៃបានទិញមកវិញ ។

មាត្រា ១៣ : រាល់ការសំរេចរបស់រដ្ឋមន្ត្រីក្រសួងសេដ្ឋកិច្ច និង ហិរញ្ញវត្ថុ ស្តីពីការដាក់ផ្សាយនឹងការគ្រប់គ្រងប័ណ្ណរតនាគារ ត្រូវធ្វើការផ្សព្វផ្សាយជាសាធារណៈ ។

មាត្រា ១៤ : ធនាគារជាតិនៃកម្ពុជា ត្រូវទទួលបន្ទុកគ្រប់គ្រងគណនីចរន្តនៃប័ណ្ណរតនាគារ និង រៀបចំចាត់ចែងរាល់ពិធីដេញថ្លៃ ព្រមទាំងទទួលខុសត្រូវលើកិច្ចការនេះ ដើម្បីអោយដំណើរការបានល្អ ។

មាត្រា ១៥ : សហរដ្ឋមន្ត្រីទទួលបន្ទុកទីស្តីការគណៈរដ្ឋមន្ត្រី រដ្ឋមន្ត្រីក្រសួងសេដ្ឋកិច្ច និង ហិរញ្ញវត្ថុ ទេសាភិបាលធនាគារជាតិនៃកម្ពុជា និង ក្រសួងស្ថាប័នពាក់ព័ន្ធមានភារកិច្ចអនុវត្តអនុក្រឹត្យនេះ ចាប់ពីថ្ងៃឡាយព្រះហស្ថលេខា និងចុះហត្ថលេខាតទៅ ។

បានបង្គំទូលថ្វាយនិងជំរាបជូន	**នាយករដ្ឋមន្ត្រីទី១**	**នាយករដ្ឋមន្ត្រីទី២**
សម្តេចនាយករដ្ឋមន្ត្រីទី១ និងទី២	**ព្រះហស្ថលេខានិងត្រា**	**ហត្ថលេខានិងត្រា**
ទេសរដ្ឋមន្ត្រីទទួលបន្ទុកនីតិសម្បទា	**នរោត្តម រណឫទ្ធិ**	**ហ៊ុន សែន**

និង អភិវឌ្ឍន៍

និងជារដ្ឋមន្ត្រីក្រសួងសេដ្ឋកិច្ច និង ហិរញ្ញវត្ថុ

គាត ឈន់

* * *

រាជធានីភ្នំពេញ, ថ្ងៃទី ២២ ខែ មករា ឆ្នាំ ១៩៩៧

អនុក្រឹត្យលេខ ០៥ អនក្រ.គត

ស្តីពីការជូនមេដាយស្ថាបនាជាតិ

* * *

រាជរដ្ឋាភិបាល

– បានឃើញរដ្ឋធម្មនុញ្ញ នៃព្រះរាជាណាចក្រកម្ពុជា

–បានឃើញព្រះរាជក្រឹត្យរបស់ព្រះករុណាព្រះបាទសម្តេចព្រះ នរោត្តម សីហនុ វរ្ម័ន ព្រះមហាក្សត្រ នៃព្រះរាជាណាចក្រកម្ពុជា ចុះថ្ងៃ ទី ០១ ខែ វិច្ឆិកា ឆ្នាំ ១៩៩៣ ស្តីពីការ តែងតាំងរាជរដ្ឋាភិបាលកម្ពុជា

–បានឃើញច្បាប់ ស្តីពីការរៀបចំ និងការប្រព្រឹត្តទៅនៃគណៈរដ្ឋមន្ត្រី ដែលប្រកាសអោយប្រើដោយព្រះរាជក្រម ចុះថ្ងៃទី ២០ ខែ កក្កដា ឆ្នាំ ១៩៩៤

–បានឃើញព្រះរាជក្រឹត្យលេខ ជស/រកត/១០៩៥/០១ ចុះថ្ងៃ ០៥ ខែ តុលា ឆ្នាំ ១៩៩៥ ស្តីពីការបង្កើតនិងប្រើប្រាស់គ្រឿងឥស្សរិយយស នៃព្រះរាជាណាចក្រកម្ពុជា

–តាមសំណើរបស់រដ្ឋមន្ត្រីក្រសួងការពារជាតិ

សំរេច

មាត្រា ១ : ត្រូវបានប្រគល់មេដាយស្ថាបនាជាតិតាមលំដាប់ថ្នាក់ ជូនចំពោះសប្បុរសជន ដែលបានបរិច្ចាគធនធានផ្ទាល់ខ្លួន សំរាប់ចូលរួមជួយស្ថាបនាជាតិ និងឧបត្ថម្ភទ្រទ្រង់ដល់កងយោធពលខេមរភូមិន្ទ ដូចមានរាយនាមខាងក្រោម ៖

ក–មេដាយ មាស ស្ថាបនាជាតិ :

១–លោកជំទាវ ប៊ុន រ៉ានី ហ៊ុន សែន ទឹកប្រាក់ ២៨ .៦០០ ដុល្លារអាមេរិក

២–ឯកឧត្តម **ឆា ចឹម៉ាត់** ទឹកប្រាក់ ៤០.៦៨០ ដុល្លារអាមេរិក

៣–លោក **តុនី តាន់ឌីបម្រួណ** ទឹកប្រាក់២៤០.០០០ ដុល្លារអាមេរិក

(ឧបត្ថម្ភមួយខែ ២០.០០០ ក្នុងរយៈពេលមួយឆ្នាំ)

៤–លោក **អ៊ុក សារុន** ទឹកប្រាក់ ១៥០.០០០ ដុល្លារអាមេរិក

៥–លោក **គីម ម៉ារិន្ទា** ទឹកប្រាក់ ១៥០.០០០ ដុល្លារអាមេរិក

៦–លោក **ស៊ុតយាឌី តាន់នុចហ្សាយ៉ា** ទឹកប្រាក់ ១៣២.០០០ ដុល្លារអាមេរិក

៧–លោក **ឈាន អេងឈិន** ទឹកប្រាក ១២៨.០០០ ដុល្លារអាមេរិក

៨–លោក **ប៊ុន សំណាង** ទឹកប្រាក់ ១០០.០០០ ដុល្លារអាមេរិក

៩–លោក ឆយ ឃុករអន ទឹកប្រាក់ ៨០.០០០ ដុល្លារអាមេរិក

១០–លោក ហេង អ៊ិតសេង ទឹកប្រាក់ ៧០.០០០ ដុល្លារអាមេរិក

១១–លោក លឹម ស៊ុនហួត ទឹកបចាក់ ៦០.០០០ ដុល្លារអាមេរិក

១២–លោក លឹម ង៉ាក់យ៉ុង ទឹកប្រាក់ ៥៨.៨០០ ដុល្លារអាមេរិក

១៣–លោកឧកញ៉ា ថេង ប៊ុនម៉ា ទឹកប្រាក់ ៥២.០០០ ដុល្លារអាមេរិក

១៤–លោក អ៊ុង ចេងសុង ទឹកប្រាក់ ៤៨.៧២០ ដុល្លារអាមេរិក

១៥–លោក ថង ឆរត្នមី ទឹកប្រាក់ ៣៥.០០០ ដុល្លារអាមេរិក

១៦–លោក ឆយ ជីអ៊ុន ទឹកប្រាក់ ៣៤.០០០ ដុល្លារអាមេរិក

១៧–លោក តាយ យុង ទឹកប្រាក់ ៣២.០០០ ដុល្លារអាមេរិក

១៨–លោកឧកញ៉ា គង់ឡើង ទឹកប្រាក់ ៣១.៤២០ ដុល្លារអាមេរិក

១៩–លោកឧកញ៉ា សោរ សេរីមុន្នី ទឹកប្រាក់ ៣០.០០០ ដុល្លារអាមេរិក

២០–លោក ម៉ែន សារុន ទឹកប្រាក់ ៣០.០០០ ដុល្លារអាមេរិក

២១–លោក តែ គុង ទឹកប្រាក់ ២៦.០០០ ដុល្លារអាមេរិក

២២–លោកវររសេនីយ ហោ ស៊ុនឈាង ទិកប្រាក់ ២៤.៦៦០ ដុល្លារអាមេរិក

២៣–លោក ពិន ប៉ាច ទឹកប្រាក់ ២១.១៧៥ ដុល្លារអាមេរិក

២៤–លោកស្រី ឈុន ឈាង ទឹកប្រាក់ ២០.០០០ ដុល្លារអាមេរិក

២៥–លោក ហុង ឈន់មិញ ទឹកប្រាក់ ២០.០០០ ដុល្លារអាមេរិក

២៦–លោក ស៊ូប៉ាចៃ ទេវាពូជុង ទឹកប្រាក់ ១៨.៥០០ ដុល្លារអាមេរិក

២៧–លោក ឈៀង ចំរើន ទឹកប្រាក់ ១៦.០០០ ដុល្លារអាមេរិក

២៨–លោកស្រី យស សុគន្ធារី ទឹកប្រាក់ ១៦.០០០ ដុល្លារអាមេរិក

២៩–លោក សោរ មុនីរស្មី ទឹកប្រាក់ ២៣.៧៥០ ដុល្លារអាមេរិក

៣០–លោក ខង់ គុយ ទឹកប្រាក់ ១២.៦០០ ដុល្លារអាមេរិក

៣១–លោកទេជ្ជបណ្ឌិត សែ មីងឃួ ទឹកប្រាក់ ១២.៣៥០ ដុល្លារអាមេរិក

៣២-ក្រុមហ៊ុនសម្បទានិកអាកាសយានដ្ឋានពោធិ៍ចិនតុងទឹកប្រាក់ ១០.០០០ ដុល្លារអាមេរិក

៣៣-លោក ហេង ស្រួន ទឹកប្រាក់ ១០.០០០ ដុល្លារអាមេរិក

៣៤-លោក គួច គាន់ឌីហប្បូលន្ទ ទឹកប្រាក់ ១០.០០០ ដុល្លារអាមេរិក

(ឧបត្ថម្ភដោយភូមិភាគទី ៥)

ខ-មេដាយ ប្រាក់ស្ថាបនាជាតិ

១ -លោក ជំទាវ តៅ គៀន ឡេងឆាញ់ ទឹកប្រាក់ ៧.៦០០ ដុល្លារអាមេរិក

២-លោក ហេង ប៊ុនថា ទឹកប្រាក់ ៩.២០០ ដុល្លារអាមេរិក

៣-លោកឧកញ៉ា ឡាយ ខឹ ទឹកប្រាក់ ៨.៩០០ ដុល្លារអាមេរិក

៤-លោក យស់ ម៉ឺន ទឹកប្រាក់ ៨.០០០ ដុល្លារអាមេរិក

៥-លោក ម៉ាត សារី ទឹកប្រាក់ ៦.០០០ ដុល្លារអាមេរិក

៦-ក្រុមហ៊ុនភូមិខ្មែរ ទឹកប្រាក់ ៥.០០០ ដុល្លារអាមេរិក

គ-មេដាយសំរិទ្ធស្ថាបនាជាតិ :

១-ឯកឧត្តម ពៅ សិទ្ធ ទឹកប្រាក់ ៣.២២៥ ដុល្លារអាមេរិក

២-លោកឧត្តមសេនីយត្រី ណាត សុវត្ថិ ទឹកប្រាក់ ៣.០០០ ដុល្លារអាមេរិក

៣-លោក ឧត្តមសេនីយត្រី ម៉ក់ សារុន ទឹកប្រាក់ ២.៥០០ ដុល្លារអាមេរិក

៤-លោក ឧត្តមសេនីយត្រី យឹម សារិ ទឹកប្រាក់ ២.៣៦០ ដុល្លារអាមេរិក

៥-លោក អៀប អេងហុង ទឹកប្រាក់ ៣.០០០ ដុល្លារអាមេរិក

៦-លោក អ៊ុំ ឆែ អ្នកស្រី ម៉ានី ទឹកប្រាក់ ២.១៨០ ដុល្លារអាមេរិក

៧-លោកវរសេនីយឯក អ៊ុំ សារ ទឹកប្រាក់ ១.៧០០ ដុល្លារអាមេរិក

៨-លោក វរសេនីយ គៀង គីមរោន ទឹកប្រាក់ ១.៨០០ ដុល្លារអាមេរិក

៩-លោក ជា សឿន ទឹកប្រាក់ ១.៨០០ ដុល្លារអាមេរិក

១០-លោក តាន ឈានស៊ុន ទឹកប្រាក់ ១.៧០០ ដុល្លារអាមេរិក

១១-លោកស្រីវរសេនីយត្រី ឈឹម ម៉ារីណា ទឹកប្រាក់ ១.០០០ ដុល្លារអាមេរិក

១២-លោក ណារ៉ុង គាន់ជាក់ស៊ុំទឹកប្រាក់ ១.០០០ ដុល្លារអាមេរិក

១៣_លោក **ឃួន ហយ** ទឹកប្រាក់ ១.០០០ ដុល្លារអាមេរិក

១៤_លោក **ទង់ សិនមិញ** ទឹកប្រាក់ ១.០០០ ដុល្លារអាមេរិក

មាត្រា ២ : សហរដ្ឋមន្ត្រីទទួលបន្ទុកទីស្តីការគណៈរដ្ឋមន្ត្រី និង សហរដ្ឋមន្ត្រីក្រសួងការពារជាតិត្រូវអនុវត្តអនុក្រឹត្យនេះ អោយទទួលបានលទ្ធផលល្អ ។

នាយករដ្ឋមន្ត្រីទី១ នាយករដ្ឋមន្ត្រីទី២

ព្រះហស្តលេខានិងត្រា ហត្ថលេខានិងត្រា

នរោត្តម រណឫទ្ធិ ហ៊ុន សែន

* * *

III- ការងារបណ្តាក្រសួង

១- ទីស្តីការរដ្ឋមន្ត្រីក្រសួងសេដ្ឋកិច្ច និង ហិរញ្ញវត្ថុ

ប្រកាស

រាជធានីភ្នំពេញ, ថ្ងៃទី ខែ ឆ្នាំ ១៩៩៧.

ប្រកាសលេខ ០១៤ ប្រក.សហវ.រជ

ស្តីពី

ការកំរិតកំណត់ចំនួនទឹកប្រាក់ចំណូលរបស់រដ្ឋដែលគ្មាក់ងារបើកផ្តល់ ឬ អង្គភាពនីមួយៗអាចរក្សាទុកនៅក្នុងបេឡារបស់ខ្លួន

ទេសរដ្ឋមន្ត្រី

រដ្ឋមន្ត្រីក្រសួងសេដ្ឋកិច្ច និង ហិរញ្ញវត្ថុ

- បានឃើញរដ្ឋធម្មនុញ្ញនៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រឹត្យរបស់ព្រះករុណាបាទសម្តេចព្រះនរោត្តម សីហនុវរ្ម័ន ព្រះមហាក្សត្រ នៃព្រះរាជាណាចក្រកម្ពុជា ចុះថ្ងៃទី ០១ ខែ វិច្ឆិកា ឆ្នាំ ១៩៩៣ ស្តីពីការតែងតាំងគណៈរដ្ឋមន្ត្រី នៃព្រះរាជាណាចក្រកម្ពុជា

- បានឃើញព្រះរាជក្រឹត្យលេខ នស រកត ១០៩៤ ៨៣ ចុះថ្ងៃទី ២៤ ខែ តុលា ឆ្នាំ ១៩៩៤ ស្តីពីការកែសំរួលសមាសភាពរាជរដ្ឋាភិបាល
- បានឃើញច្បាប់ ស្តីពីការបង្កើតក្រសួងសេដ្ឋកិច្ច និង ហិរញ្ញវត្ថុ ដែលប្រកាសអោយប្រើប្រាស់ដោយព្រះរាជក្រម នស រកម ០១៩៦ ១៨ ចុះថ្ងៃទី ២៤ ខែ មេសា ឆ្នាំ ១៩៩៦
- បានឃើញច្បាប់ស្តីពីប្រព័ន្ធហិរញ្ញវត្ថុ
ដែលប្រកាសអោយប្រើដោយព្រះរាជក្រមលេខ០១ នស ចុះថ្ងៃទី ២៨ ខែ ធ្នូ ឆ្នាំ ១៩៩៣
- បានឃើញច្បាប់ហិរញ្ញវត្ថុ សំរាប់ការគ្រប់គ្រងឆ្នាំ ១៩៩៦ ដែលប្រកាសអោយប្រើដោយព្រះ រាជក្រមលេខ នស រកម ១២៩៥ ០៧ ចុះថ្ងៃទី ៣១ ខែ ធ្នូ ឆ្នាំ ១៩៩៥
- បានឃើញអនុក្រឹត្យលេខ ៨២ អនក្រ បក ចុះថ្ងៃទី ១៦ ខែ វិច្ឆិកា ឆ្នាំ ១៩៩៥ ស្តីពីបទបញ្ញត្តទូទៅនៃគណនេយ្យសាធារណៈ
- បានឃើញប្រកាសក្រសួងលេខ ០០៨ ប្រក.សហវ ចុះថ្ងៃទី ២៣ ខែ វិច្ឆិកា ឆ្នាំ ១៩៩៤ ស្តីពីការជំរះបញ្ជីការទូទាត់ប្រាក់ចំណូល និង ចំណាយ
- បានឃើញការចាំបាច់នៃការងាររបស់ក្រសួងសេដ្ឋកិច្ច និង ហិរញ្ញវត្ថុ

សំរេច

ប្រការ ១ : មន្ត្រីរាជការដែលមានតួនាទីជាគណនេយ្យករ រដ្ឋបាលហិរញ្ញវត្ថុ (គយ–ពន្ធដារ) រដ្ឋទេយ្យករ ចំណូលដែលជាអ្នកប្រមូលប្រាក់ចំណូលចូលថវិការដ្ឋ ត្រូវយកប្រាក់ចំណូលដែលប្រមូលបានទៅបង់ទាំងស្រុងចូលរតនាគារជាតិជាទៀតទាត់ ចាំបាច់ទៅតាមប្រតិទិនដែលបានកំណត់ដោយក្រសួង ឬ អង្គភាពនិមួយៗ និង នៅពេលដែលប្រាក់ចំណូលមានទំហំលើសពីការកំរិតកំណត់ ។

ប្រការ ២ : ចំនួនទឹកប្រាក់ដែលភ្នាក់ងារ ឬ អង្គភាពនិមួយៗអាចរក្សាទុកបាននៅក្នុងបេឡារបស់ខ្លួន ត្រូវបានកំរិតកំណត់ដូចខាងក្រោមនេះ ។

\+ ចំពោះគណនេយ្យកររដ្ឋបាលហិរញ្ញវត្ថុ

– នៅរាជធានីភ្នំពេញ មិនអោយលើសពី (៥.០០០.០០០៛) ប្រាំលានរៀល

– នៅតាមបណ្តាខេត្ត–ក្រុងមិនអោយលើសពី (២.០០០.០០០៛) ពីរលានរៀល

\+ ចំពោះរដ្ឋទេយ្យករចំណូលមិនអោយលើសពី (២.០០០.០០០៛) ពីរលានរៀល

ប្រការ ៣ : សេចក្តីសំរេចទាំងឡាយណាដែលមានខ្លឹមសារផ្ទុយទៅនឹងប្រកាសនេះ ត្រូវទុកជានិរាករណ៍ ។

ប្រការ ៤ : អគ្គនាយក នាយកខុទ្ទកាល័យ ប្រធានមន្ទីរ ប្រធានរតនាគារជាតិ ប្រធាននាយកដ្ឋានពន្ធដារ ទីចាត់ការគយ–រដ្ឋាករ និង គ្រប់អង្គភាពពាក់ព័ន្ធ ត្រូវទទួលបន្ទុកអនុវត្តប្រកាសនេះ ។

ប្រការ ៥ : ប្រកាសនេះ មានប្រសិទ្ធិភាពអនុវត្ត ចាប់តាំងពីថ្ងៃទីចុះហត្ថលេខាតទៅ ។

រដ្ឋមន្ត្រី

ហត្ថលេខានិងត្រា

គាត ឈន់

* * *

២– ទីស្តីការរដ្ឋមន្ត្រីក្រសួងឧស្សាហកម្ម រ៉ែ និង ថាមពល

ប្រកាស

ប្រកាសលេខ ២៨ ឧក.ប្រក ចុះថ្ងៃទី ១៦ ខែ មករា ឆ្នាំ ១៩៩៧

ប្រការ ១ : អនុញ្ញាតអោយលោក **តាន់ សេងម៉ា** ជនជាតិខ្មែរ សញ្ញាតិកម្ពុជា កាន់អត្តសញ្ញាណប័ណ្ណ លេខ ២៩៣២៦៣ ភព. ចុះថ្ងៃទី ០៥–៧–៩០ អាស័យដ្ឋានបច្ចុប្បន្ន ផ្លូវជាតិលេខ ៥ ក្រុមទី ១១ សង្កាត់ ទួលសង្កែ ខណ្ឌឫស្សីកែវ រាជធានីភ្នំពេញ បន្តដំណើរការឧស្សាហកម្មតូចផលិតទឹកកកដើម នៅក្នុងទីតាំងផ្លូវជាតិលេខ ៥ ក្រុមទី១១ សង្កាត់ទួលសង្កែ ខណ្ឌឫស្សីកែវ រាជធានីភ្នំពេញ ។

ប្រការ ២ : ប្រកាសនេះមានតំលៃក្នុងរយៈពេល ៣ ឆ្នាំ ។ ផុតកំណត់ពេលនេះ ម្ចាស់មូលដ្ឋានត្រូវធ្វើពាក្យសុំការអនុញ្ញាតបន្តផលិតកម្មរបស់ខ្លួនឡើងវិញ ។ ក្នុងករណីប្រព្រឹត្តល្មើសច្បាប់ ផលិតផលគ្មានគុណភាពប៉ះពាល់ដល់សុខភាពប្រជារាស្ត្រ ឬបង្កអោយមានការប៉ះពាល់ដល់បរិស្ថាន ប្រកាសនេះនឹងត្រូវដកហូតវិញ ដោយគ្មានសំណងឡើយ ។

* * *

ប្រកាសលេខ ២៩ ឧក.ប្រក ចុះថ្ងៃទី ១៦ ខែ មករា ឆ្នាំ ១៩៩៧

ប្រការ ១ : អនុញ្ញាតអោយអ្នកស្រី **លី សុខខេង** ជនជាតិខ្មែរ សញ្ជាតិកម្ពុជា កាន់អត្តសញ្ញាណប័ណ្ណ លេខ ១៩៥៥៣៣ ភព. ចុះថ្ងៃទី ២៩_៨_៨៨ អាស័យដ្ឋានបច្ចុប្បន្ន ផ្ទះលេខ ៣៥៦ ផ្លូវលេខ ១៦៣ សង្កាត់អូឡាំពិក ខណ្ឌចំការមន រាជធានីភ្នំពេញ បន្តដំណើរការយានដ្ឋានផ្លួសផុលនិងលាងរថយន្តនៅក្នុងទីតាំងសង្កាត់ រាជធានីភ្នំពេញ ផ្ទះលេខ ៣៥៦ ផ្លូវលេខ ១៦៣ សង្កាត់អូឡាំពិក ខណ្ឌចំការមន រាជធានីភ្នំពេញ ។

ប្រការ ២ : ប្រកាសនេះមានតំលៃក្នុងរយៈពេល ៣ ឆ្នាំ ។ ផុតកំណត់ពេលនេះ ម្ចាស់មូលដ្ឋានត្រូវធ្វើពាក្យសុំការអនុញ្ញាតបន្តផលិតកម្មរបស់ខ្លួនឡើងវិញ ។ ក្នុងករណីប្រព្រឹត្តល្មើសច្បាប់ ផលិតផលគ្មានគុណភាពប៉ះពាល់ដល់សុខភាពប្រជារាស្ត្រ ឬបង្កអោយមានការប៉ះពាល់ដល់បរិស្ថាន ប្រកាសនេះនឹងត្រូវដកហូតវិញដោយគ្មានសំណងឡើយ ។

* * *

ប្រកាសលេខ ៥៣ ឧក.ប្រក ចុះថ្ងៃទី ១៧ ខែ មករា ឆ្នាំ ១៩៩៧

ប្រការ ១ : អនុញ្ញាតអោយអ្នកស្រី **អាន់ សំឡាន** ជនជាតិខ្មែរ សញ្ជាតិកម្ពុជា កាន់អត្តសញ្ញាណប័ណ្ណ លេខ ០២៤៩២៥ ក.ក៤ ចុះថ្ងៃទី ១០_១០_៩១ អាស័យដ្ឋានបច្ចុប្បន្ន ក្រុមទី ៧ ភូមិកោះស្តេច ឃុំកោះស្តេច ស្រុកគីរីសាគរ ខេត្តកោះកុង

បើកដំណើរការឧស្សាហកម្មតូច ផលិតទឹកកកដើម នៅក្នុងទីតាំងដូចអាស័យដ្ឋានខាងលើ ។

ប្រការ ២ : ប្រកាសនេះមានតំលៃក្នុងរយៈពេល ៣ ឆ្នាំ ។ ផុតកំណត់ពេលនេះ ម្ចាស់មូលដ្ឋានត្រូវធ្វើពាក្យសុំការអនុញ្ញាតបន្តផលិតកម្មរបស់ខ្លួនឡើងវិញ ។ ក្នុងករណីប្រព្រឹត្តល្មើសច្បាប់ ផលិតផលគ្មានគុណភាពប៉ះពាល់ដល់សុខភាពប្រជារាស្ត្រ ឬបង្កអោយមានការប៉ះពាល់ដល់បរិស្ថាន ប្រកាសនេះនឹងត្រូវដកហូតវិញដោយគ្មានសំណងឡើយ ។

* * *

ប្រកាសលេខ ៥៩ ឧក.ប្រក ចុះថ្ងៃទី ២១ ខែ មករា ឆ្នាំ ១៩៩៧

ប្រការ ១ : អនុញ្ញាតអោយលោក **ហុក ទ៊ា** ជនជាតិខ្មែរ សញ្ជាតិកម្ពុជា កាន់អត្តសញ្ញាណប័ណ្ណលេខ ៣៥៩៩៣០ កណ. ចុះថ្ងៃទី ២០_១០_៩៣ អាស័យដ្ឋានបច្ចុប្បន្ន ភូមិស្វាយជ្រុំ ឃុំស្វាយជ្រុំ ស្រុកមុខកំពូល ខេត្តកណ្តាល បន្តដំណើរការ ឡផលិតឥដ្ឋ-ក្បឿង នៅក្នុងទីតាំង ភូមិស្វាយជ្រុំ ឃុំព្រែកដំបង ស្រុកមុខកំពូល ខេត្តកណ្តាល ។

ប្រការ ២ : ប្រកាសនេះមានតំលៃក្នុងរយៈពេល ៣ ឆ្នាំ ។ ផុតកំណត់ពេលនេះ ម្ចាស់មូលដ្ឋានត្រូវធ្វើពាក្យសុំការអនុញ្ញាតបន្តផលិតកម្មរបស់ខ្លួនឡើងវិញ ។ ក្នុងករណីប្រព្រឹត្តល្មើសច្បាប់ ឬបង្កអោយមានការប៉ះពាល់ដល់បរិស្ថាន ប្រកាសនេះនឹងត្រូវដកហូតវិញដោយគ្មានសំណងឡើយ ។

* * *

ប្រកាសលេខ ៦០ ឧក.ប្រក ចុះថ្ងៃទី ២១ ខែ មករា ឆ្នាំ ១៩៩៧

ប្រការ ១ : អនុញ្ញាតអោយអ្នកស្រី **ទ៉ែ ស៊ូ** ជនជាតិខ្មែរ សញ្ជាតិកម្ពុជា កាន់អត្តសញ្ញាណប័ណ្ណលេខ ២២៨៧៦៣ ភព. ចុះថ្ងៃទី ២៧_៥_៨៩ អាស័យដ្ឋានបច្ចុប្បន្ន ផ្ទះលេខ ៦៥អឺ០ ផ្លូវលេខ ១៦៤ សង្កាត់ផ្សារ អូរឫស្សីទី ២ ខណ្ឌ ៧មករា

រាជធានីភ្នំពេញ បន្តដំណើរការសិប្បកម្មផលិតមីសរសៃ នៅក្នុងទីតាំងផ្ទះលេខ ៦១អឺ០ ផ្លូវលេខ ១៦៤ សង្កាត់អូរឫស្សីទី ២ ខ័ណ្ឌ ៧មករា រាជធានីភ្នំពេញ ។

ប្រការ ២ : ប្រកាសនេះមានតំលៃក្នុងរយៈពេល ៣ ឆ្នាំ ។ ផុតកំណត់ពេលនេះ ម្ចាស់មូលដ្ឋានត្រូវធ្វើពាក្យសុំការអនុញ្ញាតបន្តផលិតកម្មរបស់ខ្លួនឡើងវិញ ។ ក្នុងករណីប្រព្រឹត្តល្មើសច្បាប់ ផលិតផលគ្មានគុណភាពប៉ះពាល់ដល់សុខភាពប្រជារាស្ត្រ ឬបង្កអោយមានការប៉ះពាល់ដល់បរិស្ថាន ប្រកាសនេះនឹងត្រូវដកហូតវិញដោយគ្មានសំណងឡើយ ។

* * *

ប្រកាសលេខ ៦១ ឧក.ប្រក ចុះថ្ងៃទី ២១ ខែ មករា ឆ្នាំ ១៩៩៧

ប្រការ ១ : អនុញ្ញាតអោយលោក **ហុក សេង** ជនជាតិខ្មែរ សញ្ជាតិកម្ពុជា កាន់អត្តសញ្ញាណប័ណ្ណ លេខ ០៩២៤៧២ កណ. ចុះថ្ងៃទី ០៤_៥_៨៧ អាស័យដ្ឋានបច្ចុប្បន្ន ភូមិក្តីចាស់ ឃុំចាក់ខែង ស្រុកមុខកំពូល ខេត្តកណ្តាល បន្តដំណើរការឡផលិតឥដ្ឋ-ក្បឿង នៅក្នុងទីតាំង ភូមិក្តីចាស់ ឃុំចាក់ខែង ស្រុកមុខកំពូល ខេត្តកណ្តាល ។

ប្រការ ២ : ប្រកាសនេះមានតំលៃក្នុងរយៈពេល ៣ ឆ្នាំ ។ ផុតកំណត់ពេលនេះ ម្ចាស់មូលដ្ឋានត្រូវធ្វើពាក្យសុំការអនុញ្ញាតបន្តផលិតកម្មរបស់ខ្លួនឡើងវិញ ។ ក្នុងករណីប្រព្រឹត្តល្មើសច្បាប់ ឬ បង្កអោយមានការប៉ះពាល់ដល់បរិស្ថាន ប្រកាសនេះនឹងត្រូវដកហូតវិញដោយគ្មានសំណងឡើយ ។

* * *

ប្រកាសលេខ ៦២ ឧក.ប្រក ចុះថ្ងៃទី ២១ ខែ មករា ឆ្នាំ ១៩៩៧

ប្រការ ១ : អនុញ្ញាតអោយលោក **ឌូ ឈាង** ជនជាតិខ្មែរ សញ្ជាតិកម្ពុជា កាន់អត្តសញ្ញាណប័ណ្ណលេខ ២៣១៣៣៨ កណ. ចុះថ្ងៃទី ០៤_០២_៨៩ អាស័យដ្ឋានបច្ចុប្បន្ន ភូមិក្នុងព្រែក ឃុំព្រែកតយ ស្រុកស្អាង ខេត្តកណ្តាល បន្តដំណើរ

ការឡផលិតឥដ្ឋ-ក្បឿង នៅក្នុងទីតាំង ភូមិ ក្អមព្រែក ឃុំព្រែកគយ ស្រុកស្អាង ខេត្តកណ្ដាល ។

ប្រការ ២ : ប្រកាសនេះមានតំលៃក្នុងរយៈពេល ៣ ឆ្នាំ ។ ផុតកំណត់ពេលនេះ ម្ចាស់មូលដ្ឋានត្រូវធ្វើពាក្យសុំការអនុញ្ញាតបន្តផលិតកម្មរបស់ខ្លួនឡើងវិញ ។ ក្នុងករណីប្រព្រឹត្តល្មើសច្បាប់ ឬ បង្កអោយមានការប៉ះពាល់ដល់បរិស្ថាន ប្រកាសនេះនឹងត្រូវដកហូតវិញដោយគ្មានសំណងឡើយ ។

* * *

ប្រកាសលេខ ៦៣ឧក.ប្រក ចុះថ្ងៃទី ២១ ខែ មករា ឆ្នាំ ១៩៩៧

ប្រការ ១ : អនុញ្ញាតអោយលោក **ស៊ុម ស៊ុយតាំង** ជនជាតិខ្មែរ សញ្ជាតិកម្ពុជា កាន់អត្តសញ្ញាណប័ណ្ណ លេខ ០៧១៤៨៣ ភព. ចុះថ្ងៃទី ២៥_០២_៨៥ អាស័យដ្ឋានបច្ចុប្បន្ន ផ្ទះលេខ ១៩៤ ផ្លូវលេខ ៩៣ ខ័ណ្ឌ ៧មករា រាជធានីភ្នំពេញ បន្តដំណើរការរោងម៉ាស៊ីនផលិតទឹកកកដើម នៅក្នុងទីតាំង ភូមិជ្រោយ អំពិល ឃុំក្បាលកោះ ស្រុកកៀនស្វាយ ខេត្តកណ្ដាល ។

ប្រការ ២ : ប្រកាសនេះមានតំលៃក្នុងរយៈពេល ៣ ឆ្នាំ ។ ផុតកំណត់ពេលនេះ ម្ចាស់មូលដ្ឋានត្រូវធ្វើពាក្យសុំការអនុញ្ញាតបន្តផលិតកម្មរបស់ខ្លួនឡើងវិញ ។ ក្នុងករណីប្រព្រឹត្តល្មើសច្បាប់ ផលិតផលគ្មានគុណភាពប៉ះពាល់ដល់សុខភាពប្រជារាស្ត្រ ឬ បង្កអោយមានការប៉ះពាល់ដល់បរិស្ថាន ប្រកាសនេះនឹងត្រូវដកហូតវិញដោយគ្មានសំណងឡើយ ។

* * *

ប្រកាសលេខ ៦៤ ឧក.ប្រក ចុះថ្ងៃទី ២១ ខែ មករា ឆ្នាំ ១៩៩៧

ប្រការ ១ : អនុញ្ញាតអោយលោក **លី ហេង** ជនជាតិខ្មែរ សញ្ជាតិកម្ពុជា កាន់អត្តសញ្ញាណប័ណ្ណ លេខ ៣១៤៧៤៣ ភព. ចុះថ្ងៃទី ២២_៥_៩១ អាស័យដ្ឋានបច្ចុប្បន្ន ភូមិ ខ្សុំ ឃុំបន្ទាយដែក ស្រុកកៀនស្វាយ ខេត្តកណ្ដាល បន្តដំណើរ

ការឡផលិតឥដ្ឋ-ក្បឿង នៅក្នុងទីតាំង ភូមិ ខ្ញុំ ឃុំបន្ទាយដែក ស្រុកកៀនស្វាយ ខេត្តកណ្ដាល ។

ប្រការ ២ : ប្រកាសនេះមានតំលៃក្នុងរយៈពេល ៣ ឆ្នាំ ។ ផុតកំណត់ពេលនេះ ម្ចាស់មូលដ្ឋានត្រូវធ្វើពាក្យសុំការអនុញ្ញាតបន្តផលិតកម្មរបស់ខ្លួនឡើងវិញ ។ ក្នុងករណីប្រព្រឹត្តល្មើសច្បាប់ ឬ បង្កអោយមានការប៉ះពាល់ដល់បរិស្ថាន ប្រកាសនេះនឹងត្រូវដកហូតវិញដោយគ្មានសំណងឡើយ ។

* * *

ប្រកាសលេខ ៦៥ ឧក.ប្រក ចុះថ្ងៃទី ២១ ខែ មករា ឆ្នាំ ១៩៩៧

ប្រការ ១ : អនុញ្ញាតអោយលោក **ស៊ឹម ស៊ុយតាំង** ជនជាតិខ្មែរ សញ្ជាតិកម្ពុជា កាន់អត្តសញ្ញាណប័ណ្ណ លេខ ០៧១៤៨៣ ភព. ចុះថ្ងៃទី ២៥_០២_៨៥ អាស័យដ្ឋានបច្ចុប្បន្ន ផ្ទះលេខ ១៩៤ ផ្លូវលេខ ៩៣ ខ័ណ្ឌ ៧មករា រាជធានីភ្នំពេញ បន្តដំណើរការឡផលិតឥដ្ឋ-ក្បឿង នៅក្នុងទីតាំង ភូមិជ្រោយអំពិល ឃុំក្បាលកោះ ស្រុកកៀនស្វាយ ខេត្តកណ្ដាល ។

ប្រការ ២ : ប្រកាសនេះមានតំលៃក្នុងរយៈពេល ៣ ឆ្នាំ ។ ផុតកំណត់ពេលនេះ ម្ចាស់មូលដ្ឋានត្រូវធ្វើពាក្យសុំការអនុញ្ញាតបន្តផលិតកម្មរបស់ខ្លួនឡើងវិញ ។ ក្នុងករណីប្រព្រឹត្តល្មើសច្បាប់ ផលិតផលគ្មានគុណភាពប៉ះពាល់ដល់សុខភាពប្រជារាស្ត្រ ឬ បង្កអោយមានការប៉ះពាល់ដល់បរិស្ថាន ប្រកាសនេះនឹងត្រូវដកហូតវិញដោយគ្មានសំណងឡើយ ។

* * *

ប្រកាសលេខ ៦៦ ឧក.ប្រក ចុះថ្ងៃទី ២១ ខែ មករា ឆ្នាំ ១៩៩៧

ប្រការ ១ : អនុញ្ញាតអោយលោក **វ៉ាន់ សារ** ជនជាតិខ្មែរ សញ្ជាតិកម្ពុជា កាន់អត្តសញ្ញាណប័ណ្ណលេខ ០៥៩៩៨០ កណ. ចុះថ្ងៃទី ២១_១១_៨៩ អាស័យដ្ឋានបច្ចុប្បន្ន ភូមិពពែ ឃុំជ្រៃលាស់ ស្រុកពញាឮ ខេត្តកណ្ដាល បន្តដំណើរការរោង ម៉ាស៊ីន

កិនស្រូវ កំលាំង ១៨សេះ នៅក្នុងទីតាំង ភូមិពពែ ឃុំជ្រៃលាស់ ស្រុកពញាឮ ខេត្តកណ្តាល ។

ប្រការ ២ : លោក រ៉ាន់ សា ត្រូវបន្តដំណើរការផលិតកម្ម-អាជីវកម្មលើទីតាំង ដូចបានកំណត់ក្នុងប្លង់ ដោយធានានូវទិន្នផលអង្ករលេខ ១ អោយបានយ៉ាងតិចបំផុត ៦៥ ភាគរយ ។

ប្រការ ៣ : ប្រកាសនេះមានតំលៃក្នុងរយៈពេល ៣ ឆ្នាំ ។ ផុតកំណត់ពេលនេះ ម្ចាស់មូលដ្ឋានត្រូវធ្វើពាក្យសុំការអនុញ្ញាតបន្តផលិតកម្មរបស់ខ្លួនឡើងវិញ ។ ក្នុងករណីប្រព្រឹត្តល្មើសច្បាប់ ឬ បង្កអោយមានការប៉ះពាល់ដល់បរិស្ថាន ប្រកាសនេះនឹងត្រូវដកហូតវិញដោយគ្មានសំណងឡើយ ។

* * *

ប្រកាសលេខ ៦៧ ឧក.ប្រក ចុះថ្ងៃទី ២១ ខែ មករា ឆ្នាំ ១៩៩៧

ប្រការ ១ : អនុញ្ញាតអោយលោក **សៀង ស៊្រុន** ជនជាតិខ្មែរ សញ្ជាតិកម្ពុជា កាន់អត្តសញ្ញាណប័ណ្ណលេខ ១៥៧០៧៣ កណ. ចុះថ្ងៃទី ២៩-១១-៨៩ អាស័យដ្ឋានបច្ចុប្បន្ន ភូមិត្បូងវត្ត ឃុំជ្រៃលាស់ ស្រុកពញាឮ ខេត្តកណ្តាល បន្តដំណើរការរោងម៉ាស៊ីនកិនស្រូវ កំលាំង ៤០សេះ នៅក្នុងទីតាំង ភូមិត្បូងវត្ត ឃុំជ្រៃលាស់ ស្រុកពញាឮ ខេត្តកណ្តាល ។

ប្រការ ២ : លោក **សៀង ស៊្រុន** ត្រូវបន្តដំណើរការផលិតកម្ម- អាជីវកម្មលើទីតាំងដូចបានកំណត់ក្នុងប្លង់ ដោយធានានូវទិន្នផលអង្ករលេខ ១ អោយបានយ៉ាងតិចបំផុត ៦៥ ភាគរយ ។

ប្រការ ៣ : ប្រកាសនេះមានតំលៃក្នុងរយៈពេល ៣ ឆ្នាំ ។ ផុតកំណត់ពេលនេះ ម្ចាស់មូលដ្ឋានត្រូវធ្វើពាក្យសុំការអនុញ្ញាតបន្តផលិតកម្មរបស់ខ្លួនឡើងវិញ ។ ក្នុងករណីប្រព្រឹត្តល្មើសច្បាប់ ឬ បង្កអោយមានការប៉ះពាល់ដល់បរិស្ថាន ប្រកាសនេះនឹងត្រូវដកហូតវិញដោយគ្មានសំណងឡើយ ។

* * *

ប្រកាសលេខ ៦៨ ជក.ប្រក ចុះថ្ងៃទី ២១ ខែ មករា ឆ្នាំ ១៩៩៧

ប្រការ ១ : អនុញ្ញាតអោយលោក **សុខ សាន** ជនជាតិខ្មែរ សញ្ជាតិកម្ពុជា ជាម្ចាស់សិប្បកម្ម ផលិតទឹកស៊ីអ៊ីវសញ្ញា "ភ្នំមាស " ដែលមានទីតាំងក្រុមទី ៥ ភូមិគោរដ្ឋាន ឃុំអូរអំពិល ស្រុកសិរីសោភ័ណ ខេត្តបន្ទាយមានជ័យ ។

ប្រការ ២ : លោក **សុខ សាន** ត្រូវបានអនុញ្ញាតអោយផលិតបន្ថែមនូវមុខផលិតផល ទឹកស៊ីអ៊ីវសញ្ញា " ផ្កាកូឡាប " ស្របតាមគំរូសញ្ញាសំគាល់ ដែលបានតំកល់ទុកនៅក្រសួងឧស្សាហកម្ម រ៉ែ និង ថាមពល ។

ប្រការ ៣ : រាល់ប្រការដែលមានចែងក្នុងប្រកាសលេខ ៦២៨ ជក.ប្រក. ថ្ងៃទី ០៤ ខែវិច្ឆិកា ឆ្នាំ ១៩៩៦ នៅមានតំលៃជាធរមានបញ្ញត្តិដដែល ។

ប្រការ ៤ : ប្រធាននាយកដ្ឋានផែនការ ប្រធាននាយកដ្ឋានបច្ចេកទេស ប្រធានមន្ទីរវិទ្យាស្ថានក្រសួងឧស្សាហកម្ម រ៉ែ និង ថាមពល ប្រធានមន្ទីរឧស្សាហកម្ម រ៉ែ និងថាមពលខេត្តបន្ទាយមានជ័យ និង លោក **សុខ សាន** ត្រូវទទួលអនុវត្តប្រកាសនេះតាមមុខការរៀងៗ ខ្លួន ។

ប្រការ ៥ : ប្រកាសនេះ មានអានុភាពអនុវត្តិ ចាប់ពីថ្ងៃចុះហត្ថលេខាតទៅ ។

* * *

ប្រកាសលេខ ៦៩ ជក.ប្រក ចុះថ្ងៃទី ២១ ខែ មករា ឆ្នាំ ១៩៩៧

ប្រការ ១ : អនុញ្ញាតអោយលោក **អ៊ុំ សេងអាន** ជនជាតិខ្មែរ សញ្ជាតិកម្ពុជា កាន់អត្តសញ្ញាណប័ណ្ណលេខ ២០៥៩៧១ ភព. ចុះថ្ងៃទី ២៣–៣–៨៥ អាស័យដ្ឋានបច្ចុប្បន្ន ផ្ទះលេខ ៤៤EOZ ផ្លូវលេខ ២១៩ សង្កាត់ផ្សារដើមគរ ខ័ណ្ឌទួលគោក រាជធានីភ្នំពេញ បន្តដំណើរសិប្បកម្ម ផលិតស្វាបព្រា វែក អំពី

អាលុយ មិញ្ញូម " ៩៩៩ " នៅក្នុងទីតាំង ផ្ទះលេខ ៤៤EOZ ផ្លូវលេខ ២១៩ សង្កាត់ផ្សារដើមគរ ខ័ណ្ឌ ទួលគោក រាជធានីភ្នំពេញ ។

ប្រការ ២ : ប្រកាសនេះមានតំលៃក្នុងរយៈពេល ៣ ឆ្នាំ ។ ផុតកំណត់ពេលនេះ ម្ចាស់មូលដ្ឋានត្រូវធ្វើពាក្យសុំការអនុញ្ញាតបន្តផលិតកម្មរបស់ខ្លួនឡើងវិញ ។ ក្នុងករណីប្រព្រឹត្តល្មើសច្បាប់ ឬបង្កអោយមានការប៉ះពាល់ដល់បរិស្ថាន ប្រកាសនេះនឹងត្រូវដកហូតវិញដោយគ្មានសំណងឡើយ ។

* * *

ប្រកាសលេខ ៧០ ឧក.ប្រក ចុះថ្ងៃទី ២១ ខែ មករា ឆ្នាំ ១៩៩៧

ប្រការ ១ : អនុញ្ញាតអោយរោងជាងស្ពាន់ដែកដែលមានលោក **ឃិន ម៉ិល** ជនជាតិខ្មែរ សញ្ញាតិកម្ពុជា កាន់អត្តសញ្ញាណប័ណ្ណលេខ ២៣២៤៨៧ ភព. ចុះថ្ងៃទី ០៥-៥-៨៩ ជាប្រធាន អាស័យដ្ឋានបច្ចុប្បន្ន ផ្ទះលេខ ៦៧អឺ២ ផ្លូវលេខ ១០៧ សង្កាត់មនោរម្យ ខ័ណ្ឌ ៧មករា រាជធានីភ្នំពេញ បន្តដំណើរការផលិតកម្ម នៅក្នុងទីតាំង ផ្ទះសង់ថ្មី ផ្លូវលេខ ២៧១ ភូមិត្រពាំងឈូក សង្កាត់ទឹកថ្លា ខ័ណ្ឌ ឫស្សីកែវ រាជធានីភ្នំពេញ ។

ប្រការ ២ : ប្រកាសនេះមានតំលៃក្នុងរយៈពេល ៣ ឆ្នាំ ។ ផុតកំណត់ពេលនេះ ម្ចាស់មូលដ្ឋានត្រូវធ្វើពាក្យសុំការអនុញ្ញាតបន្តផលិតកម្មរបស់ខ្លួនឡើងវិញ ។ ក្នុងករណីប្រព្រឹត្តល្មើសច្បាប់ ផលិតផលគ្មានគុណ ភាពប៉ះពាល់ដល់សុខភាពប្រជារាស្ត្រ ឬបង្កអោយមានការប៉ះពាល់ដល់បរិស្ថាន ប្រកាសនេះនឹងត្រូវដកហូតវិញដោយគ្មានសំណងឡើយ ។

* * *

ប្រកាសលេខ ៧១ ឧក.ប្រក ចុះថ្ងៃទី ២១ ខែ មករា ឆ្នាំ ១៩៩៧

ប្រការ ១ : អនុញ្ញាតអោយលោក **អ៊ិច ឌូតេង** ជនជាតិខ្មែរ សញ្ញាតិកម្ពុជា កាន់អត្តសញ្ញាណប័ណ្ណលេខ ២៥១៥០៥ ភព. ចុះថ្ងៃទី ១៤-៧-៨៩ អាស័យ

ដ្ឋានបច្ចុប្បន្ន ផ្ទះលេខ ៩៣E0 ផ្លូវលេខ ១៣៦ សង្កាត់ ផ្សារថ្មីទី៣ ខណ្ឌដូនពេញ រាជធានីភ្នំពេញ បន្តដំណើរការសិប្បកម្ម ផលិតកម្ម ឥដ្ឋ-ក្បឿង នៅក្នុងទីតាំង ភូមិ ២ សង្កាត់ច្រាំងចំរេះ ២ ខណ្ឌឫស្សីកែវ រាជធានីភ្នំពេញ ។

ប្រការ ២ : ប្រកាសនេះមានតំលៃក្នុងរយៈពេល ៣ ឆ្នាំ ។ ផុតកំណត់ពេលនេះ ម្ចាស់មូលដ្ឋានត្រូវធ្វើពាក្យសុំការអនុញ្ញាតបន្តផលិតកម្មរបស់ខ្លួនឡើងវិញ ។ ក្នុងករណីប្រព្រឹត្តល្មើសច្បាប់ ឬ បង្កអោយមានការប៉ះពាល់ដល់បរិស្ថាន ប្រកាសនេះនឹងត្រូវដកហូតវិញដោយគ្មានសំណងឡើយ ។

* * *

ប្រកាសលេខ ៧២ ឧក.ប្រក ចុះថ្ងៃទី ២៣ខែ មករា ឆ្នាំ ១៩៩៧

ប្រការ ១ : អនុញ្ញាតអោយលោក **ឈៃ ខេមិច** ជនជាតិខ្មែរ សញ្ជាតិកម្ពុជា កាន់អត្តសញ្ញាណប័ណ្ណលេខ ២៦៧៣២១ភព. ចុះថ្ងៃទី ១៥_១០_៩២ អាស័យដ្ឋានបច្ចុប្បន្ន ផ្ទះលេខ ៥៩B ផ្លូវសម្តេចសុធារស សង្កាត់ទន្លេបាសាក់ ខណ្ឌចំការមន រាជធានីភ្នំពេញ បន្តដំណើរការឧស្សាហកម្មតូច ផលិតទឹកកកដើមនៅក្នុងទីតាំងផ្ទះគ្មានលេខ ផ្លូវលេខ ៣៦៩ ភូមិព្រះពន្លា សង្កាត់ព្រែកប្រា ខណ្ឌមានជ័យ រាជធានីភ្នំពេញ ។

ប្រការ ២ : ប្រកាសនេះមានតំលៃក្នុងរយៈពេល ៣ ឆ្នាំ ។ ផុតកំណត់ពេលនេះ ម្ចាស់មូលដ្ឋានត្រូវធ្វើពាក្យសុំការអនុញ្ញាតបន្តផលិតកម្មរបស់ខ្លួនឡើងវិញ ។ ក្នុងករណីប្រព្រឹត្តល្មើសច្បាប់ ផលិតផលគ្មានគុណភាពប៉ះពាល់ដល់សុខភាពប្រជារាស្ត្រ ឬបង្កអោយមានការប៉ះពាល់ដល់បរិស្ថាន ប្រកាសនេះនឹងត្រូវដកហូតវិញដោយគ្មានសំណងឡើយ ។

* * *

ប្រកាសលេខ ៧៣ ឧក.ប្រក ចុះថ្ងៃទី ២៣ ខែ មករា ឆ្នាំ ១៩៩៧

ប្រការ ១ : អនុញ្ញាតអោយលោក **ឡាយ សុខឡី** ជនជាតិខ្មែរ សញ្ជាតិកម្ពុជា កាន់អត្តសញ្ញាណប័ណ្ណលេខ ០៥២១១៣ បជ. ចុះថ្ងៃទី ២១_១២_៨៩ អាស័យដ្ឋាន

បច្ចុប្បន្ន ក្រុមទី៤ ភូមិសូភី២ ឃុំកំពង់ស្វាយ ស្រុកសិរីសោភ័ណ ខេត្តបន្ទាយមានជ័យ បើកដំណើរការសិប្បកម្មផលិតស្រាកែវឆ្លងសញ្ញា ហេនូអាន នៅក្នុងទីតាំង នៅក្នុងទីតាំងដូចអាស័យដ្ឋានខាងលើ ។

ប្រការ ២ : លោក **ឡាយ សុខធី** បានអនុញ្ញាតអោយបន្តដំណើរការផលិតកម្ម និងផលិតនូវមុខ ផលិតផល ស្រាវិស្គី សញ្ញា ហេនូអាន ស្របតាមគំរូសញ្ញាសំគាល់ ដែលបានដំកល់ទុកនៅក្រសួង ឧស្សាហកម្ម រ៉ែ និងថាមពល ។

ប្រការ ៣ : ប្រកាសនេះមានតំលៃក្នុងរយៈពេល ៣ ឆ្នាំ ។ ផុតកំណត់ពេលនេះ ម្ចាស់អាជីវកម្មត្រូវធ្វើពាក្យសុំការអនុញ្ញាតបន្តផលិតកម្មរបស់ខ្លួនឡើងវិញ ។ ក្នុងករណីប្រព្រឹត្តល្មើសច្បាប់ ផលិតផលគ្មានគុណភាពប៉ះពាល់ដល់សុខភាពប្រជារាស្ត្រ ឬបង្កអោយមានការប៉ះពាល់ដល់បរិស្ថាន ប្រកាសនេះនឹងត្រូវដកហូតវិញដោយគ្មានសំណងឡើយ ។

* * *

ប្រកាសលេខ ៧៤ ឧក.ប្រក ចុះថ្ងៃទី ២៣ ខែ មករា ឆ្នាំ ១៩៩៧

ប្រការ ១ : អនុញ្ញាតអោយលោក **អ៊ុច ជុះតេខ** ជនជាតិខ្មែរ សញ្ជាតិកម្ពុជា កាន់អត្តសញ្ញាណប័ណ្ណលេខ ០៥២១១៣ បធ. ចុះថ្ងៃទី ២១_១២_៨៩ អាស័យដ្ឋានបច្ចុប្បន្ន ក្រុមទី៤ ភូមិសូភី២ ឃុំកំពង់ស្វាយ ស្រុក សិរីសោភ័ណ ខេត្តបន្ទាយមានជ័យ បើកដំណើរការសិប្បកម្មផលិតទឹកស៊ីអ៊ីវ សញ្ញា រូបារ៉ូ នៅក្នុងទីតាំងដូចអាស័យដ្ឋានខាងលើ ។

ប្រការ ២ : លោក **ឡាយ សុខធី** ត្រូវបានអនុញ្ញាតអោយបន្តដំណើរការផលិតកម្ម និងផលិតនូវមុខផលិត ផល ទឹកស៊ីអ៊ីវ សញ្ញា រូបារ៉ូ ស្របតាមគំរូសញ្ញាសំគាល់ ដែលបានដំកល់ទុកនៅក្រសួងឧស្សាហកម្ម រ៉ែ និងថាមពល ។

ប្រការ ៣ : ប្រកាសនេះមានតំលៃក្នុងរយៈពេល ៣ ឆ្នាំ ។ ផុតកំណត់ពេលនេះ ម្ចាស់អាជីវកម្មត្រូវធ្វើពាក្យសុំការអនុញ្ញាតបន្តផលិតកម្មរបស់ខ្លួនឡើងវិញ ។ ក្នុងករណីប្រព្រឹត្តល្មើសច្បាប់ ផលិតផលគ្មានគុណភាពប៉ះពាល់ដល់សុខភាពប្រជារាស្ត្រ ឬ.

បង្កអោយមានការប៉ះពាល់ដល់បរិស្ថាន ប្រកាសនេះនឹងត្រូវដកហូតវិញដោយគ្មានសំណងឡើយ ។

* * *

ប្រកាសលេខ ៧៥ ឧក.ប្រក ចុះថ្ងៃទី ២៣ ខែ មករា ឆ្នាំ ១៩៩៧

ប្រការ ១ : អនុញ្ញាតអោយលោក **ឃួន ហៀក** ជនជាតិខ្មែរ សញ្ជាតិកម្ពុជា កាន់អត្តសញ្ញាណប័ណ្ណលេខ ១៨២៤០៨ ត.ក ០៨_៣_៨៩ អាស័យដ្ឋានបច្ចុប្បន្ន ភូមិក្បាលពោធិ ឃុំសំបួរ ស្រុកទ្រាំង ខេត្តតាកែវ បើកដំណើរការរោងម៉ាស៊ីនកិនស្រូវកំលាំង ៨០ សេះ នៅក្នុងទីតាំង ភូមិក្បាលពោធិ ឃុំសំបួរ ស្រុកទ្រាំង ខេត្តតាកែវ ។

ប្រការ ២ : លោក **ឃួន ហៀក** ត្រូវចាប់ផ្តើមដំណើរការផលិតកម្ម អាជីវកម្ម លើទីតាំងដូចបានកំណត់ក្នុងប្លង់ ដោយធានានូវទិន្នផលអង្ករលេខ ១ អោយបានយ៉ាងតិចបំផុត ៦៥ ភាគរយ ។

ប្រការ ៣ : ប្រកាសនេះមានតំលៃក្នុងរយៈពេល ៣ ឆ្នាំ ។ ផុតកំណត់ពេលនេះ ម្ចាស់មូលដ្ឋានត្រូវធ្វើពាក្យសុំការអនុញ្ញាបន្តផលិតកម្មរបស់ខ្លួនឡើងវិញ ។ ក្នុងករណីប្រព្រឹត្តល្មើសច្បាប់ ផលិតផលគ្មានគុណភាពប៉ះពាល់សុខភាពប្រជារាស្ត្រ ឬ បង្កអោយមានការប៉ះពាល់ដល់បរិស្ថាន ប្រកាសនេះនឹងត្រូវដកហូតវិញដោយគ្មានសំណងឡើយ ។

* * *

ប្រកាសលេខ ៧៦ ឧក.ប្រក ចុះថ្ងៃទី ២៣ ខែ មករា ឆ្នាំ ១៩៩៧

ប្រការ ១ : អនុញ្ញាតអោយលោក **លឹម ចាន់សុគី** ជនជាតិខ្មែរ សញ្ជាតិកម្ពុជា កាន់អត្តសញ្ញាណប័ណ្ណលេខ ៣៧៧៤៧៣ ក.ណ ចុះថ្ងៃទី ០២–៨–៩២ អាស័យដ្ឋានបច្ចុប្បន្នផ្ទះលេខ ១២៩ បេ សង្កាត់ទឹកល្អក់ទី ១ ខ័ណ្ឌទួលគោក រាជធានីភ្នំពេញ បន្តដំណើរការឡសិប្បកម្មឥដ្ឋ_ក្បឿង នៅក្នុងទីតាំង ភូមិកណ្តាល ឃុំលំហាច ស្រុកអង្គស្នួល ខេត្តកណ្តាល ។

ប្រការ ២ : ប្រកាសនេះមានតំលៃក្នុងរយៈពេល ៣ ឆ្នាំ ។ ផុតកំណត់ពេលនេះ ម្ចាស់មូលដ្ឋានត្រូវធ្វើពាក្យសុំការអនុញ្ញាតបន្តផលិតកម្មរបស់ខ្លួនឡើងវិញ ។ ក្នុងករណីប្រព្រឹត្តល្មើសច្បាប់ ឬ បង្កអោយមានការប៉ះពាល់ដល់បរិស្ថាន ប្រកាសនេះនឹងត្រូវដកហូតវិញដោយគ្មានសំណងឡើយ ។

* * *

ប្រកាសលេខ ៧៧ ផក.ប្រក ចុះថ្ងៃទី ២៣ ខែ មករា ឆ្នាំ ១៩៩៧

ប្រការ ១ : អនុញ្ញាតអោយលោក **ម្ទូច យ៉ាដារ៉ា** ជាប្រធានមូលដ្ឋានផលិតឥដ្ឋ-ក្បឿង ដែលមានទីតាំង ភូមិឡកំប៉ោរ សង្កាត់ ស្វាយប៉ាក ខ័ណ្ឌឬស្សីកែវ រាជធានីភ្នំពេញ ផ្ទេរសិទ្ធិកាន់កាប់ និង គ្រប់គ្រងជូនលោក **ឡុ ម៉េង** វិញ ។

ប្រការ ២ : ទទួលស្គាល់លោក **ឡុ ម៉េង** ជនជាតិចិន សញ្ញាតិកម្ពុជា កាន់អត្តសញ្ញាណប័ណ្ណលេខ ២០៨៣២៧ ភព. ចចុះថ្ងៃទី ២៧–៣–៨៩ អាស័យដ្ឋាន បច្ចុប្បន្នផ្ទះលេខ ៣៧៣អ៊ី២ ផ្លូវលេខ ៩៣ សង្កាត់អូរឬស្សីទី៤ ខ័ណ្ឌ៧មករា រាជធានីភ្នំពេញ ជាម្ចាស់មូលដ្ឋានផលិតឥដ្ឋ - ក្បឿង ដែលមានទីតាំងដូចមានចែងក្នុងប្រការ ១ ។

ប្រការ ៣ : ប្រកាសនេះមានតំលៃក្នុងរយៈពេល ៣ ឆ្នាំ ។ ផុតកំណត់ពេលនេះ ម្ចាស់មូលដ្ឋានត្រូវធ្វើពាក្យសុំការអនុញ្ញាតបន្តផលិតកម្មរបស់ខ្លួនឡើងវិញ ។ ក្នុងករណីប្រព្រឹត្តល្មើសច្បាប់ ឬ បង្កអោយមានការប៉ះពាល់ដល់បរិស្ថាន ប្រកាសនេះនឹងត្រូវដកហូតវិញដោយគ្មានសំណងឡើយ ។

ប្រការ ៤ : ប្រកាសលេខ ២៥៥ ផ.ក/ប្រក. ចុះថ្ងៃទី ១៩–១០–១៩៩៣ ត្រូវចាត់ទុកជានិរាករណ៍

* * *

ប្រកាសលេខ ៧៨ ឧក.ប្រក ចុះថ្ងៃទី ២៣ ខែ មករា ឆ្នាំ ១៩៩៧

ប្រការ ១ : អនុញ្ញាតអោយលោក **ឡុង ទ័ត** ជនជាតិខ្មែរ សញ្ជាតិកម្ពុជា កាន់អត្តសញ្ញាណប័ណ្ណលេខ ០៣៨៥៦១ កណ. ចុះថ្ងៃទី ១៥_៩_៨៦ អាស័យដ្ឋានបច្ចុប្បន្ន ភូមិថ្មល់ទទឹង ឃុំតំណាក់អំពិល ស្រុក ភ្នំពេញ ខេត្តកណ្ដាល បន្តដំណើរការរោងម៉ាស៊ីនកិនស្រូវកំលាំង ៦០សេះ នៅក្នុងទីតាំង ភូមិថ្មល់ទទឹង ឃុំតំណាក់អំពិល ស្រុកភ្នំពេញ ខេត្តកណ្ដាល ។

ប្រការ ២ : លោក **ឡុង ទ័ត** ត្រូវបន្តដំណើរការផលិតកម្ម អាជីវកម្ម លើទីតាំងដូចបានកំណត់ក្នុងប្លង់ ដោយធានានូវទិន្នផលអង្ករលេខ ១ អោយបានយ៉ាងតិចបំផុត ៦៥ភាគរយ ។

ប្រការ ៣ : ប្រកាសនេះមានតំលៃក្នុងរយៈពេល ៣ ឆ្នាំ ។ ផុតកំណត់ពេលនេះ ម្ចាស់មូលដ្ឋានត្រូវធ្វើពាក្យសុំការអនុញ្ញាតបន្តផលិតកម្មរបស់ខ្លួនឡើងវិញ ។ ក្នុងករណីប្រព្រឹត្តល្មើសច្បាប់ ឬ បង្កអោយមានការប៉ះពាល់ដល់បរិស្ថាន ប្រកាសនេះនឹងត្រូវដកហូតវិញ ដោយគ្មានសំណងឡើយ ។

* * *

ប្រកាសលេខ ៧៩ ឧក.ប្រក ចុះថ្ងៃទី ២៣ ខែ មករា ឆ្នាំ ១៩៩៧

ប្រការ ១ : អនុញ្ញាតអោយលោក **ឃឹម ខួន** ជនជាតិខ្មែរ សញ្ជាតិកម្ពុជា កាន់អត្តសញ្ញាណប័ណ្ណ លេខ ១០៤៩៨១ ភព. ចុះថ្ងៃទី ១៥_១០_៨៨ អាស័យដ្ឋានបច្ចុប្បន្ន ភូមិព្រែករនាំង ឃុំព្រែកកំពឹស ស្រុកកណ្ដាលស្ទឹង ខេត្តកណ្ដាល បន្តដំណើរការផលិតឥដ្ឋ-ក្បឿង នៅក្នុងទីតាំង ភូមិព្រែករនាំង ឃុំព្រែកកំពឹស ស្រុកកណ្ដាលស្ទឹង ខេត្តកណ្ដាល ។

ប្រការ ២ : ប្រកាសនេះមានតំលៃក្នុងរយៈពេល ៣ ឆ្នាំ ។ ផុតកំណត់ពេលនេះ ម្ចាស់មូលដ្ឋានត្រូវធ្វើពាក្យសុំការអនុញ្ញាតបន្តផលិតកម្មរបស់ខ្លួនឡើងវិញ ។ ក្នុងករណីប្រព្រឹត្តល្មើសច្បាប់ ឬ បង្កអោយមានការប៉ះពាល់ដល់បរិស្ថាន ប្រកាសនេះនឹងត្រូវដកហូតវិញដោយគ្មានសំណងឡើយ ។

ជ.រដ្ឋមន្ត្រី

រដ្ឋលេខាធិការ

ហត្ថលេខា និង ត្រា

អ៊ិត ប្រាង

* * *

៣— ទីស្តីការរដ្ឋមន្ត្រីក្រសួងសាធារណការ និង ដឹកជញ្ជូន

សេចក្តីសំរេច

រាជធានីភ្នំពេញ ថ្ងៃទី ១៧ ខែ មករា ឆ្នាំ ១៩៩៧

សេក្តីសំរេចលេខ ០៥១ ស.ក១.សសរ.

ឧបនាយករដ្ឋមន្ត្រី រដ្ឋមន្ត្រីក្រសួងសាធារណការនិងដឹកជញ្ជូន

- បានឃើញរដ្ឋធម្មនុញ្ញ នៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រឹត្យ របស់ព្រះករុណាព្រះបាទសម្តេចព្រះ **នរោត្តម សីហនុវរ្ម័ន** ព្រះមហាក្សត្រ នៃព្រះរាជាណាចក្រកម្ពុជា ចុះថ្ងៃទី ០១ ខែ វិច្ឆិកា ឆ្នាំ ១៩៩៣ ស្តីពីការតែងតាំងរាជរដ្ឋាភិបាលកម្ពុជា ។
- បានឃើញព្រះរាជក្រឹត្យលេខ នស.រកត.១០៩៤/៩០ ចុះថ្ងៃទី ៣១ ខែ តុលា ឆ្នាំ ១៩៩៤ ស្តីពីការកែសំរួលសមាសភាពរាជរដ្ឋាភិបាលកម្ពុជា
- យោងតាមកិច្ចការចាំបាច់របស់ក្រសួង

សំរេច

ប្រការ ១ : តែងតាំងគណៈកម្មការមួយ ដើម្បីសិក្សាស្រាវជ្រាវ និងផ្តល់យោបល់លើឯកសារ Preliminary Design Audit ព្រមជាមួយ Detailed Programme, General Plan, Preliminary Design និងពង្រាងកិច្ចសន្យាបន្ថែមស្តីពីការសាងសង់ព្រលានយន្តហោះអន្តរជាតិពោធិ៍ចិនតុង ។

ប្រការ ២ : គណៈកម្មការនេះ មានសមាសភាពដូចខាងក្រោម ÷

១_ឯកឧត្តម **មាសកេត្ត តែមីរ៉ាន** អនុរដ្ឋលេខាធិការក្រសួងសាធារណការនិងដឹកជញ្ជូន ជាប្រធាន

២_ឯកឧត្តម **ស្រាត់ ខៃសៀង** ទីប្រឹក្សាឯកឧត្តមឧបនាយករដ្ឋមន្ត្រី សមាជិក

៣_ឯកឧត្តម **មិច សុវណ្ណា**
អនុប្រធានប្រតិបត្តិអាជ្ញាធរអភិវឌ្ឍន៍អាកាសយានដ្ឋាន សមាជិក

៤_លោក **គួច ចាន់គុសល** នាយក នាយកដ្ឋានការងារថ្មី សមាជិក

៥_លោក **ជា ស៊ានហុង** ប្រធានមជ្ឈមណ្ឌលសាងសង់ផ្លូវថ្នល់ សមាជិក

៦_លោក **ហែម យឹមអេង** នាយក នាយកដ្ឋាននគររោបនីយកម្ម សមាជិក

៧_លោក **ជុំ សុគន្ធ** អគ្គអធិការកិច្ច សមាជិក

៨_លោក **មាស សាមិត** នាយការិយាល័យពតិមាន សមាជិក

៩_លោក **ឈិត ធន្លា** មន្ត្រីការិយាល័យសហប្រតិបត្តិការអន្តរជាតិ លេខាកត់ត្រា

ប្រការ ៣ : គណៈកម្មការនេះត្រូវចូលរួមប្រជុំតាមការអញ្ជើញរបស់ប្រធាន ។

ប្រការ ៤ : លោកនាយខុទ្ទកាល័យ ក្រសួងសាធារណការនិងដឹកជញ្ជូន និងសាមីខ្លួនត្រូវទទួលបន្ទុកអនុវត្តរៀងៗ ខ្លួន តាមខ្លឹមសារនៃសេចក្ដីសំរេចនេះ ចាប់ពីពេលចុះហត្ថលេខាតទៅ ។

ឧបនាយករដ្ឋមន្ត្រី
រដ្ឋមន្ត្រីក្រសួងសាធារណការនិងដឹកជញ្ជូន
ហត្ថលេខានិងត្រា
អ៊ុង ភឿត

* * *

រាជធានីភ្នំពេញ, ថ្ងៃទី ២១ ខែ មករា ឆ្នាំ ១៩៩៧

សេចក្ដីសំរេចលេខ ០៥៦ ស.ក .សសរ.

ស្ដីពីការបង្កើតគណៈកម្មការ កម្មវិធីអនុវត្តន៍ ធនាគារ ពិភពលោក

ឧបនាយករដ្ឋមន្ត្រី រដ្ឋមន្ត្រីក្រសួងសាធារណការនិងដឹកជញ្ជូន

- បានឃើញរដ្ឋធម្មនុញ្ញ នៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រឹត្យ របស់ព្រះករុណាព្រះបាទសម្ដេចព្រះ **នរោត្តម សីហនុវរ្ម័ន** ព្រះមហាក្សត្រ នៃព្រះរាជាណាចក្រកម្ពុជា ចុះថ្ងៃទី ០១ ខែ វិច្ឆិកា ១៩៩៣ ស្ដីពីការតែងតាំងរាជរដ្ឋាភិបាលកម្ពុជា ។
- បានឃើញព្រះរាជក្រឹត្យលេខ នស.រកត.១០៩៤/៩០ ចុះថ្ងៃទី ៣១ ខែ តុលា ឆ្នាំ ១៩៩៤ ស្ដីពីការ កែសំរួលសមាសភាពរាជរដ្ឋាភិបាលកម្ពុជា
- យោងតាមសំណើរបស់ធនាគារពិភពលោក
- យោងតាមការចាំបាច់របស់ក្រសួង

សំរេច

ប្រការ ១ : បង្កើតគណៈកម្មការក្រសួងមួយ មានឈ្មោះថា គណៈកម្មការអនុវត្តគំរោងអភិវឌ្ឍន៍ ធនាគារពិភពលោក (PROJECT IMPLEMENTATION PIU) ដែលមានសមាសភាពដូចខាងក្រោម ÷

ក_ក្រុមទីប្រឹក្សា កម្មវិធីអភិវឌ្ឍន៍ ធនាគារ ពិភពលោក :

ឯកឧត្តម **មាសកេត្ត ចែមរីវ៉ាន** អនុរដ្ឋលេខាធិការ ប្រធាន

ឯកឧត្តម **ត្រាក់ ថៃសៀង** ទីប្រឹក្សារដ្ឋមន្ត្រី ទទួលបន្ទុកសហប្រតិបត្តិការអន្តរជាតិ អនុប្រធាន

លោក **ទូច ចាន់កុសល** នាយក នាយកដ្ឋានការងារថ្មី សមាជិក

Mr KAZUO Mirakami ទីប្រឹក្សាមជ្ឈមណ្ឌលសាងសង់ ផ្លូវថ្នល់ ទទួលបន្ទុកសំណង់ស៊ីវិល សមាជិក

Mr Jean Paul DEAN នាយក្រុម តំណាង ធនាគារពិភពលោក សមាជិក

ខ_ក្រុមអនុវត្តជំនួយការ ដល់ក្រុមទីប្រឹក្សា ធនាគារ ពិភពលោក :

លោក **ជា ស៊ានហុង** នាយក កម្មវិធីអនុវត្ត ធនាគារ ពិភពលោក ប្រធាន

លោក **យឹម រាជលិតា** អ្នកទទួលបន្ទុកការងាររដ្ឋបាល និងហិរញ្ញវត្ថុ អនុប្រធាន

លោក **អ៊ុំ ទុទ្ធី** អ្នកទទួលបន្ទុកទំនាក់ទំនង សមាជិក

លោក **ស៊ុន ចាន់ថុល** អ្នកទទួលបន្ទុកទំនាក់ទំនង សមាជិក

លោក **ទេព្យ សុធា** អ្នកទទួលខុសត្រូវផ្នែកកុំព្យូទ័រ សមាជិក

លោក **គុំ ទិសិដ្ឋ** អ្នកទទួលខុសត្រូវផ្នែកគូរផែនទី សមាជិក

លោក **សួន ឡាត** អ្នកទទួលខុសត្រូវផ្នែកផែនការ សមាជិក

លោក **គង់ ពិទូ** អ្នកទទួលខុសត្រូវផ្នែកយន្តសាស្ត្រ សមាជិក

លោក ទ្រី ទិដ្ឋា អ្នកទទួលខុសត្រូវផ្នែកសំណង់ស៊ីវិល សមាជិក

លោក ស៊ុន សុភឌ្ឍារី អ្នកទទួលខុសត្រូវផ្នែកគណនេយ្យ សមាជិក

លោក ឈិត ចន្ថា អ្នកជំនួយការ សមាជិក

ប្រការ ២ : គណៈកម្មការនេះ មានភារកិច្ចសហការយ៉ាងជិតស្និទ្ធជាមួយក្រុមជំនាញ របស់ធនាគារពិភពលោក ដើម្បីអនុវត្តគំរោងការស្តារឡើងវិញ នូវហេដ្ឋារចនាសម្ព័ន្ធសាធារណការនិងដឹកជញ្ជូន ដែលផ្គត់ផ្គង់ ហិរញ្ញវត្ថុ បានមកពីប្រាក់ខ្ចីបុលរយៈពេលវែង ពីធនាគារពិភពលោក តាមភារកិច្ចជាក់ស្តែងដូចខាងក្រោម÷

១_ធ្វើការសិក្សាសំរាំង និង ជ្រើសរើសនូវគំរោងការអទិភាពសំរាប់អនុវត្ត ដើម្បីលើកឡើងទៅគណៈកម្មការត្រួតពិនិត្យ និង ទំនាក់ទំនងគំរោងការ PROJECT MONITORING AND COORDINATING UNIT (PMCU) ពោលគឺក្រសួងហិរញ្ញវត្ថុ ដើម្បីសំរេចយល់ព្រម ។

២_រៀបរៀងនូវចំណងជើងនិងខ្លឹមសាររបស់គំរោងការ ព្រមទាំងធ្វើការសិក្សាស្រាវជ្រាវធ្វើនូវគំរោងលំអិត សំរាប់អនុវត្តគំរោងការទាំងឡាយ ដែលបានយល់ព្រមរួចរហើយ ។

៣_អនុវត្តជាក់ស្តែង នូវគំរោងការទាំងនោះ ដោយរួមមានទាំងការងារត្រួតពិនិត្យការដ្ឋានផង ។

៤_រៀបចំ និង គ្រប់គ្រងនូវកិច្ចសន្យាក្នុងការទិញសំភារៈគ្រឿងចក្រនានា ។ ល ។

៥_គ្រប់គ្រងហិរញ្ញវត្ថុ រាល់ការចំណាយលើគំរោងការទាំងនោះ ។

៦_ត្រួតពិនិត្យ និង ទទួលខុសត្រូវលើគុណភាព នៃសំណង់គំរោងការ

៧_ធ្វើរបាយការណ៍រៀងរាល់ត្រីមាសទៅក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ P-M-C-U ដើម្បីបង្ហាញនូវការរីកចំរើន នៅក្នុងការអនុវត្តគំរោងការ ។

សមាជិកទាំងអស់ត្រូវចូលរួមប្រជុំ និង ធ្វើការងារតាមការអញ្ជើញរបស់ប្រធាន ។

ប្រការ ៣ : សេចក្តីសំរេចនេះ មានប្រសិទ្ធភាពអនុវត្តចាប់ពីថ្ងៃដែលបានចុះហត្ថលេខាតទៅ ។

ប្រការ ៤ : លោកនាយកខុទ្ទកាល័យ និង សាមីខ្លួន ត្រូវទទួលបន្ទុកអនុវត្តរៀងៗ តាមខ្លឹមសារ នៃសេចក្តី សំរេចនេះ ។

ឧបនាយករដ្ឋមន្ត្រី

រដ្ឋមន្ត្រីក្រសួងសាធារណការនិងដឹកជញ្ជូន

ហត្ថលេខានិងត្រា

អ៊ុង គៀត

* * *

រាជធានីភ្នំពេញ, ថ្ងៃទី ១៧ ខែ មករា ឆ្នាំ ១៩៩៧

ប្រកាស

លេខ ០៥៣ ប្រក.សកឋដ ចុះថ្ងៃទី ១៧-០១-១៩៩៧

ស្តីពីការកំណត់ថ្លៃឈ្នួលអាជីវកម្ម-សេវាកម្មនិងពន្ធផ្សេងៗ របស់កំពង់ផែ ក្រុងព្រះសីហនុ

* * *

ឧបនាយករដ្ឋមន្ត្រី-រដ្ឋមន្ត្រីក្រសួងសាធារណការនិងដឹកជញ្ជូន

- បានឃើញរដ្ឋធម្មនុញ្ញ នៃព្រះរាជាណាចក្រកម្ពុជា ។
- បានឃើញព្រះរាជក្រឹត្យចុះថ្ងៃទី ០១ ខែ វិច្ឆិកា ឆ្នាំ ១៩៩៣ ស្តីពីការតែងតាំងរាជរដ្ឋាភិបាលកម្ពុជា ។
- បានឃើញព្រះរាជក្រឹត្យលេខ នស.រកត ១០៩៤-៩០ ចុះថ្ងៃទី ៣១ ខែ តុលា ឆ្នាំ ១៩៩៤ ស្តីពីការកែសំរួលសមាសភាពរាជរដ្ឋាភិបាលកម្ពុជា ។
- យោងតាមសំណើរបស់កំពង់ផែ ក្រុងព្រះសីហនុ លេខ ៧៩៦ កផស.ផក ចុះថ្ងៃទី ២២ ខែ ១០ ឆ្នាំ ១៩៩៦ ។

-យោងតាមលិខិតលេខ ០៤៥ សហវ-ហ ចុះថ្ងៃទី ០៨ ខែ មករា ឆ្នាំ ១៩៩៧ របស់ក្រសួងសេដ្ឋកិច្ច និង ហិរញ្ញវត្ថុ ស្តីពីករណីសំណើសុំអនុម័តលើពង្រាងតម្លៃឈ្នួលអាជីវកម្ម-សេវាកម្ម និងពន្ធផ្សេងៗរបស់កំពង់ផែក្រុងព្រះសីហនុ ។

សំរេច

មាត្រា ១ : អនុញ្ញាតអោយកំពង់ផែក្រុងព្រះសីហនុអនុវត្តការគិតថ្លៃឈ្នួលអាជីវកម្ម - សេវាកម្ម និង ពន្ធផ្សេងៗតាមតារាងឧបសម្ព័ន្ធ ដូចមានភ្ជាប់នឹងប្រកាសនេះ ។

មាត្រា ២ : ប្រកាសទាំងឡាយណាដែលន័យខុសពីប្រកាសនេះ ត្រូវចាត់ទុកជានិរាករណ៍ ។

មាត្រា ៣ : ឯកឧត្តមអគ្គនាយក នាយកខុទ្ទកាល័យ និង លោកប្រធានកំពង់ផែក្រុងព្រះសីហនុ ត្រូវទទួលបន្ទុករៀងៗខ្លួនអនុវត្តនូវសេចក្តីប្រកាសនេះ ។

ប្រកាសនេះមានប្រសិទ្ធភាពគតិយុត្តិចាប់ពីដើមត្រីមាសទី ១ ឆ្នាំ ១៩៩៧ តទៅ ។

ឧបនាយករដ្ឋមន្ត្រី
រដ្ឋមន្ត្រីក្រសួងសាធារណការ និងដឹកជញ្ជូន
ហត្ថលេខា និងត្រា
អ៊ុង គៀត

* * *

ឧបសម្ព័ន្ធភ្ជាប់ និងប្រកាសលេខ ០៥៣.ប្រក.សក-មាច ចុះថ្ងៃទី ១៧ ខែ មករា ឆ្នាំ ១៩៩៧

ស្តីអំពី

ការយកពន្ធ និងថ្លៃឈ្នួលផ្សេងៗ នៅកំពង់ផែ ក្រុងព្រះសីហនុ នៃព្រះរាជាណាចក្រកម្ពុជា

គោលការណ៍រួម :

សេចក្តីកំណត់យកពន្ធ និងថ្លៃឈ្នួលនេះ សំដៅអនុវត្តការយកពន្ធ និងថ្លៃឈ្នួល ផ្សេងៗពីគ្រប់នាវា និងទំនិញដែលចូល និងចេញតាមមណ្ឌលកំពង់ផែក្រុងព្រះសីហនុ នៃព្រះរាជាណាចក្រកម្ពុជា ។

ជំពូក ១

របៀបគិតពន្ធ និងថ្លៃឈ្នួល

១–ពន្ធផែ និងថ្លៃឈ្នួលគ្រប់ប្រភេទ ត្រូវគិតជាប្រាក់ « ដុល្លារអាមេរិក » ។

២–រយៈពេលធ្វើការយប់ គឺរាប់ពីម៉ោង ១៧:៣០នាទី ដល់ម៉ោង ០៧:០០ នៃថ្ងៃបន្ទាប់ ។

ថ្ងៃឈប់សំរាកប្រចាំឆ្នាំ និងអនុវត្តទៅតាមអនុក្រឹត្យរបស់រាជរដ្ឋាភិបាល នៃព្រះរាជាណាចក្រកម្ពុជា ។

៣–ឯកត្តាសំរាប់ការគិតថ្លៃឈ្នួលផែ និងពន្ធ និងរបៀបគិត :

ក–ពន្ធលើចំណុះផ្ទុកត្រូវគិតទៅតាមចំណុះសរុប ហ្សេតេ នៃនាវា

–មិនដល់ ១ហ្សេតេ ត្រូវគិតជា ១ហ្សេតេ

–ចំពោះនាវាដែលមិនអាចដឹង ហ្សេតេ គឺត្រូវគិតតាម :

\+ នាវាសណ្តោង : កម្លាំងម៉ាស៊ីន ១សេះ គិតជា ១ហ្សេតេ

\+ សាឡាង : ១តោននៃទំងន់ផ្ទុកអតិបរិមា គិតស្មើ ១ហ្សេតេ

ខ–ឯកត្តាសំរាប់គិតកំលាំងម៉ាស៊ីនគឺសេះ

-មិនដល់ ១សេះ ត្រូវគិតជា ១សេះ

គ-ឯកត្តា សំរាប់គិតពេល គឺថ្ងៃ និងម៉ោង (១ថ្ងៃគិត ២៤ម៉ោង)

-ពី ១២ម៉ោងចុះ គិតកន្លះថ្ងៃ លើសពី១២ម៉ោង គិតពេញ១ថ្ងៃ

-១ម៉ោងគឺ ៦០នាទី ពី៣០នាទីចុះ ត្រូវគិតកន្លះម៉ោង លើសពី៣០នាទី ត្រូវគិតពេញ១ម៉ោង ។

ឃ-ឯកត្តាសំរាប់គិតចំងាយគឺ « មីល » ពីកន្លះមីលចុះ គិតកន្លះមីល លើសពីកន្លះមីល ត្រូវគិតពេញ ១មីល ។

ជំពូក២

ការគិតពន្ធ និងថ្លៃឈ្នួល

១-ពន្ធលើចំណុះផ្ទុក :

១.១-រាល់នាវាដែលចូលមកកំពង់ផែក្រុងព្រះសីហនុ ត្រូវបង់ពន្ធលើចំណុះផ្ទុក លើកលែងតែនាវាដែលចូលចត ដើម្បីគេចពីព្យុះសង្ឃរា ឬដើម្បីរកពេទ្យព្យាបាលនាវិក ។

១.២-ពន្ធលើចំណុះផ្ទុក ត្រូវគិត : ០,២៥ដុល្លារ /ហ្សេតេ

១.៣-ចំពោះនាវាដែលចូលចតដោយគ្មានធ្វើការផ្ទេរផ្ទុកទំនិញ ឬឡើងចុះអ្នកដំណើរ ប៉ុន្តែគ្រាន់តែចូលចត ដើម្បីធ្វើការជួសជុល ដាក់ទឹកសាប ឬ ចាក់ប្រេងពន្ធលើចំណុះផ្ទុកនឹងត្រូវបានបន្ថយ ៣០ ភាគរយ ពីការកំណត់ក្នុងចំណុច ១.២ ។

១.៤-ចំពោះនាវាសណ្តោងដែលអូសក្បូនសាឡាង ពន្ធលើចំណុះផ្ទុកត្រូវគិតលើចំណុះសរុបនៃបណ្តានាវាទាំងអស់នោះបូកបញ្ចូល គ្នា ។

១.៥-ចំពោះនាវា «ឡាហ្ស »ពន្ធលើចំណុះផ្ទុក ត្រូវគិតលើនាវាមេដែលដឹកនាំសាឡាងមកតាម ចំពោះថ្លៃឈ្នួលត្រូវគិតដូចក្នុងចំណុចខាងលើ ។ ឯបណ្តាសាឡាង «ឡាហ្ស »ដែលដាក់ចុះពីនាវាមេរួច ហើយៗត្រូវចូលរើទំនិញ នៅកំពង់ផែទាំងឡាយក្រៅពីមណ្ឌលផែ ដែលមាននាវាមេនោះ

បោះយុថ្កាពន្ធលើចំណុះផ្ទុកត្រូវបានបន្ថយ ៥០ ភាគរយ ពីការកំណត់ក្នុងចំណុច ១.២។

២–ពន្ធសំចត :

២.១–នាវាដែលចតនៅស្ពានផែ នៅពោង ឬ នៅកន្លែងបោះយុថ្កា ត្រូវបង់ពន្ធសំចត ។

២.២–ពន្ធសំចតត្រូវគិតតាមអត្រា ៣យ៉ាងដូចតទៅ :

ក–នៅស្ពានផែ : ០,២៣ដុល្លារ/ហ្សេតេ

ខ–នៅពោង : ០,១០ ដុល្លារ/ហ្សេតេ

គ–នៅកន្លែងបោះយុថ្កា : ០,០៥ដុល្លារ/ហ្សេតេ

២.៣–ក្នុងករណីដែលនាវាចូលចត ២ ឬ ៣កន្លែងផ្សេងគ្នា ពន្ធសំចតត្រូវគិតតែម្តងទេ ដោយយកអត្រាដែលខ្ពស់ជាងគេ ។

២.៤–ក្នុងករណីដែលនាវាបានទទួលបញ្ជាអោយចេញដំណើរពីសេវាដ្ឋាននាវាចរណ៍តែមិនព្រមចេញនោះ នាវាត្រូវបង់ប្រាក់ពិន័យគឺ ÷

–នៅស្ពានផែ : ០,៧០ដុល្លារ /ម៉ែត្រ /ម៉ោង

–នៅពោង : ៥០ ដុល្លារ / ម៉ោង

–នៅកន្លែងបោះយុថ្កា: ២៥ដុល្លារ / ម៉ោង

២.៥–ឈ្នួលសំចតសំរាប់នាវាទេសចរណ៍ នាវាដឹកអ្នកដំណើរ នាវាចូលចតដើម្បីមុខការផ្សេងៗ ត្រូវបានកំណត់យកថ្លៃឈ្នួលតាមអត្រា ដូចខាងក្រោម ÷

ក–នៅស្ពានផែ : ០,០០៣ ដុល្លារ /ហ្សេតេ / ម៉ោង

ខ–នៅពោង : ០,០០១ ដុល្លារ /ហ្សេតេ / ម៉ោង

គ–នៅកន្លែងបោះយុថ្កា : ០,០០០៥ ដុល្លារ /ហ្សេតេ / ម៉ោង

២.៦–ចំពោះនាវាដឹកទំនិញដែលចូលចតផ្ទេរផ្ទុកលើសពី ៥ថ្ងៃឡើងទៅត្រូវគិតតំណាក់ទីមួយ ៥ថ្ងៃដំបូងតាមចំណុច ២.២ និងត្រូវបូកបន្ថែមចំនួនថ្ងៃដែលលើសជាក់ស្តែងតាមចំណុច ២.៥ខាងលើ ។

៣–ពន្ធប្រឡាយ :

៣.១–ពន្ធប្រឡាយត្រូវគិតតាមអត្រា : ០,៥០ដុល្លារ /ហ្សេតេ

៣.២–សំរាប់នាវា «ឡាហ្គ »ពន្ធប្រឡាយត្រូវគិតតាមអត្រាដូចតទៅ ÷

\+ នាវាដឹកសាឡាង : ០,១០ដុល្លារ /ហ្សេតេ

\+ សាឡាង : ០,១៥ដុល្លារ /ហ្សេតេ

៤–ថ្លៃឈ្នួលកណ្ណធារ :

៤.១–គ្រប់នាវាដែលចេញ ចូលកំពង់ផែ ឬ ក៏ធ្វើការផ្លាស់ប្តូរកន្លែងចតក្នុងមណ្ឌលផែត្រូវមានកណ្ណធារនាំផ្លូវជាចាំបាច់ ហើយត្រូវបង់ថ្លៃឈ្នួលកណ្ណធារ ។

៤.២–ថ្លៃឈ្នួលកណ្ណធារ ត្រូវបង់ដោយយោងទៅតាមចំណុះសរុប «ហ្សេតេ » នៃនាវា និងចំងាយផ្លូវ ។

ក–ចេញ-ចូល កំពង់ផែ : ០,០៣ដុល្លារ / ហ្សេតេ

ខ–ចេញ-ចូល កំពង់ផែប្រេង : ០,០៣៥ដុល្លារ / ហ្សេតេ

ប៉ុន្តែកំរិតទាបបំផុតត្រូវបង់ ១២៥ដុល្លារ នាវាមួយគ្រឿង (គិតបញ្ចូលទាំងថ្លៃកាណូតចំលង) ។

គ–សំរាប់ការផ្លាស់ប្តូរកន្លែងម្តងៗក្នុងមណ្ឌលផែត្រូវគិត ០,០២២ ដុល្លារ /ហ្សេតេ

ឃ–ការផ្លាស់ប្តូរសំចតតាមបណ្តោយផែ ដោយមិនប្រើកណ្ណធារត្រូវគិត ១១៤ដុល្លារ /ផ្លាស់ប្តូរម្តង ។

៤.៣–ដើម្បីចៀសវាងការរង់ចាំនាវាត្រូវផ្ញើជូនអាជ្ញាធរកំពង់ផែ នូវសំណើកណ្ណធារ២៤ម៉ោងមុន ។ ក្នុងករណីដែលត្រូវធ្វើការកែប្រែ ឬលុបចោលសំណើនោះវិញ នាវាត្រូវផ្តល់ពត៌មានជាលាយល័ក្ខអក្សរទៅកំពង់ផែ ៦ម៉ោងមុន ។ បើមិនដូច្នេះទេ នាវានឹងត្រូវបង់ថ្លៃរង់ចាំនៃកណ្ណធារ ។

ក–បើសិនជាកណ្ណធារនៅចំណុចចេញដំណើរនៅឡើយ រយៈពេលរង់ចាំត្រូវគិតមួយម៉ោង ។

ខ–បើសិនជាកណ្ណធារបានចេញពីចំណុចចេញដំណើររួចហើយ រយៈពេលរង់ចាំត្រូវគិតពីពេលដែលកណ្ណធារចាកចេញ

រហូតដល់ពេលត្រឡប់ដល់កន្លែងដើមវិញ បន្ទាប់ពីបានទទួលពត៌មានសុំកែប្រែនោះ ។

គ-បើសិនជាកណ្ណធារបានទៅដល់ស្ថានីយ៍កណ្ណធាររួចហើយ រយៈពេលរង់ចាំត្រូវកំណត់យ៉ាងច្រើនបំផុតត្រឹម ៥ម៉ោង ហួសពីរយៈពេលនេះសំណើសុំកណ្ណធារត្រូវទុកជាមោឃៈ ។

៤.៤-បន្ទាប់ពីចប់បេសកកម្មរួចហើយ បើសិនជាមេបញ្ជាការនាវា ស្នើសុំរក្សាទុកកណ្ណធារលើនាវាជាបន្តទៅទៀត នាវាត្រូវបង់ថ្លៃកណ្ណធារប្រចាំការតាមរយៈពេលដែលស្នើសុំនោះ ។

៤.៥-ថ្លៃឈ្នួលកណ្ណធាររង់ចាំគឺ : ៣០ដុល្លារ / ម៉ោង «ដោយគិត ទាំងថ្ងៃការណ្ឌតចំលងផង » ។

៤.៦-ថ្លៃឈ្នួលប្រចាំការនៅលើនាវា : ១០ដុល្លារ / ម៉ោង ។

៥-ថ្លៃឈ្នួលនាវាជំនួយ :

៥.១-នាវាដែលចូល ឬចេញពីកំពង់ផែ ឬផ្លាស់ប្តូរចំណត ត្រូវប្រើនាវាជំនួយ និងត្រូវបង់ថ្លៃឈ្នួលដោយគិតទៅតាមរយៈពេលធ្វើការនៃនាវាជំនួយនោះ ។ រយៈពេលធ្វើការងារនេះ គិតចាប់តាំងពីពេលដែលនាវាជំនួយចេញដំណើរទៅរហូតត្រឡប់ចូលចំណតដើមវិញ ឬរហូតដល់ពេលផ្លាស់ទៅបំរើការងារផ្សេងទៀត ។

៥.២-ថ្លៃឈ្នួលនាវាជំនួយ ត្រូវគិតយោងទៅតាមចំណុះសរុប «ហ្សេតេ» នៃនាវាសុំជំនួយដូចមានតារាងខាងក្រោម ÷

ប្រភេទនាវាតាម « ហ្សេតេ »		តម្លៃឈ្នួលក្នុង១ម៉ោង
-ក្រោម ១.០០០ ហ្សេតេ		១០៥
-ពី	១.០០១ ហ្សេតេ ទៅ ៤.០០០ ហ្សេតេ	១៧៨
-ពី	៤.០០១ ហ្សេតេ ១០.០០០ ហ្សេតេ	១៩០
-ពី	១០.០០១ ហ្សេតេ ១៥.០០០ ហ្សេតេ	២៣៧

*លើសពី ១៥.០០១ ហ្សេតេ រាល់ ១.០០០ ហ្សេតេ ដែលលើសត្រូវបូកបន្ថែម ២០ដុល្លារ / ម៉ោង ។

៥.៣–ការប្រើប្រាស់នាវាជំនួយតិច ឬច្រើនជាងលទ្ធភាព និងជាសមត្ថកិច្ចរបស់អាជ្ញាធរកំពង់ផែ ។

៦–ថ្លៃឈ្នួលពាក់ និងដោះពួរ :

៦.១–រាល់នាវាដែលចតនៅស្ពានផែ ឬនៅពោង ត្រូវបង់ថ្លៃឈ្នួលពាក់ និងដោះពួរដោយគិតថ្លៃឈ្នួលតាមតារាងខាងក្រោមនេះ ÷

*** តារាង ពាក់ - ដោះពួរ**

ប្រភេទនាវាតាមហ្សេតេ	ថ្លៃឈ្នួលពាក់ និង ដោះពួរ	
	នៅស្ពានផែ	នៅពោង
	ដុល្លារ / ដង	ដុល្លារ / ដង
នាវាក្រោម ១.០០០ ហ្សេតេ	១៦	៥០
ពី ១.០០១ ដល់ ៤.០០០ ហ្សេតេ	៣៣	៨៣
ពី ៤.០០១ ដល់ ១០.០០០ហ្សេតេ	៥០	១១៦
ពី ១០.០០១ ដល់ ១៥.០០០ ហ្សេតេ	៦៦	១៣២
លើសពី ១៥.០០១ ហ្សេតេ រាល់ ១.០០០ ហ្សេតេ ដែលលើសត្រូវបន្ថែម	១៧	៥៥

៧–ថ្លៃឈ្នួលបើក-បិទឃ្លប់នាវា :

៧.១–នាវា ឬ សាឡង់ត្រូវបង់ថ្លៃឈ្នួលបើក ឬបិទឃ្លប់ម្តងៗដែលធ្វើ ឡើងដោយកម្មករកំពង់ផែតាមតារាងថ្លៃឈ្នួលខាងក្រោមនេះ ÷

*** តារាងតម្លៃបើក - បិទឃ្លប់**

ប្រភេទនាវាតាមហ្សេតេ	ថ្លៃឈ្នួលសំរាប់បើកម្តង ឬបិទម្តងក្នុងឃ្លប់មួយ	
	បើកឬបិទឃ្លប់គ្មានធ្នឹម	បើកឬបិទឃ្លប់មានធ្នឹម
	ដុល្លារ / ឃ្លប់	ដុល្លារ / ឃ្លប់
–ក្រោម ៥.០០០ ហ្សេតេ	១៣	២៦

-ពី ៥.០០១ ដល់១០.០០០ ហ្សេកេ	២៣	៤៦
-ពី១០.០០១ ដល់១៥.០០០ហ្សេកេ	៣៦	៧៣
-លើសពី ១៥.០០១ រាល់ ១.០០០ ហ្សេកេ ដែលលើសត្រូវបន្ថែម	១៣	២៦

៧.២-ចំពោះនាវាដែលប្រដាប់ដោយគ្រឿងយន្តអាចបើក-បិទឃ្លប់បាន ÷

ក-បើការបើកឬបិទឃ្លប់នោះបញ្ជាដោយក្រុមនាវិក នាវាមិនបាច់បង់ថ្លៃឈ្នួលទេ

ខ-បើការបើក ឬបិទនោះបញ្ជាដោយកម្មករ ថ្លៃឈ្នួលបើក ឬបិទត្រូវគិត៣០ ភាគរយ នៃអត្រាដែលកំណត់ក្នុងតារាងតំលៃបើក-បិទឃ្លប់ខាងលើ ។

គ-ការបិទបើកឃ្លប់ដោយប្រើមធ្យោបាយផ្សេ នាវាត្រូវបង់បន្ថែមថ្លៃឈ្នួលមធ្យោ-បាយទាំងនោះ ។

៨-ថ្លៃឈ្នួលបោសសំអាតឃ្លប់នាវា :

៨.១- ការបោសសំអាតឃ្លប់នាវា-សាឡាងដោយកម្មករ ថ្លៃឈ្នួលនិងត្រូវគិតដូច ក្នុងតារាងខាងក្រោមនេះ ៕

៨.២- នាវាត្រូវផ្តល់ទឹក និងសំភារៈផ្សេងៗសំរាប់ការបោសសំអាតឃ្លប់ ។

៨.៣-ក្នុងការបោសសំអាតឃ្លប់នាវាដែលមានច្រើនថ្នាក់ ១ថ្នាក់ត្រូវគិតដូច ១ឃ្លប់ដែរ

៨.៤- ឃ្លប់នាវាដែលត្រូវធ្វើការបោសសំអាត មិនត្រូវអោយមានទំនិញអ្វីនៅ សល់ឡើយ ។ បើមិនដូច្នេះទេ នាវានឹងត្រូវបង់ថ្លៃឈ្នួលលើកទំនិញនោះ ចេញបន្ថែមទៀត

*** តារាងតំលៃបោសសំអាតឃ្លប់**

ប្រភេទនាវាតាមហ្សេកេ	ថ្លៃឈ្នួលសំរាប់ការបោសសំអាតឃ្លប់មួយ	
	បោសសំអាតបន្ទាប់ពីការ រើទំនិញគ្មានជាតិពុល	បោសសំអាតបន្ទាប់ពីការ រើទំនិញគ្រោះថ្នាក់ពុល
	ដុល្លារ / ដង	ដុល្លារ / ដង
-ក្រោម ៥.០០០ ហ្សេកេ	៣៣	៥៣

ពី ៥.០០១ ដល់ ១០.០០០ ហ្សេគេ	៨១	៨៣
ពី ១០.០០១ ដល់ ១៥.០០០ ហ្សេគេ	៥៦	១១៦
លើសពី ១៥.០០១ ហ្សេគេ រាល់ ១.០០០ ហ្សេគេ ដែលលើសត្រូវបន្ថែម	១០	២៣

៨.៥–តាមសំណូមពររបស់មេបញ្ជាការនាវា ក្នុងការលាងសំអាតថ្នាក់យប់ថ្ងៃឈ្នួល ត្រូវគិតទៅតាមទំហំដែលត្រូវធ្វើនោះ ។

ក–ដោយប្រើទឹកផ្តល់ពីនាវា ០,១៧ដុល្លារ / ម³

ខ–ដោយប្រើទឹកផ្តល់ពីកំពង់ផែ ០,២០ដុល្លារ / ម³

គ–ថ្លៃឈ្នួលនេះកំណត់តិចបំផុតត្រឹម ៥០ដុល្លារ / ដង

៩– ថ្លៃឈ្នួលចាក់សំរាម :

បើសិនជាអាជ្ញាធរកំពង់ផែ គ្មានចេញបទបញ្ញាណាផ្សេងទៀតទេ នាវាស្នាក់នៅកំពង់ផែ ត្រូវអោយកម្មកររបស់កំពង់ផែ យកសំរាមទៅចាក់ចោល ក្នុងរយៈ ៥ ថ្ងៃម្តង ។

–នៅស្ពានផែ : ៣០ដុល្លារ / ម្តង

–នៅពោង ឬបោះយុថ្កា : ៦០ដុល្លារ / ម្តង

ក្នុងករណីដែលការចាក់សំរាមធ្វើឡើងមុន ៥ថ្ងៃ តាមសំណូមពរនៃបញ្ជាការនាវា នាវាត្រូវបង់ថ្លៃឈ្នួលបន្ថែមទៀត ដូចការកំណត់ខាងលើ ។

១០– ថ្លៃឈ្នួលផ្តល់ទឹកសាប :

១០.១–នៅស្ពានផែ : ២,៥០ដុល្លារ / ម³

១០.២–នៅពោង ឬបោះយុថ្កា : ៣,៥០ដុល្លារ / ម³

១១– ឈ្នួលប្រគល់ - ទទួលទំនិញ :

១១.១–ទំនិញជាចាវ : ០,៥០ដុល្លារ / តោន

១១.២–ទំនិញទូទៅ : ០,៧០ដុល្លារ / តោន

១១.៣–រថយន្តគ្រឿងចក្រ: ៥ដុល្លារ / ១គ្រឿង

១២— ឈ្នួលធ្វើបែបបទផ្សេងៗ :

១២.១–នាវាគ្រប់ប្រភេទចាំបាច់ត្រូវបង់ថ្លៃឈ្នួលធ្វើបែបបទ : មួយជើងនាវា ១០០ដុល្លារ

១២.២–ឈ្នួលការពារនាវា: ១,៥០ដុល្លារ / នាក់ម៉ោង

១២.៣–ម្ចាស់ទំនិញនាំចូល-នាំចេញ ត្រូវបង់ថ្លៃបោសសំអាត-លាងផែនៅមុខនាវាចូលចតផ្ទេរផ្ទុកតាមអត្រា ១២ដុល្លារ / ថ្ងៃ « គិតពីនាវាចាប់ផ្តើមផ្ទេរដល់ថ្ងៃបញ្ចប់ការផ្ទេរ » ។

១៣— ចំណុចអនុគ្រោះបន្ថយពន្ធ :

១៣.១–ចំពោះនាវាទេសចរ ដឹកអ្នកដំណើរ និងនាវាសញ្ជាតិកម្ពុជាដែលធ្វើអាជីវកម្ម ដឹកជញ្ជូនឆ្លងកាត់ផ្លូវអន្តរជាតិ ត្រូវបានបន្ថយ ២០% លើពន្ធចំណុះផ្ទុក និងពន្ធ ប្រឡាយ ។

១៣.២–ឯនាវាសញ្ជាតិកម្ពុជា « នាវាក្នុងស្រុក » ធ្វើអាជីវកម្ម ដឹកជញ្ជូនពីកំពង់ផែមួយទៅកំពង់ផែមួយទៀតក្នុងស្រុក ត្រូវបានអនុគ្រោះបន្ថយពន្ធដូចខាងក្រោម ÷

ក–បន្ថយ ២០ភាគរយ លើពន្ធចំណុះផ្ទុក

ខ–បន្ថយ ៥០ភាគរយ លើពន្ធប្រឡាយ

១៣.៣–ករណីប្រធានស័ក្តមានព្យុះសង្ឃរា តម្រូវនាំនាវាទៅកន្លែងបោះយុថ្កាដើម្បីការពារសុវត្ថិភាពផែ និង នាវាពន្ធសំចតនៅកន្លែងបោះយុថ្កាត្រូវបានលើកលែង ប៉ុន្តែនាវាត្រូវបង់ថ្លៃឈ្នួលនាវាជំនួយកណ្តាប់ និងអ្នកពាក់-ដោះពួរ ។

ជំពូក ៣

បណ្តាថ្លៃឈ្នួល

១៤-ថ្លៃឈ្នួលលើកដាក់ទំនិញ :

១៤.១- ថ្លៃឈ្នួលលើកដាក់ទំនិញដូចមានក្នុងតារាងខាងក្រោមនេះ គឺតម្រូវអោយភាគីនាវា ឬម្ចាស់ទំនិញបង់ចំណាយថ្លៃលើកដាក់ទំនិញដោយប្រើជងយោងនាវា ។

១៤.២-ឯកត្តាគិតទំងន់ទំនិញគឺ «តោនមេទ្រិក »របៀបគិតជាលេខគត់ ។

-ទំងន់ក្រោម ៥០០គក្រ ត្រូវគិត ៥០០ គ.ក្រ

-ទំងន់លើស ៥០០គក្រ ត្រូវគិត ១តោនពេញ

-ដោយឡែកទំនិញរៀបទុកដាក់ភាគទី ១,២០០ម² ឬ ១,១៣៣ម³ ត្រូវគិត ១តោន ។

-ទំងន់ទំនិញត្រូវយកតាមតារាងរាយមុខទំនិញ (អ.ម) ឬអាជ្ញាប័ណ្ណ (Manifeste) គិតទាំងទំងន់ទំនិញសុទ្ធ និងសំបកវេចខ្ចប់ ឬ សំបកកេសក្នុងតែន័រ ។

១៤.៣-ទំនិញសត្វរស់-ស្រាល ហើយសំពីងសំពោងត្រូវគិតតាមតារាងខាងក្រោម ÷

ល.រ	រាយប្រភេទទំនិញ	ឯកត្តា	ទំងន់គិតថ្លៃឈ្នួល
១	គោ - ក្របី - សេះ	១ក្បាល	១.០០០តោន
២	ជ្រូក - ពពែ - ចៀម	១ក្បាល	០.៥០០តោន
៣	សត្វដាក់ក្នុងទ្រុង-កន្ត្រក	១ម³	១,០០០តោន
៤	ទំនិញសំពីងសំពោង	១តោន	៣.០០០តោន

១៤.៤-តារាងថ្លៃឈ្នួលលើកដាក់ទំនិញគិតជារូបិយប័ណ្ណ ដុល្លារអាមេរិក/តោន។ តំលៃគោលគឺ គិតពីឃ្លាំងនាវា ដល់គែមផែ

១៥-ការគិតបន្ថែមថ្លៃឈ្នួល :

« លើតំលៃគោលនៃតារាងថ្លៃឈ្នួលលើកដាក់ ១៤.៤ »

ក–ការផ្ទេរផ្ទុកទំនិញពីឃ្លាំងមួយទៅឃ្លាំងមួយទៀតនៃនាវាដដែល ត្រូវបានបង្កើន ៣០ ％ ។

ខ–ការផ្ទេរផ្ទុកទំនិញនៅឃ្លាំងនាវាដែលមានជំរៅ៣ម៉ែត្រឡើងទៅ ឬមាត់ឃ្លាំងតូចជាង ៣ម៉ែត្រ ត្រូវគិតបន្ថែម ១០០ភាគរយ ។

គ–ទំនិញស្មៀតហាប់ជាគំនរ ត្រូវវាយបំបែកទើបផ្ទេរផ្ទុកបាន ត្រូវគិតបន្ថែម ៤០ភាគរយ ។

ឃ–ទំនិញជាឡូតិ , កេស ប្រអប់បាវតូចពេកដែលមានទំងន់១ដុំៗតិចជាង ១០ គ.ក្រ ត្រូវបង្កើន ៥០ភាគរយ ។

ង–ការផ្ទេរផ្ទុកទំនិញក្នុងឃ្លាំងត្រជាក់ក្រោម ១០អង្សាសេ ត្រូវបង្កើន ៥០ភាគរយ និង បង្កើន ១០០ភាគរយ ចំពោះឃ្លាំងត្រជាក់ក្រោមសូន្យអង្សាសេ ។

ច–ចំពោះទំនិញវែងហួសខ្នាត និងទំងន់ធ្ងន់ហួសធម្មតា គិតបន្ថែមមានដូចខាងក្រោម:

–ប្រវែងលើសពី ១២ម – ១៦ម ឬទំងន់លើសពី ១០តោន-២០តោន ត្រូវបង្កើន ៥០ភាគរយ ។

–ប្រវែងលើសពី ១៦ម -២០ម ឬទំងន់លើសពី២០តោនទៅ ត្រូវបង្កើន ៧០ភាគរយ ។

–ប្រវែងលើសពី២១មឬទំងន់លើសពី២១តោនឡើងទៅត្រូវបង្កើន១០០ភាគរយ ។

ឆ–ការលើកដាក់ទំនិញមានជាតិពុល ទំនិញមានគ្រោះថ្នាក់ ត្រូវបង្កើន ៥០ភាគរយ ។

ជ–ការលើកដាក់ទំនិញ ពីម៉ោង ១៧:៣០នាទី ទៅម៉ោង ២៣:០០ ត្រូវបង្កើន២៥ ភាគរយ ។

ឈ–ការលើកដាក់ទំនិញ ពីម៉ោង ២៤:០០ ទៅម៉ោង ៧:០០ ថ្ងៃបន្ទាប់ ត្រូវបង្កើន៥០ ភាគរយ ។

ញ–ការផ្ទេរផ្ទុកទំនិញ នៅថ្ងៃបុណ្យ–សៅរ៍-អាទិត្យ ត្រូវបង្កើន៥០ ភាគរយៈ ចំពោះតែ នៅនាវាប៉ុណ្ណោះ ។

១៦-ថ្លៃឈ្នួលកុងតែន័រ :

១៦.១-ឈ្នួលលើកដាក់កុងតែន័រ ត្រូវបានកំណត់ដូចតារាងខាងក្រោម ÷

ប្រភេទ កុងតែន័រ	តំលៃគោល	នាវា-ទីលាន	ទីលាន-រថយន្ត	ទីលាន-រថភ្លើង
កុងតែន័រ ២០ មានទំនិញ	២៨	៥៧	៤៦	៥៧
កុងតែន័រ ២០ ទទេ	១៤	៣០	២៣	២៨
កុងតែន័រ ៤០ មានទំនិញ	៤២	៨៥	៦២	៧៨
កុងតែន័រ ៤០ ទទេ	២២	៤៥	៤៤	៥៥

១៦.២–តំលៃឈ្នួលខាងលើគឺ ការលើកដាក់ដោយប្រើយោងនាវា ។ បើសិនជាប្រើប្រាស់រថយន្តស្ទូចរបស់កំពង់ផែ ថ្លៃឈ្នួលត្រូវបានបង្កើន ១៨ដុល្លារ ១គ្រឿង កុងតែន័រមានទំនិញ និង១០ដុល្លារ ១គ្រឿង កុងតែន័រគ្មានទំនិញ ។

១៦.៣–គ្រង់ស៊ីតកុងតែន័រផ្ទេរ ឬផ្ទុក ត្រូវបានកំណត់ដូចខាងក្រោម ÷

–កុងតែន័រ ២០ ពេញ : ៥១ដុល្លារ ១គ្រឿង
–កុងតែន័រ ២០ ទទេ : ២៧ដុល្លារ ១គ្រឿង
–កុងតែន័រ ៤០ ពេញ : ៧៦ដុល្លារ ១គ្រឿង
–កុងតែន័រ ៤០ ទទេ : ៣២ដុល្លារ ១គ្រឿង

១៦.៤.១–ឈ្នួលផ្លាស់ប្តូរកុងតែន័រក្នុងនាវា «ពីឃួបមួយទៅឃួបមួយ»

–កុងតែន័រ ២០ មានទំនិញ : ២៥ដុល្លារ ១គ្រឿង
–កុងតែន័រ ២០ ទទេ : ១៥ដុល្លារ ១គ្រឿង
–កុងតែន័រ ៤០ មានទំនិញ : ៣៨ដុល្លារ ១គ្រឿង
–កុងតែន័រ ៤០ ទទេ : ២៣ដុល្លារ ១គ្រឿង

១៦.៤.២–ឈ្នួលផ្លាស់ប្តូរទីកន្លែងកុងតែន័រពីនាវាមកគែមផែ និងត្រឡប់វិញ

–កុងតែន័រ ២០ មានទំនិញ : ២៨ដុល្លារ ១គ្រឿង

–កុងតែន័រ ២០ ទទេ : ១៤ដុល្លារ ១គ្រឿង
–កុងតែន័រ ៤០ មានទំនិញ : ៤២ដុល្លារ ១គ្រឿង
–កុងតែន័រ ៤០ ទទេ : ២២ដុល្លារ ១គ្រឿង

១៦.៤.៣–ឈ្នួលផ្លាស់ប្តូរទីកន្លែងនៅទីលាន (តាមសំណូមពររបស់ភាគីម្ចាស់ទំនិញ)

–កុងតែន័រ ២០ មានទំនិញ : ២៧ដុល្លារ ១គ្រឿង
–កុងតែន័រ ២០ ទទេ : ១៥ដុល្លារ ១គ្រឿង
–កុងតែន័រ ៤០ មានទំនិញ : ៤០ដុល្លារ ១គ្រឿង
–កុងតែន័រ ៤០ ទទេ : ២២ដុល្លារ ១គ្រឿង

១៦.៤.៤–ប្តូរទីកន្លែងពីនាវាមកទីលាន និងត្រឡប់វិញ (តាមសំណូមពរចាំបាច់ របស់ម្ចាស់នាវា)

–កុងតែន័រ ២០ មានទំនិញ : ៧៦ដុល្លារ ១គ្រឿង
–កុងតែន័រ ២០ ទទេ : ៤០ដុល្លារ ១គ្រឿង
–កុងតែន័រ ៤០ មានទំនិញ : ១១៤ដុល្លារ ១គ្រឿង
–កុងតែន័រ ៤០ ទទេ : ៤៨ដុល្លារ ១គ្រឿង

១៦.៤.៥– ឈ្នួលស្តុកកុងតែន័រ :

ប្រភេទកុងតែន័រ	រយៈពេលស្តុក (ដុល្លារ/គ្រឿង/ថ្ងៃ)		
	ពី ១ - ៧ ថ្ងៃ	ពី ៨ - ១៤ ថ្ងៃ	ពី១៥ថ្ងៃឡើងទៅ
–កុងតែន័រ ២០ មានទំនិញ	៣	៦	៩
–កុងតែន័រ ២០ ទទេ	១,៥០	៣	៤,៥០
–កុងតែន័រ ៤០ មានទំនិញ	៦	១២	១៨
–កុងតែន័រ ៤០ ទទេ	២,៥០	៥	៧,៥០
–កុងតែន័រ ក្លាសេប្រើថាមពលអគ្គិសនីផែ	៤០	៧៥	

* ឈ្នួលស្តុកត្រូវបានលើកលែងចំនួន ៣ថ្ងៃ ដោយគិតពីថ្ងៃផ្ទេរចប់ពីនាវា ។
* ចំពោះកុងតែន័រត្រង់ស៊ីត ត្រូវបានមិនគិតថ្លៃឈ្នួល ១០ថ្ងៃ លើសរយៈពេលនេះ ត្រូវគិតតាមតំលៃស្តុកខាងលើ ។

១៦.៤.៦–ឈ្នួលបើទំនិញពីកុងតែន័រផ្ទេរចូលឃ្លាំង ឬផ្ទេរចូលកុងតែន័រមួយទៀត ៥០ដុល្លារ ១គ្រឿង ចំពោះកុងតែន័រ ២០ និង ១០០ដុល្លារ ១គ្រឿង ចំពោះកុងតែន័រ ៤០ ។

– ចំពោះការបើចេញ-ផ្ទុកចូលមួយផ្នែកនៃទំនិញក្នុងកុងតែន័រ ត្រូវគិតតាមតារាងតំលៃទំនិញទូទៅ ដែលផ្ទេរពីឃ្លាំងដាក់រថយន្ត ឬពីរថយន្តចូលឃ្លាំង ។

១៧–មធ្យោបាយ កំលាំងពលកម្មក្រៅ ចូលបំរើការងារក្នុងផែ :

– ករណីចាំបាច់ដោយមានការយល់ព្រមពីកំពង់ផែ ម្ចាស់ទំនិញសុំយកមធ្យោបាយ ឬ កំលាំងពលកម្មពីក្រៅមកបំរើការងារក្នុងកិច្ចការផែ ម្ចាស់ទំនិញត្រូវបង់ថ្លៃឈ្នួល២០ភាគរយ នៃតំលៃឈ្នួលរបស់កំពង់ផែ ។

១៨–ថ្លៃឈ្នួលស្តុកទំនិញក្នុងឃ្លាំង ទីលាន :

១៨.១–ទំនិញនាំចូលត្រូវបានលើកលែង ៥ថ្ងៃ ដោយមិនគិតថ្លៃឈ្នួល បន្ទាប់ពីថ្ងៃ បញ្ចប់ការផ្ទេរពីនាវា ។

១៨.២–ចំពោះទំនិញនាំចេញ ត្រូវបានលើកលែង៧ថ្ងៃ ដោយមិនគិតថ្លៃឈ្នួល គឺចាប់ រាប់ពីថ្ងៃដំបូងបង្អស់ដែលទំនិញបានចូលដល់ឃ្លាំង ឬទីលាន ។

–ក្នុងឃ្លាំង : ០,២០ដុល្លារ / តោនថ្ងៃ ឬ ០.២៥ដុល្លារ/ម២/ថ្ងៃ

–ទីលាន : ០,១០ដុល្លារ / តោនថ្ងៃ ឬ ០.១៥ដុល្លារ/ម២/ថ្ងៃ

១៩–ថ្លៃឈ្នួលកើបច្រក វេចខ្ចប់ កែច្នៃ :

– ម្ចាស់ទំនិញជាអ្នកផ្គត់ផ្គង់សំភារៈវេចខ្ចប់ អំបោះដេរ និងសំភារៈកែច្នៃ
– ថ្លៃឈ្នួលកើបច្រក វេចខ្ចប់កែច្នៃ : ១ដុល្លារ/តោន
– កើបច្រក វេចខ្ចប់ កែច្នៃទំនិញមានគ្រោះថ្នាក់ , ជាតិពុល ,ទំនិញ ប៉ះពាល់ដល់សុខភាពត្រូវបង្កើន ៥០ភាគរយ ។

– បើលើកទុកដាក់ចំងាយ ២៥ម៉ែត្រ ឬរៀបគំនរកំពស់ ២ម៉ែត្រឡើង ត្រូវបង្កើន ៣០ភាគរយ ក្នុងករណីមានសំណូមពរពីម្ចាស់ទំនិញ ។

– ទំនិញកកជាដុំ ត្រូវគាស់បំបែកទើបកើបច្រក វេចខ្ចប់កែច្នៃបាន ត្រូវបង្កើន៥០ ភាគរយ ។

២០– ថ្លៃឈ្នួលកំលាំងពលកម្ម–អ្នកបច្ចេកទេស :

–ពលកម្មបច្ចេកទេសជំនាញ : ៥ដុល្លារ/នាក់/ម៉ោង

–ពលកម្មធម្មតា : ៣ដុល្លារ/នាក់/ម៉ោង

–អ្នកមុជទឹក : ៥០ដុល្លារ/នាក់/ម៉ោង

–កណ្ដារ : ២០ដុល្លារ/នាក់/ម៉ោង

–ពលកម្មជាមួយទំនិញមានគ្រោះថ្នាក់ ជាតិពុល ត្រូវបង្កើន ៥០ភាគរយ ។

២១– ថ្លៃឈ្នួលចំលងទំនិញ :

២១.១– ចំពោះការចម្លងទំនិញដែលធ្វើឡើងក្នុងមណ្ឌលផែ ដោយឡែកថ្លៃ ឈ្នួល កម្មករ, លើកដាក់, ថ្លៃឈ្នួលចម្លងនឹងត្រូវគិតទៅតាមទំនន់ទំនិញ និងចំងាយផ្លូវដឹកជញ្ជូន

ដូចមានកំណត់ក្នុងតារាងខាងក្រោម ÷

ប្រភេទទំនិញ	ចំងាយត្រឹម ៣ម៉ីល	រាល់១ម៉ីលដែលលើស
	ដុល្លារ/ត	ដុល្លារ/ត
១- ទំនិញចាក់ជា, វត្ថុរាវ លោហធាតុ	១,៥	០,០៥
២- ទំនិញដាក់បាវ	២	០,០៦
៣- ទំនិញដាក់ធុង, កេស	២,២	០,០៧
៤- ឈើអារ, ទំនិញផ្សេងៗ	២,៤	០,០៨

២១.២– ថ្លៃឈ្នួលចម្លងគិតតែថ្លៃឈ្នួលចល័នារបស់មធ្យោបាយចំលងទំនិញ ពីនាវាទៅស្ពានផែ ឬ ស្ពានផែ ទៅនាវា ដោយមិនរាប់បញ្ចូលថ្លៃឈ្នួលលើក ដាក់ ។

២១.៣– ថ្លៃឈ្នួលពិសេសសំរាប់ការចំលងទំនិញពីនាវាសែងលង្ហប់គ្រោះថ្នាក់ នឹងត្រូវផ្អែកលើកិច្ចព្រមព្រៀងដោយឡែក ។

ជំពូក IV

ថ្លៃឈ្នួលមធ្យោបាយ

២២– ឈ្នួលមធ្យោបាយដឹកជញ្ជូន លើកដាក់ និង សំភារៈផ្សេងៗ :

២២.១ – នាវាសណ្តោងអូសសាឡាង : ០,៣៥ដុល្លារ/សេះ/ម៉ោង
– នាវាសណ្តោងដឹកអ្នកដំណើរ : ០,២០ដុល្លារ/សេះ/ម៉ោង
– នាវាសណ្តោងប្រចាំការក្រោម : ០,១០ដុល្លារ/សេះ/ម៉ោង
– នាវាសណ្តោងលើសពី ១.០០០សេះ : ០,០៧ដុល្លារ/សេះ/ម៉ោង
– សាឡាងគ្មានម៉ាស៊ីន : ១,៨០ដុល្លារ/ហ្សេតេ/ថ្ងៃ
– អូប័រ : ១០០ដុល្លារ/ម៉ោង
– កាណូតចម្លង : ៣៥ដុល្លារ/ម៉ោង
– ឈ្នួលជញ្ជីងថ្លឹង : ០,៥០ដុល្លារ/តោន

២២.២–ឈ្នួលរថយន្ត :

–រថយន្តស្ទូចសមត្ថភាពលើស	៥តោន	២០ដុល្លារ/ម៉ោង
–រថយន្តស្ទូចសមត្ថភាពលើស	៥-១០តោន	៣០ដុល្លារ/ម៉ោង
–រថយន្តស្ទូចសមត្ថភាពលើស	១០-២៥តោន	៤០ដុល្លារ/ម៉ោង
–រថយន្តស្ទូចសមត្ថភាពលើស	២៥-៤០តោន	៦២ដុល្លារ/ម៉ោង
–រថយន្តស្ទូចសមត្ថភាពលើស	៤១-៥០តោន	២០ដុល្លារ/ម៉ោង
–រថយន្តស្ទូចសមត្ថភាពលើស	៥១-៨០តោន	១៥០ដុល្លារ/ម៉ោង
–Super Stacker		១៥០ដុល្លារ/ម៉ោង

២២.៣–ឈ្នួលរថចូក «អេឡេវ៉ាទ័រ» (អនុវត្តតែលើទំនិញទូទៅ)

–សមត្ថភាពលើកត្រឹម	៥តោន	១០ដុល្លារ/ម៉ោង
–សមត្ថភាពលើកពី	៦-១០តោន	១៥ដុល្លារ/ម៉ោង

–សមត្ថភាពលើកពី	១១-២០តោន	៣៥ដុល្លារ/ម៉ោង
–សមត្ថភាពលើកពី	២១-៣០តោន	៦០ដុល្លារ/ម៉ោង

២២.៤–រថយន្តដឹកជញ្ជូន :

–ក្បាលរថយន្តដឹកទំនិញ	៥ដុល្លារ/ម៉ោង
–រ៉ឺម៉កសណ្តោង «មិនគិតរថយន្ត ឬត្រាក់ទ័រ »	២ដុល្លារ/ម៉ោង
–ត្រាក់ទ័រ	២០ដុល្លារ/ម៉ោង
–ម៉ាស៊ីនផ្សំខ្យល់សំរាប់អ្នកមុជទឹក	១៥ដុល្លារ/ម៉ោង
–វិទ្យុទាក់ទងក្រៅប្រទេស	៤ដុល្លារ/ នាទី
–វិទ្យុទាក់ទងក្នុងប្រទេស	១,៣ដុល្លារ/នាទី

២២.៥–ពន្ធឆ្លងកាត់ផែ :

–អ្នកដំណើរទេសចរ ក្នុងមួយដំណើរឆ្លងកាត់ទីសំចតផែត្រូវបង់២ដុល្លារ/ម្នាក់ ។

២៣–របៀបគិតរយៈពេលជួល :

រយៈពេលជួល គឺគិតពីមល្បោចាយចេញទៅអនុវត្តការងាររហូតដល់មល្បោចាយត្រឡប់ដល់កន្លែងដើមវិញ ។ ចំពោះការជួលមល្បោចាយចេញក្រៅមូលដ្ឋានកំពង់ផែកំរិតអប្បបរិមា ត្រូវគិតពីម៉ោង ។ ឯក្នុងមណ្ឌលផែត្រូវគិតតាមរយៈពេលជាក់ស្តែង ។

២៤–ការបង្កើនអត្រាថ្លៃឈ្នួល :

ក–ជាតុវិទ្យុសកម្ម-គ្រឿងផ្ទុះ ជាតិគីមីអាចឆេះ នីត្រាត-នីត្រូមាសអាល់កាឡាំងមេតាន ម៉ាញេស្យូម-នីត្រូលូឡូស ផលិតផលផ្សេងៗដែលចេញពីជាតុទាំងអស់នេះ ត្រូវបង្កើន ថ្លៃឈ្នួល ១០០ភាគរយលើតំលៃមូលដ្ឋាន ។

ខ–វត្ថុធាតុពុល ឬអាចឆេះ ដូចជាប្រេងសាំង ប្រេងឥន្ធនៈគ្រប់ប្រភេទ ស្រាអេទែអា មូនីញាក់ ម្សៅកំបោរ ម្ទេសក្រៀម អាស៊ីតគ្រប់ប្រភេទ ឧស្ម័នល័ក្ខជ្រលក់ ថ្នាំសំលាប់ សត្វល្អិត ផ្សិតកួក ។ ល។ ត្រូវបង្កើន ៥០ភាគរយ ។

គ–ផលិតផលមានក្លិន មានធូលី ឬកខ្វក់ ដូចជាប្រេងកំបូណាហ្វូតាខ្មៅស៊ីម៉ង់ត៍ ជីគ្រប់ប្រភេទ ត្បូងរ៉ែផ្សេងៗ ម្សៅឆ្អឹងបង្កង ឆ្អឹងសត្វ អំបិល ត្រី និង

ផលិតផលហុយ និងមានគ្រោះថ្នាក់ផ្សេងៗទៀតដែលមិនទាន់រាប់ក្នុងក្រុម ក និង ខ ត្រូវបង្កើន ៣០ ភាគរយ ។

២៥—ប្រការអវសាន :

បណ្តាថ្លៃឈ្នួលទាំងឡាយដែលពុំបានកំណត់ក្នុងប្រកាសនេះ ក្នុងគ្រាអនុវត្ត អាជ្ញាធរកំពង់ផែ និង អតិថិជនអាចនឹងធ្វើការសំរបសំរួលគ្នា សំដៅជានាផលប្រយោជន៍ទាំងទ្វេភាគី និងធានាដល់សង្វាក់ការងារ ។

ឧបនាយករដ្ឋមន្ត្រី
រដ្ឋមន្ត្រីក្រសួងសាធារណការនិងដឹកជញ្ជូន
ហត្ថលេខានិងត្រា
អ៊ុង ហឿត

* * *

៤- ទីស្តីការរដ្ឋមន្ត្រីក្រសួងពត៌មាន

ប្រកាស

រាជធានីភ្នំពេញ , ថ្ងៃទី ១៧ ខែ មករា ឆ្នាំ ១៩៩៧

ប្រកាសលេខ ០១៩/៩៧ ពម.ប្រក

– បានឃើញរដ្ឋធម្មនុញ្ញ នៃព្រះរាជាណាចក្រកម្ពុជា ជំពូក ៣ មាត្រាទី ៤១
– បានឃើញព្រះរាជក្រឹត្យរបស់ព្រះបាទសម្តេច ព្រះនរោត្តម សីហនុ វរ្ម័ន ព្រះមហាក្សត្រនៃព្រះរាជា ណាចក្រកម្ពុជា ចុះថ្ងៃទី ០១ ខែ វិច្ឆិកា ឆ្នាំ ១៩៩៣ ស្តីពីការតែងតាំងរាជរដ្ឋាភិបាល នៃព្រះរាជា ណាចក្រកម្ពុជា

– បានឃើញច្បាប់ស្ដីពីរបបសារពត៌មាន នៃព្រះរាជាណាចក្រកម្ពុជា ដែលប្រកាសអោយប្រើតាម ព្រះរាជក្រមលេខ ន.ស រ ក.ម ០៨៩៥-០៧ ចុះថ្ងៃទី ០១ ខែ កញ្ញា ឆ្នាំ ១៩៩៥

– បានឃើញសំណើសុំផ្ទេរសិទ្ធិនិពន្ធនាយករបស់លោក លឹម អែលឡារ៉ាដូ ចុះថ្ងៃទី ៩ ខែ សីហា ឆ្នាំ ១៩៩៦

សំរេច

ប្រការ ១ : អនុញ្ញាតអោយលោក លឹម អែលឡារ៉ាដូ ផ្ទេរសិទ្ធិ និពន្ធនាយកទស្សនាវដ្ដី «ជីវិតរីករាយ» ជូនទៅលោកស្រី **សរ សុរិយា** និពន្ធ នាយិកា ជំនួសវិញ ។ ទីស្នាក់ការផ្ទះលេខ ៩ ផ្លូវលេខ ៦០០ សង្កាត់បឹងកក់ ខ័ណ្ឌទួលគោក រាជធានីភ្នំពេញ ។ ក្នុងករណីមានការផ្លាស់ប្ដូរនូវចំណុចណាមួយ ក្នុងអត្តសញ្ញាណ នៃទស្សនាវដ្ដីរបស់ខ្លួនត្រូវជូនដំណឹងជាមុន ៥ថ្ងៃ មកក្រសួងពត៌មាន ដើម្បីរង់ចាំសេចក្ដីសំរេចថ្មី ។

ប្រការ ២ : រាល់ដំណើរការបោះពុម្ពចែកផ្សាយត្រូវគោរពតាមគោលការណ៍ក្រមសីលធម៌ អ្នកសារពត៌មាន និង ឈរលើស្មារតីទទួលខុសត្រូវខ្ពស់ក្នុងវិជ្ជាជីវៈរបស់ខ្លួន ។ ខ្លឹមសារ អត្ថបទត្រូវអនុវត្តន៍អោយបានសមស្របតាមទំនៀមទំលាប់ប្រពៃណីល្អ និងច្បាប់ នៃព្រះរាជាណាចក្រកម្ពុជា និងស្នើប្រគល់ទស្សនាវដ្ដីចំនួន ០៦ច្បាប់ រៀងរាល់ លេខចេញផ្សាយមកតំកល់ទុកជាឯកសារនៅក្រសួងពត៌មាន ។

ប្រការ ៣ : ក្នុងករណីប្រព្រឹត្តិល្មើសអំពីសេចក្ដីដូចមានចែងក្នុងប្រការ១ និងប្រការ២ ខាងលើនេះសាម៉ីខ្លួនត្រូវ ទទួលទោសតាមច្បាប់ជាធរមាន ។

ប្រការ ៤ : អគ្គនាយករដ្ឋបាលនិងហិរញ្ញវត្ថុ ប្រធាននាយកដ្ឋានមណ្ឌលពត៌មាន នៃក្រសួងពត៌មាន និង លោកស្រី **សរ សុរិយា** ត្រូវអនុវត្តន៍នូវប្រកាសនេះ ។

ប្រការ ៥ : ប្រកាសនេះមានប្រសិទ្ធភាពរយៈពេល ២ឆ្នាំ និងចូលជាធរមាន ចាប់ពីថ្ងៃចុះហត្ថលេខានេះតទៅ។

រដ្ឋមន្ត្រី
រដ្ឋលេខាធិការ
ហត្ថលេខានិងត្រា
ខៀវ កាញារីទ្ធ

* * *

រាជធានីភ្នំពេញ , ថ្ងៃទី ២១ ខែ មករា ឆ្នាំ ១៩៩៧

ប្រកាសលេខ ០២០/៩៧ ពម.ប្រក

- បានឃើញរដ្ឋធម្មនុញ្ញ នៃព្រះរាជាណាចក្រកម្ពុជា ជំពូក ៣ មាត្រាទី ៤១
- បានឃើញព្រះរាជក្រឹត្យរបស់ព្រះបាទសម្តេច ព្រះនរោត្តម សីហនុ វរ្ម័ន ព្រះមហាក្សត្រនៃព្រះរាជាណាចក្រកម្ពុជា ចុះថ្ងៃទី ០១ ខែ វិច្ឆិកា ឆ្នាំ ១៩៩៣ ស្តីពីការតែងតាំងរាជរដ្ឋាភិបាល នៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញច្បាប់ស្តីពីរបបសារពត៌មាន នៃព្រះរាជាណាចក្រកម្ពុជា ដែលប្រកាសអោយប្រើតាមព្រះរាជក្រមលេខ ន.ស/រ ក.ម ០៨៩៥-០៧ ចុះថ្ងៃទី ០១ ខែ កញ្ញា ឆ្នាំ ១៩៩៥
- បានឃើញសំណើសុំបោះពុម្ពបន្ថែមកាសែត «ព្រលឹងជាតិ» ផ្សាយជាភាសាចិន ចុះថ្ងៃទី ៣ ខែ មិថុនា ឆ្នាំ ១៩៩៦

សំរេច

ប្រការ ១ : អនុញ្ញាតអោយចេញផ្សាយសារពត៌មាន « ព្រលឹងជាតិ» ចេញផ្សាយជាភាសាចិន បោះពុម្ពចែកផ្សាយ ដោយមានលោក **ជួន ម៉ុនឆៀន** ជាថៅកែការផ្សាយ ។ ទីស្នាក់ការលេខ៣០៤ ផ្លូវលេខ ២២៨ វិថីព្រះមុនីវង្ស ខ័ណ្ឌដូនពេញ ភ្នំពេញ ។

ក្នុងករណីមានការផ្លាស់ប្តូរចំណុចណាមួយ ក្នុងអត្តសញ្ញាណ នៃកាសែតរបស់ខ្លួន ត្រូវជូនដំណឹងជាមុន ៥ថ្ងៃ មកក្រសួងពតិមាន ដើម្បីរង់ចាំសេចក្តីសំរេចជាថ្មី ។

ប្រការ ២ : រាល់ដំណើរការបោះពុម្ពចែកផ្សាយ ត្រូវគោរពតាមគោលការណ៍ក្រមសីលធម៌អ្នកកាសែត និង ឈរលើស្មារតីទទួលខុសត្រូវខ្ពស់ក្នុងវិជ្ជាជីវៈរបស់ខ្លួន ។ ខ្លឹមសារអត្ថបទត្រូវអនុវត្តន៍អោយបាន សមស្របតាមទំនៀមទំលាប់ប្រពៃណីល្អ និងច្បាប់នៃព្រះរាជាណាចក្រកម្ពុជា រួចស្នើប្រគល់កាសែត ចំនួន ០៦ច្បាប់ រៀងរាល់លេខចេញផ្សាយមកតំកល់ទុកជាឯកសារនៅក្រសួងពតិមាន ។

ប្រការ ៣ : ក្នុងករណីប្រព្រឹត្តិល្មើសអំពីសេចក្តីដូចមានចែងក្នុងប្រការ១ និងប្រការ២ ខាងលើ សាម៉ីខ្លួនត្រូវ ទទួលទោសតាមច្បាប់ជាធរមាន ។

ប្រការ ៤ : អគ្គនាយករដ្ឋបាលនិងហិរញ្ញវត្ថុ ប្រធាននាយកដ្ឋានមណ្ឌលពតិមាន នៃក្រសួងពតិមាន និងចាងហ្វាងកាសែត «ព្រលឹងជាតិ» ជាភាសាចិន ត្រូវអនុវត្តន៍នូវប្រកាសនេះ ។

ប្រការ ៥ : ប្រកាសនេះមានប្រសិទ្ធភាពរយៈពេល ២ឆ្នាំ និងចូលជាធរមានចាប់ពីថ្ងៃចុះហត្ថលេខានេះតទៅ ។

រដ្ឋមន្ត្រី
រដ្ឋលេខាធិការ
ហត្ថលេខានិងត្រា
ខៀវ កាញារិទ្ធ

* * *

រាជធានីភ្នំពេញ , ថ្ងៃទី ២១ ខែ មករា ឆ្នាំ ១៩៩៧

ប្រកាសលេខ ០២១/៩៧ ពម.ប្រក

–បានឃើញរដ្ឋធម្មនុញ្ញ នៃព្រះរាជាណាចក្រកម្ពុជា ជំពូក ៣ មាត្រាទី ៤១

- បានឃើញព្រះរាជក្រឹត្យរបស់ព្រះបាទសម្តេច ព្រះនរោត្តម សីហនុ វរ្ម័ន ព្រះមហាក្សត្រនៃព្រះរាជាណាចក្រកម្ពុជា ចុះថ្ងៃទី ០១ ខែ វិច្ឆិកា ឆ្នាំ ១៩៩៣ ស្តីពីការតែងតាំងរាជរដ្ឋាភិបាល នៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញច្បាប់ស្តីពីរបបសារពត៌មាន នៃព្រះរាជាណាចក្រកម្ពុជា ដែលប្រកាសអោយប្រើតាម ព្រះរាជក្រមលេខ ន.ស/ រ.ក.ម ០៨៩៥-០៧ ចុះថ្ងៃទី ០១ ខែ កញ្ញា ឆ្នាំ ១៩៩៥
- បានឃើញសំណើចេញផ្សាយសារពត៌មាន «កុលបុត្រអង្គរ» បន្តឡើងវិញ របស់លោក គង្គ សុវណ្ណារិ ចុះថ្ងៃទី ០៩ ខែ កញ្ញា ឆ្នាំ ១៩៩៦

សំរេច

ប្រការ ១ : អនុញ្ញាតអោយសារពត៌មាន « កុលបុត្រអង្គរ » បន្តការចេញផ្សាយឡើងវិញ ដោយមានលោក គង្គ សុវណ្ណារិ ជាចាងហ្វាងការផ្សាយ ។ ទីស្នាក់ការផ្ទះលេខ ៤៧០ ផ្លូវលេខ ១៣៦ សង្កាត់បឹង កេងកង៣ ខ័ណ្ឌចំការមន ក្រុងភ្នំពេញ ។ ក្នុងករណីមានការផ្លាស់ប្តូរនូវចំណុចណាមួយក្នុងអត្តសញ្ញាណនៃកាសែតរបស់ខ្លួនត្រូវជូនដំណឹងជាមុន៥ថ្ងៃមកក្រសួងពត៌មាន ដើម្បីរង់ចាំសេចក្តី សំរេចជាថ្មី ។

ប្រការ ២ : រាល់ដំណើរការបោះពុម្ពចែកផ្សាយ ត្រូវគោរពតាមគោលការណ៍ក្រមសីលធមិអ្នកកាសែត និង ឈរលើស្មារតីទទួលខុសត្រូវខ្ពស់ក្នុងវិជ្ជាជីវៈរបស់ខ្លួន ។ ខ្លឹមសារអត្ថបទត្រូវអនុវត្តន៍អោយបានសមស្របតាមទំនៀមទំលាប់ប្រពៃណីល្អ និងច្បាប់នៃព្រះរាជាណាចក្រកម្ពុជា និងស្នើប្រគល់កាសែតចំនួន ០៦ច្បាប់ រៀងរាល់លេខចេញផ្សាយមកតំកល់ទុកជាឯកសារនៅក្រសួងពត៌មាន ។

ប្រការ ៣ : ក្នុងករណីប្រព្រឹត្តិល្មើសអំពីសេចក្តីដូចមានចែងក្នុងប្រការ១ និងប្រការ២ ខាងលើនេះ សាម៉ីខ្លួនត្រូវទទួលទោសតាមច្បាប់ជាធរមាន ។

ប្រការ ៤ : អគ្គនាយករដ្ឋបាលនិងហិរញ្ញវត្ថុ ប្រធាននាយកដ្ឋានមណ្ឌលពត៌មាន នៃក្រសួងពត៌មាន និង ចាងហ្វាងកាសែត «កុលបុត្រអង្គរ» ត្រូវអនុវត្តន៍នូវប្រកាសនេះ ។

ប្រការ ៥ : ប្រកាសនេះមានប្រសិទ្ធភាពរយៈពេល ២ឆ្នាំ និងចូលជាធរមាន ចាប់ពីថ្ងៃចុះហត្ថលេខានេះតទៅ ។

រដ្ឋមន្ត្រី
រដ្ឋលេខាធិការ
ហត្ថលេខានិងត្រា
ខៀវ កាញារីទ្ធ

* * *

៥- និស្តិការរដ្ឋមន្ត្រីក្រសួងអប់រំយុវជន និង កីឡា

ប្រកាស

រាជធានីភ្នំពេញ , ថ្ងៃទី ១៦ ខែ មករា ឆ្នាំ ១៩៩៧

ប្រកាសលេខ ៤៧ អយក.ប្រក

ស្តីពីការបើកអនុវិទ្យាល័យសម្តេចក្រុមព្រះ នរោត្តម រណឫទ្ធិ
ក្នុងឃុំអូរអំបិល ស្រុកសិរីសោភ័ណ ខេត្តបន្ទាយមានជ័យ

* * *

រដ្ឋមន្ត្រីក្រសួងអប់រំ យុវជន និងកីឡា

- បានឃើញព្រះរាជក្រឹត្យរបស់ព្រះករុណាព្រះបាទ សម្តេចនរោត្តម **សីហនុ វរ្ម័ន** ព្រះមហាក្សត្រនៃ ព្រះរាជាណាចក្រកម្ពុជា ចុះថ្ងៃទី ០១ ខែ វិច្ឆិកា ឆ្នាំ ១៩៩៣ ស្តីពីការតែងតាំងរាជរដ្ឋាភិបាលកម្ពុជា
- បានឃើញច្បាប់ស្តីពីការរៀបចំ និងការប្រព្រឹត្តទៅនៃគណៈរដ្ឋមន្ត្រី ដែលប្រកាសអោយប្រើដោយ ព្រះរាជក្រម ចុះថ្ងៃទី ២០ ខែ កក្កដា ឆ្នាំ ១៩៩៤
- ឃើញព្រះរាជក្រឹត្យលេខ នស/រកត/០៧៩៦/៥២ ចុះថ្ងៃទី ២៦ ខែ កក្កដា ឆ្នាំ ១៩៩៦ ស្តីពី ប្រព័ន្ធអប់រំចំណេះទូទៅ ១២ឆ្នាំ

-បានឃើញសារាចរណែនាំលេខ ៦៦ អរ.ចទម ចុះថ្ងៃទី ០២ ខែ មេសា ឆ្នាំ ១៩៨៣ ស្ដីពីការ បើកសាលាមធ្យមសិក្សាកំរិត ១ - កំរិត ២

-យោងលិខិតស្នើរបស់មន្ទីរអប់រំយុវជន និង កីឡា ខេត្តបន្ទាយមានជ័យ លេខ ២៥០០ ចុះថ្ងៃទី ១០ ខែ កក្កដា ឆ្នាំ ១៩៩៦ ដោយមានយោបល់ឯកភាពពី អភិបាលខេត្តបន្ទាយមានជ័យ

-តាមយោបល់ឯកភាពរបស់នាយកដ្ឋានចំណេះទូទៅ និង មត្តេយ្យសិក្សា

សំរេច

ប្រការ ១ : អនុញ្ញាតអោយមន្ទីរអប់រំយុវជន និង កីឡាខេត្តបន្ទាយមានជ័យបើកអនុវិទ្យាល័យ ដែលមានឈ្មោះថាអនុវិទយាល័យ សម្ដេចក្រុមព្រះនរោត្តមរណឫទ្ធិ «អូរអំបិល» ចាប់ពីឆ្នាំសិក្សា ១៩៩៦- ៩៧ តទៅ ។

ប្រការ ២ : អនុវិទ្យាល័យនេះត្រូវដឹកនាំដោយនាយកមួយរូប. និង នាយករងតាមការចាំបាច់ ព្រមទាំងបុគ្គលិក ផ្សេងៗមួយចំនួនទៀតតាមអង្គការលេខនៃអនុវិទ្យាល័យ ។

ប្រការ ៣ : នាយក- នាយករងនៃអនុវិទ្យាល័យ មានសិទ្ធិទទួលប្រាក់បំណាច់ភារកិច្ចរបស់ នាយក-នាយករង នៃ អនុវិទ្យាល័យ ។

ប្រការ ៤ : ប្រធានមន្ទីរ ប្រធាននាយកដ្ឋានចំណេះទូទៅ និងមត្តេយ្យសិក្សា ប្រធាននាយកដ្ឋានបុគ្គលិក-ប្រធាននាយកដ្ឋានផែនការ និងហិរញ្ញកិច្ច នៃក្រសួងអប់រំយុវជន និង កីឡា ប្រធានមន្ទីរអប់រំ យុវជន និង កីឡា ខេត្តបន្ទាយមានជ័យ និង អនុវិទ្យាល័យសាមីមានភារកិច្ចរៀងៗ ខ្លួន អនុវត្តប្រកាសនេះ ។

ជ.រដ្ឋមន្ត្រីក្រសួងអប់រំ យុវជន និង កីឡា
រដ្ឋលេខាធិការ
ហត្ថលេខានិងត្រា

គា សោឃន

* * *

រាជធានីភ្នំពេញ , ថ្ងៃទី ១៦ ខែ មករា ឆ្នាំ ១៩៩៧

ប្រកាសលេខ ៤៨ អយក.ប្រក

ស្ដីពីការបើកអនុវិទ្យាល័យ ម៉ិន រ៉ានី ហ៊ុន សែន «ស្វាយម»

ក្នុងឃុំរទៀង ស្រុកសំរោង ខេត្តតាកែវ

* * *

រដ្ឋមន្ត្រីក្រសួងអប់រំយុវជន និង កីឡា

- បានឃើញព្រះរាជក្រឹត្យរបស់ព្រះករុណាព្រះបាទសម្ដេចព្រះនរោត្តម **សីហនុ វរ្ម័ន** ព្រះមហាក្សត្រនៃ ព្រះរាជាណាចក្រកម្ពុជា ចុះថ្ងៃទី ០១ ខែ វិច្ឆិកា ឆ្នាំ ១៩៩៣ ស្ដីពីការតែងតាំងរាជរដ្ឋាភិបាលកម្ពុជា
- បានឃើញច្បាប់ស្ដីពីការរៀបចំ និងការប្រព្រឹត្តទៅនៃគណៈរដ្ឋមន្ត្រី ដែលប្រកាសអោយប្រើដោយព្រះរាជក្រម ចុះថ្ងៃទី ២០ ខែ កក្កដា ឆ្នាំ ១៩៩៤
- ឃើញព្រះរាជក្រឹត្យលេខ នស/រកត/០៧៩៦/៥២ ចុះថ្ងៃទី ២៦ ខែ កក្កដា ឆ្នាំ ១៩៩៦ ស្ដីពី ប្រព័ន្ធអប់រំចំណេះទូទៅ ១២ឆ្នាំ
- បានឃើញសារាចរណែនាំលេខ ៦៦ អវ.ចទម ចុះថ្ងៃទី ០២ ខែ មេសា ឆ្នាំ ១៩៨៣ ស្ដីពីការ បើកសាលាមធ្យមសិក្សាកំរិត ១ – កំរិត ២
- យោងលិខិតស្នើសុំរបស់មន្ទីរអប់រំយុវជន និង កីឡា ខេត្តតាកែវ លេខ ៣៣០៩ អយក.ត មស ចុះថ្ងៃទី ១៣ ខែ កញ្ញា ឆ្នាំ ១៩៩៦ ដោយមានយោបល់ឯកភាពពី អភិបាលខេត្តតាកែវ
- តាមយោបល់ឯកភាពរបស់នាយកដ្ឋានចំណេះទូទៅ និង មត្តេយ្យសិក្សា

សំរេច

ប្រការ ១ : អនុញ្ញាតអោយមន្ទីរអប់រំយុវជន និង កីឡាខេត្តតាកែវ បើកអនុវិទ្យាល័យ ដែលមានឈ្មោះថា អនុវិទ្យាល័យ **ម៉ិន រ៉ានី ហ៊ុន សែន** «ស្វាយម» ចាប់ពីឆ្នាំសិក្សា ១៩៩៦–៩៧ តទៅ ។

ប្រការ ២ : អនុវិទ្យាល័យនេះ ត្រូវដឹកនាំដោយនាយកមួយរូប និង នាយករងតាមការចាំបាច់ ព្រមទាំងបុគ្គលិក ផ្សេងៗមួយចំនួនទៀតតាមអង្គការលេខនៃអនុវិទ្យាល័យ ។

ប្រការ ៣ : នាយក- នាយករងនៃអនុវិទ្យាល័យ មានសិទ្ធិទទួលប្រាក់បំណាច់ភារកិច្ច របស់ នាយក-នាយករង នៃ អនុវិទ្យាល័យ ។

ប្រការ ៤ : ប្រធានមន្ទីរ ប្រធាននាយកដ្ឋានចំណេះទូទៅ និង មត្តេយ្យសិក្សា ប្រធាននាយកដ្ឋានបុគ្គលិក- ប្រធាននាយកដ្ឋានផែនការ និង ហិរញ្ញកិច្ច នៃក្រសួងអប់រំ យុវជន និង កីឡា ប្រធានមន្ទីរអប់រំ យុវជននិងកីឡាខេត្តតាកែវ និង អនុវិទ្យាល័យសាមីមានភារកិច្ចរៀងៗខ្លួនអនុវត្តប្រកាសនេះ ។

ជ.រដ្ឋមន្ត្រីក្រសួងអប់រំ យុវជន និង កីឡា

រដ្ឋលេខាធិការ

ហត្ថលេខានិងត្រា

គា សាហន

* * *

រាជធានីភ្នំពេញ , ថ្ងៃទី ១៦ ខែ មករា ឆ្នាំ ១៩៩៧

ប្រកាសលេខ ៤៩ អយក.ប្រក

ស្តីពីការបើកអនុវិទ្យាល័យ ហ៊ុន សែន «ត្នោតជុំ» ក្នុងឃុំអូរសារាយ ស្រុកត្រាំកក់ ខេត្តតាកែវ

* * *

រដ្ឋមន្ត្រីក្រសួងអប់រំយុវជន និង កីឡា

- បានឃើញព្រះរាជក្រឹត្យរបស់ព្រះករុណាព្រះបាទសម្តេច **នរោត្តម សីហនុ វរ្ម័ន** ព្រះមហាក្សត្រនៃ ព្រះរាជាណាចក្រកម្ពុជា ចុះថ្ងៃទី ០១ ខែ វិច្ឆិកា ឆ្នាំ ១៩៩៣ ស្តីពីការតែងតាំងរាជរដ្ឋាភិបាល កម្ពុជា
- បានឃើញច្បាប់ស្តីពីការរៀបចំ និងការប្រព្រឹត្តទៅនៃគណៈរដ្ឋមន្ត្រី ដែលប្រកាសអោយប្រើដោយ ព្រះរាជក្រម ចុះថ្ងៃទី ២០ ខែ កក្កដា ឆ្នាំ ១៩៩៤

-បានឃើញព្រះរាជក្រឹត្យលេខ នស/រកត/០៧៩៦/៥២ ចុះថ្ងៃទី ២៦ ខែ កក្កដា ឆ្នាំ ១៩៩៦ ស្តីពី ប្រព័ន្ធអប់រំចំណេះទូទៅ ១២ឆ្នាំ

-បានឃើញសារាចរណែនាំលេខ ៦៦ អរ.ចទម ចុះថ្ងៃទី ០២ ខែ មេសា ឆ្នាំ ១៩៨៣ ស្តីពីការ បើកសាលាមធ្យមសិក្សាកំរិត ១ – កំរិត ២

-យោងលិខិតស្នើសុំរបស់មន្ទីរអប់រំ យុវជន និង កីឡា ខេត្តតាកែវ លេខ ៣៣១០ អយក.ត មស ចុះថ្ងៃទី ១៣ ខែ កញ្ញា ឆ្នាំ ១៩៩៦ ដោយមានយោបល់ឯកភាពពីអភិបាលខេត្តតាកែវ

-តាមយោបល់ឯកភាពរបស់នាយកដ្ឋានចំណេះទូទៅ និង មត្តេយ្យសិក្សា

សំរេច

ប្រការ ១ : អនុញ្ញាតអោយមន្ទីរអប់រំយុវជន និង កីឡាខេត្តតាកែវ បើកអនុវិទ្យាល័យ ដែលមានឈ្មោះថា អនុវិទ្យាល័យ ហ៊ុន សែន «ត្នោតជុំ» ចាប់ពីឆ្នាំសិក្សា ១៩៩៦–៩៧ តទៅ ។

ប្រការ ២ : អនុវិទ្យាល័យនេះ ត្រូវដឹកនាំដោយនាយកមួយរូប និង នាយករងតាមការចាំបាច់ ព្រមទាំងបុគ្គលិក ផ្សេងៗមួយចំនួនទៀតតាមអង្គការលេខនៃអនុវិទ្យាល័យ ។

ប្រការ ៣ : នាយក- នាយករងនៃអនុវិទ្យាល័យ មានសិទ្ធិទទួលប្រាក់បំណាច់ភារកិច្ចរបស់នាយក–នាយករង នៃអនុវិទ្យាល័យ ។

ប្រការ ៤ : ប្រធានមន្ទីរ ប្រធាននាយកដ្ឋានចំណេះទូទៅ និង មត្តេយ្យសិក្សា ប្រធាននាយកដ្ឋានបុគ្គលិក– ប្រធាននាយកដ្ឋានផែនការ និង ហិរញ្ញកិច្ច នៃក្រសួងអប់រំ យុវជន និង កីឡា ប្រធានមន្ទីរអប់រំ យុវជននិងកីឡាខេត្តតាកែវ និងអនុវិទ្យាល័យសាមី មានភារកិច្ចរៀងៗខ្លួនអនុវត្តប្រកាសនេះ ។

ជ.រដ្ឋមន្ត្រីក្រសួងអប់រំ យុវជន និង កីឡា
រដ្ឋលេខាធិការ
ហត្ថលេខានិងត្រា
គា សាឃាន

* * *

រាជធានីភ្នំពេញ , ថ្ងៃទី ១៦ ខែ មករា ឆ្នាំ ១៩៩៧

ប្រកាសលេខ ៥០ អយក.ប្រក

ស្តីពីការពង្រីកអនុវិទ្យាល័យបាធាយ ទៅជាវិទ្យាល័យបាធាយ

ក្នុងស្រុកបាធាយ ខេត្តកំពង់ចាម

* * *

រដ្ឋមន្ត្រីក្រសួងអប់រំយុវជន និង កីឡា

–បានឃើញព្រះរាជក្រឹត្យរបស់ព្រះករុណាព្រះបាទសម្តេច **នរោត្តម សីហនុ វរ្ម័ន** ព្រះមហាក្សត្រនៃ ព្រះរាជាណាចក្រកម្ពុជា ចុះថ្ងៃទី ០១ ខែ វិច្ឆិកា ឆ្នាំ ១៩៩៣ ស្តីពីការតែងតាំងរាជរដ្ឋាភិបាលកម្ពុជា

–បានឃើញច្បាប់ស្តីពីការរៀបចំ និងការប្រព្រឹត្តទៅនៃគណៈរដ្ឋមន្ត្រី ដែលប្រកាសអោយប្រើដោយ ព្រះរាជក្រម ចុះថ្ងៃទី ២០ ខែ កក្កដា ឆ្នាំ ១៩៩៤

–បានឃើញព្រះរាជក្រឹត្យលេខ នស/រកត/០៧៩៦/៥២ ចុះថ្ងៃទី ២៦ ខែ កក្កដា ឆ្នាំ ១៩៩៦ ស្តីពី ប្រព័ន្ធអប់រំចំណេះទូទៅ ១២ឆ្នាំ

–បានឃើញសារាចរណែនាំលេខ ៦៦ អរ.ចទម ចុះថ្ងៃទី ០២ ខែ មេសា ឆ្នាំ ១៩៨៣ ស្តីពីការ បើកសាលាមធ្យមសិក្សាកំរិត ១ – កំរិត ២

–យោងលិខិតស្នើរបស់គណៈកម្មការទ្រទ្រង់អនុវិទ្យាល័យបាធាយ ចុះថ្ងៃទី ២០ មិថុនា ១៩៩៦ ដោយមានយោបល់ឯកភាពពីមន្ទីរអប់រំ យុវជន និង កីឡា និងអភិបាលខេត្តកំពង់ចាម

–តាមយោបល់ឯកភាពរបស់នាយកដ្ឋានចំណេះទូទៅ និង មត្តេយ្យសិក្សា

សំរេច

ប្រការ ១ : អនុញ្ញាតអោយពង្រីកអនុវិទ្យាល័យ បាធាយ បច្ចុប្បន្នទៅជាវិទ្យាល័យបាធាយ ចាប់ពីឆ្នាំសិក្សា ១៩៩៦–៩៧ តទៅ ។

ប្រការ ២ : វិទ្យាល័យនេះ ត្រូវដឹកនាំដោយនាយកមួយរូប និងនាយករងតាមការចាំបាច់ ព្រមទាំងបុគ្គលិក ផ្សេងៗមួយចំនួនទៀតតាមអង្គការលេខនៃវិទ្យាល័យ ។

ប្រការ ៣ : នាយក-នាយករងនៃវិទ្យាល័យ មានសិទ្ធិទទួលប្រាក់បំណាច់ភារកិច្ចរបស់នាយក នាយករង នៃវិទ្យាល័យ ។

ប្រការ ៤ : ប្រធានមន្ទីរ ប្រធាននាយកដ្ឋានចំណេះទូទៅ និង មត្តេយ្យសិក្សា ប្រធាននាយកដ្ឋានបុគ្គលិក- ប្រធាននាយកដ្ឋានផែនការ និង ហិរញ្ញកិច្ច នៃក្រសួងអប់រំ យុវជន និង កីឡា ប្រធានមន្ទីរអប់រំ យុវជននិងកីឡាខេត្តកំពង់ចាម និង វិទ្យាល័យសាមីមានភារកិច្ចរៀងៗខ្លួនអនុវត្តប្រកាសនេះ ។

ជ.រដ្ឋមន្ត្រីក្រសួងអប់រំ យុវជន និង កីឡា
រដ្ឋលេខាធិការ
ហត្ថលេខានិងត្រា
គា សាឃាន

* * *

រាជធានីភ្នំពេញ , ថ្ងៃទី ១៦ ខែ មករា ឆ្នាំ ១៩៩៧

ប្រកាសលេខ ៥១ អយក.ប្រក

ស្តីពីការផ្លាស់ប្តូរវិទ្យាល័យ អន្លង់វែង ឧបសម្ព័ន្ធ នៃវិទ្យាល័យសម្តេចឪនៅជា វិទ្យាល័យ អន្លង់វែង ក្នុងស្រុកសំរោង ខេត្តតាកែវ

* * * *

រដ្ឋមន្ត្រីក្រសួងអប់រំយុវជន និង កីឡា

-បានឃើញព្រះរាជក្រឹត្យរបស់ព្រះករុណាព្រះបាទសម្តេច **នរោត្តម សីហនុ វរ្ម័ន** ព្រះមហាក្សត្រនៃ ព្រះរាជាណាចក្រកម្ពុជា ចុះថ្ងៃទី ០១ ខែ វិច្ឆិកា ឆ្នាំ ១៩៩៣ ស្តីពីការតែងតាំងរាជរដ្ឋាភិបាលកម្ពុជា

-បានឃើញច្បាប់ស្តីពីការរៀបចំ និង ការប្រព្រឹត្តទៅនៃគណៈរដ្ឋមន្ត្រីដែលប្រកាសអោយប្រើដោយព្រះរាជក្រម ចុះថ្ងៃទី ២០ ខែ កក្កដា ឆ្នាំ ១៩៩៤

-បានឃើញព្រះរាជក្រឹត្យលេខ នស/រកត/០៧៩៦/៥២ ចុះថ្ងៃទី ២៦ ខែ កក្កដា ឆ្នាំ ១៩៩៦ ស្តីពីប្រព័ន្ធអប់រំចំណេះទូទៅ ១២ឆ្នាំ

-បានឃើញសារាចរណែនាំលេខ ៦៦ អរ.ចទម ចុះថ្ងៃទី ០២ ខែ មេសា ឆ្នាំ ១៩៨៣ ស្តីពីការ បើកសាលាមធ្យមសិក្សាកំរិត ១ - កំរិត ២

-យោងលិខិតស្នើសុំរបស់មន្ទីរអប់រំ យុវជន និង កីឡា ខេត្តតាកែវ លេខ ១៣២៥ អយក.ត មស ចុះថ្ងៃទី ២១ ខែ កុម្ភៈ ឆ្នាំ ១៩៩៦ ដោយមានយោបល់ឯកភាពពីអភិបាលខេត្តតាកែវ

-តាមយោបល់ឯកភាពរបស់នាយកដ្ឋានចំណេះទូទៅ និង មត្តេយ្យសិក្សា

សំរេច

ប្រការ ១ : អនុញ្ញាតអោយផ្លាច់វិទ្យាល័យ អង្គប្រីយ៍ ឧបសម្ព័ន្ធ វិទ្យាល័យសម្តេចឳ ទៅជាវិទ្យាល័យអង្គប្រីយ៍ ចាប់ពីឆ្នាំសិក្សា ១៩៩៦-៩៧ តទៅ ។

ប្រការ ២ : វិទ្យាល័យនេះ ត្រូវដឹកនាំដោយនាយកមួយរូប និងនាយករងតាមការចាំបាច់ ព្រមទាំងបុគ្គលិកផ្សេងៗ មួយចំនួនទៀតតាមអង្គការលេខនៃវិទ្យាល័យ ។

ប្រការ ៣ : នាយក- នាយករងនៃវិទ្យាល័យ មានសិទ្ធិទទួលប្រាក់បំណាច់ភារកិច្ចរបស់នាយក-នាយករង នៃវិទ្យាល័យ ។

ប្រការ ៤ : បទបញ្ញត្តិទាំងឡាយណាដែលមានខ្លឹមសារផ្ទុយពីប្រកាសនេះ ត្រូវចាត់ទុកជានិរាករណ៍ ។

ប្រការ ៥ : ប្រធានមន្ទីរ ប្រធាននាយកដ្ឋានចំណេះទូទៅ និង មត្តេយ្យសិក្សា ប្រធាននាយកដ្ឋានបុគ្គលិក- ប្រធាននាយកដ្ឋានផែនការ និង ហិរញ្ញកិច្ច នៃក្រសួងអប់រំ យុវជន និង កីឡា ប្រធានមន្ទីរអប់រំ យុវជននិងកីឡាខេត្តតាកែវ និងនាយក

វិទ្យាល័យសាម៉ីមានភារកិច្ចរៀងៗខ្លួនអនុវត្តប្រកាសនេះ ។

ជ.រដ្ឋមន្ត្រីក្រសួងអប់រំ យុវជន និង កីឡា

រដ្ឋលេខាធិការ

ហត្ថលេខានិងត្រា

គា សាហាន

* * *

រាជធានីភ្នំពេញ , ថ្ងៃទី ២១ ខែ មករា ឆ្នាំ ១៩៩៧

ប្រកាសលេខ ៦៤ អយក.ប្រក

ស្តីពីការប្តូរឈ្មោះសាលាបឋមសិក្សាបណ្ណុះវិជ្ជា

មកជាសាលាបឋមសិក្សាសុធារស

* * * *

រដ្ឋមន្ត្រីក្រសួងអប់រំ យុវជន និង កីឡា

- បានឃើញរដ្ឋធម្មនុញ្ញ នៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រឹត្យរបស់ព្រះករុណាព្រះបាទសម្តេច **នរោត្តម សីហនុ វរ្ម័ន** ព្រះមហាក្សត្រនៃ ព្រះរាជាណាចក្រកម្ពុជា ចុះថ្ងៃទី ០១ ខែ វិច្ឆិកា ឆ្នាំ ១៩៩៣ ស្តីពីការតែងតាំងរាជរដ្ឋាភិបាល កម្ពុជា
- បានឃើញច្បាប់ស្តីពីការរៀបចំ និងការប្រព្រឹត្តទៅនៃគណៈរដ្ឋមន្ត្រី ដែលប្រកាសអោយប្រើដោយ ព្រះរាជក្រម ចុះថ្ងៃទី ២០ ខែ កក្កដា ឆ្នាំ ១៩៩៤
- បានឃើញព្រះរាជក្រឹត្យ ព្រះបាទសម្តេចព្រះ **នរោត្តម សីហនុ វរ្ម័ន** ព្រះមហាក្សត្រនៃព្រះរាជាណា ចក្រកម្ពុជា លេខ សន.រកត. ០៧៩៦.៥២ ចុះថ្ងៃទី ២៦ ខែ កក្កដា ឆ្នាំ ១៩៩៦ ស្តីពីប្រព័ន្ធអប់រំ ចំណេះទូទៅ ១២ឆ្នាំ
- បានឃើញលិខិតស្នើសុំរបស់គណៈកម្មការទ្រទ្រង់សាលាបឋមសិក្សាបណ្ណុះវិជ្ជា លេខ ១៥០បណវ ចុះថ្ងៃទី ០៨ តុលា ឆ្នាំ ១៩៩៦ ដោយមានចំណារឯកភាព

លេខ ៤០៣២ លស.ស ចុះថ្ងៃទី ២៩ ខែ វិច្ឆិកា ឆ្នាំ ១៩៩៦ របស់ឯកឧត្តម **ជា សុផារ៉ា** អភិបាលរងទី ១ នៃគណៈប្រតិភូរាជរដ្ឋាភិបាលប្រចាំរាជធានីភ្នំពេញ

-តាមយោបល់ឯកភាពរបស់នាយកដ្ឋានចំណេះទូទៅ និង មត្តេយ្យសិក្សា

សំរេច

ប្រការ ១ : អនុញ្ញាតអោយមន្ទីរអប់រំយុវជន និង កីឡា រាជធានីភ្នំពេញ ប្តូរឈ្មោះសាលាបឋមសិក្សាបណ្តុះវិជ្ជា ដែលមានទីតាំងស្ថិតនៅសង្កាត់ទន្លេបាសាក់ ខ័ណ្ឌចំការមន រាជធានីភ្នំពេញ មកជា «សាលាបឋមសិក្សា សុធារស» វិញ ចាប់ពីឆ្នាំសិក្សា ១៩៩៦-៩៧ នេះតទៅ ។

ប្រការ ២ : បទបញ្ញត្តិទាំងឡាយណាដែលមានខ្លឹមសារផ្ទុយពីប្រកាសនេះ ត្រូវចាត់ទុកជានិរាករណ៍ ។

ប្រការ ៣ : ប្រធានមន្ទីរក្រសួងអប់រំ យុវជន និង កីឡា ប្រធាននាយកដ្ឋានចាត់តាំង ប្រធាននាយកដ្ឋានផែនការ ហិរញ្ញកិច្ច ប្រធាននាយកដ្ឋានចំណេះទូទៅ និង មត្តេយ្យសិក្សា ប្រធានមន្ទីរអប់រំ យុវជន និង កីឡារាជធានីភ្នំពេញ ប្រធានការិយាល័យអប់រំ យុវជន និង កីឡាខ័ណ្ឌចំការមន នាយក សាលាបឋមសិក្សា សុធារស មានភារកិច្ចអនុវត្តប្រកាសនេះ ។

ហត្ថលេខានិងត្រា

តុល ឡោះ

* * *

រាជធានីភ្នំពេញ , ថ្ងៃទី ២២ ខែ មករា ឆ្នាំ ១៩៩៧

ប្រកាសលេខ ៦៩ អយក.ប្រក

ស្តីពីការប្តូរឈ្មោះសាលាបឋមសិក្សា តានី មកជា

សាលាបឋមសិក្សា អេង មាស តានី

* * * *

រដ្ឋមន្ត្រីក្រសួងអប់រំ យុវជន និង កីឡា

- បានឃើញរដ្ឋធម្មនុញ្ញ នៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រឹត្យរបស់ព្រះករុណាព្រះបាទសម្តេច **នរោត្តមសីហនុ វរ្ម័ន** ព្រះមហាក្សត្រនៃ ព្រះរាជាណាចក្រកម្ពុជា ចុះថ្ងៃទី ០១ ខែ វិច្ឆិកា ឆ្នាំ ១៩៩៣ ស្តីពីការតែងតាំងរាជរដ្ឋាភិបាល កម្ពុជា
- បានឃើញច្បាប់ស្តីពីការរៀបចំ និងការប្រព្រឹត្តិទៅនៃគណៈរដ្ឋមន្ត្រី ដែលប្រកាសអោយប្រើដោយ ព្រះរាជក្រម ចុះថ្ងៃទី ២០ ខែ កក្កដា ឆ្នាំ ១៩៩៤
- បានឃើញព្រះរាជក្រឹត្យ ព្រះបាទសម្តេចព្រះ **នរោត្តម សីហនុ វរ្ម័ន** ព្រះមហាក្សត្រនៃព្រះរាជាណាចក្រកម្ពុជា លេខ នស.រកត. ០៧៩៦.៥២ ចុះថ្ងៃទី ២៦ ខែ កក្កដា ឆ្នាំ ១៩៩៦ ស្តីពីប្រព័ន្ធអប់រំ ចំណេះទូទៅ ១២ឆ្នាំ
- យោងលិខិតស្នើសុំរបស់មន្ទីរអប់រំ យុវជន និង កីឡា ខេត្តកំពតលេខ ៤០ អយក.បឋ/៩៦ ចុះថ្ងៃទី ១០ ខែ តុលា ឆ្នាំ ១៩៩៦ ដោយមានយោបល់ឯកភាពពីអភិបាលខេត្តកំពត
- តាមយោបល់ឯកភាពរបស់នាយកដ្ឋានចំណេះទូទៅ និង មត្តេយ្យសិក្សា

សំរេច

ប្រការ ១ : អនុញ្ញាតអោយមន្ទីរអប់រំ យុវជន និង កីឡា ខេត្តកំពត ប្តូរឈ្មោះសាលាបឋមសិក្សា **តានី** ដែលមានទីតាំងស្ថិតនៅឃុំ តានី ស្រុកអង្គរជ័យ ខេត្តកំពត មកជាសាលាបឋមសិក្សា **អេង មាស តានី** ចាប់ពីឆ្នាំសិក្សា ១៩៩៦-៩៧ នេះតទៅ ។

ប្រការ ២ : បទបញ្ញត្តិទាំងឡាយណាដែលមានខ្លឹមសារផ្ទុយពីប្រកាសនេះ ត្រូវចាត់ទុកជានិរាករណ៍ ។

ប្រការ ៣ : ប្រធានមន្ទីរ ប្រធាននាយកដ្ឋានចំណេះទូទៅ និង មត្តេយ្យសិក្សា ប្រធាននាយកដ្ឋានបុគ្គលិក ប្រធាននាយកដ្ឋានផែនការ ហិរញ្ញកិច្ច នៃក្រសួងអប់រំ យុវជន និង កីឡា ប្រធានមន្ទីរអប់រំ យុវជន និង កីឡាខេត្តកំពត ប្រធានការិយាល័យអប់រំ យុវជន និង កីឡាស្រុកអង្គរជ័យ នាយកសាលាបឋមសិក្សាអេងមាស តានី មានភារកិច្ចរៀងៗ ខ្លួនអនុវត្តប្រកាសនេះ ។

ហត្ថលេខានិងត្រា

តូល ឡោ

* * *

រាជធានីភ្នំពេញ , ថ្ងៃទី ២៣ ខែ មករា ឆ្នាំ ១៩៩៧

ប្រកាសលេខ ៧០ អយក.ប្រក

ស្តីពីការប្តូរឈ្មោះសាលាបឋមសិក្សា «អង្គទេឡូចំន» មកជា សាលាបឋមសិក្សា «អង្គបរិច្ឆាគ»

* * *

រដ្ឋមន្ត្រីក្រសួងអប់រំ យុវជន និង កីឡា

– បានឃើញរដ្ឋធម្មនុញ្ញ នៃព្រះរាជាណាចក្រកម្ពុជា
– បានឃើញព្រះរាជក្រឹត្យរបស់ព្រះបាទសម្តេចព្រះ **នរោត្តម សីហនុ វរ្ម័ន** ព្រះមហាក្សត្រនៃព្រះ រាជាណាចក្រកម្ពុជា ចុះថ្ងៃទី ០១ ខែ វិច្ឆិកា ឆ្នាំ ១៩៩៣ ស្តីពីការតែងតាំងរាជរដ្ឋាភិបាលកម្ពុជា
– បានឃើញច្បាប់ស្តីពីការរៀបចំ និងការប្រព្រឹត្តិទៅនៃគណៈរដ្ឋមន្ត្រី ដែលប្រកាសអោយប្រើដោយ ព្រះរាជក្រម ចុះថ្ងៃទី ២០ ខែ កក្កដា ឆ្នាំ ១៩៩៤

រាជធានីភ្នំពេញ , ថ្ងៃទី ២២ ខែ មករា ឆ្នាំ ១៩៩៧

ប្រកាសលេខ ៦៩ អយក.ប្រក

ស្តីពីការប្តូរឈ្មោះសាលាបឋមសិក្សា តានី មកជា

សាលាបឋមសិក្សា អេង មាស តានី

* * * *

រដ្ឋមន្ត្រីក្រសួងអប់រំ យុវជន និង កីឡា

- បានឃើញរដ្ឋធម្មនុញ្ញ នៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រឹត្យរបស់ព្រះករុណាព្រះបាទសម្តេច **នរោត្តមសីហនុ វរ្ម័ន** ព្រះមហាក្សត្រនៃ ព្រះរាជាណាចក្រកម្ពុជា ចុះថ្ងៃទី ០១ ខែ វិច្ឆិកា ឆ្នាំ ១៩៩៣ ស្តីពីការតែងតាំងរាជរដ្ឋាភិបាល កម្ពុជា
- បានឃើញច្បាប់ស្តីពីការរៀបចំ និងការប្រព្រឹត្តិទៅនៃគណៈរដ្ឋមន្ត្រី ដែលប្រកាសអោយប្រើដោយ ព្រះរាជក្រម ចុះថ្ងៃទី ២០ ខែ កក្កដា ឆ្នាំ ១៩៩៤
- បានឃើញព្រះរាជក្រឹត្យ ព្រះបាទសម្តេចព្រះ **នរោត្តម សីហនុ វរ្ម័ន** ព្រះមហាក្សត្រនៃព្រះរាជាណាចក្រកម្ពុជា លេខ នស.រកត. ០៧៩៦.៥២ ចុះថ្ងៃទី ២៦ ខែ កក្កដា ឆ្នាំ ១៩៩៦ ស្តីពីប្រព័ន្ធអប់រំ ចំណេះទូទៅ ១២ឆ្នាំ
- យោងលិខិតស្នើសុំរបស់មន្ទីរអប់រំ យុវជន និង កីឡា ខេត្តកំពតលេខ ៤០ អយក.បឋ/៩៦ ចុះថ្ងៃទី ១០ ខែ តុលា ឆ្នាំ ១៩៩៦ ដោយមានយោបល់ឯកភាពពីអភិបាលខេត្តកំពត
- តាមយោបល់ឯកភាពរបស់នាយកដ្ឋានចំណេះទូទៅ និង មត្តេយ្យសិក្សា

សំរេច

ប្រការ ១ : អនុញ្ញាតអោយមន្ទីរអប់រំ យុវជន និង កីឡា ខេត្តកំពត ប្តូរឈ្មោះសាលាបឋមសិក្សា **តានី** ដែលមានទីតាំងស្ថិតនៅឃុំ តានី ស្រុកអង្គរជ័យ ខេត្តកំពត មកជាសាលាបឋមសិក្សា **អេង មាស តានី** ចាប់ពីឆ្នាំសិក្សា ១៩៩៦-៩៧ នេះតទៅ ។

៦- ទីស្តីការក្រសួងធម្មការ និង សាសនា

សេចក្តីសំរេច

រាជធានីភ្នំពេញ , ថ្ងៃទី ២០ ខែ មករា ឆ្នាំ ១៩៩៧

សេចក្តីសំរេចលេខ ១០/៩៧ កធស

ស្តីពីការអនុញ្ញាតអោយសាងសង់វិហារឥស្លាម សាលារៀនឥស្លាម អាគារសិស្សស្នាក់នៅនិងការិយាល័យមួយខ្នងភូមិជ្រោយមេត្រីលើ ឃុំឫស្សីជ្រោយ ស្រុកមុខកំពូល ខេត្តកណ្តាល

* * *

រដ្ឋលេខាធិការក្រសួងធម្មការ និង សាសនា

- បានឃើញរដ្ឋធម្មនុញ្ញ នៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រឹត្យ ចុះថ្ងៃទី ០១-១១-១៩៩៣ ស្តីពីការតែងតាំងរាជរដ្ឋាភិបាលកម្ពុជា
- បានឃើញច្បាប់ស្តីពីការបង្កើតក្រសួងធម្មការ និង សាសនា ដែលប្រកាសអោយប្រើតាមព្រះរាជក្រមលេខ នស.រកម ០១៩៦-១៩ ចុះថ្ងៃទី ២៤ ខែ មករា ឆ្នាំ ១៩៩៦
- បានឃើញអនុក្រឹត្យលេខ ២២ អនក្រ ចុះថ្ងៃទី ៣០ ខែ មិថុនា ឆ្នាំ ១៩៩២ ស្តីពីការរៀបចំ និង ប្រព្រឹត្តទៅនៃក្រសួងធម្មការ និង សាសនា
- យោងតាមមតិឯកភាពរបស់ឯកឧត្តមអភិបាលខេត្តកណ្តាលលេខ ២៨៦សណ ចុះថ្ងៃទី ១៧-១២-១៩៩៦
- បានឃើញសំណើសុំសាងសង់វិហារឥស្លាម សាលារៀន អាគារសិស្សស្នាក់នៅ និង ការិយាល័យមួយខ្នង ភូមិជ្រោយមេត្រីលើ ចុះថ្ងៃទី ១៣ ខែ កញ្ញា ឆ្នាំ ១៩៩៦ របស់គណៈកម្មការសាងសង់

សំរេច

ប្រការ ១ : អនុញ្ញាតអោយសាងសង់វិហារឥស្លាម សាលារៀន អាគារសិស្សស្នាក់នៅ និង ការិយាល័យមួយ ខ្នង ក្នុងភូមិជ្រោយមេត្រីលើ ឃុំឫស្សីជ្រោយ ស្រុកមុខកំពូល ខេត្តកណ្តាល ។

ប្រការ ២ : វិហារឥស្លាម សាលារៀន អាគារសិស្សស្នាក់នៅ និង ការិយាល័យមួយខ្នងនេះ ត្រូវបានអនុញ្ញាត អោយសាសនិកឥស្លាមគោរពប្រតិបត្តិ ផ្សព្វផ្សាយតាមជំនឿ ប្រពៃណីយ៍ សាសនាឥស្លាម ដោយអនុវត្តអោយបានត្រឹមត្រូវតាមគម្ពីរគួរអាន និង ហាទេស ។

ប្រការ ៣ : វិហារឥស្លាម សាលារៀន អាគារសិស្សស្នាក់នៅ និង ការិយាល័យមួយខ្នងនេះ ត្រូវគោរពអោយបានម៉ឺងម៉ាត់ តាមច្បាប់នៃព្រះរាជាណាចក្រកម្ពុជា និងបទបញ្ញត្តិទាំងឡាយរបស់ក្រសួងធម្មការ និងសាសនា មិនធ្វើអោយប៉ះពាល់ដល់សិទ្ធិសេរីភាព ជំនឿសាសនាដទៃ និង សណ្តាប់ធ្នាប់សង្គម ព្រមទាំងទំនាក់ទំនងអោយបានល្អប្រសើរជាមួយរដ្ឋអំណាច និង ស្ថាប័នពាក់ព័ន្ធ ។

ប្រការ ៤ : រាល់ការអនុវត្តន៍ដែលផ្ទុយពីសេចក្តីសំរេចនេះ ត្រូវទទួលទោសតាមច្បាប់ជាធរមាន ។

ប្រការ ៥ : នាយកដ្ឋានរដ្ឋបាល–ហិរញ្ញកិច្ច នាយកដ្ឋានសាសនា មន្ទីរធម្មការ និង សាសនាខេត្តកណ្តាល និងសាសនិកនៃវិហារឥស្លាមភូមិជ្រោយមេត្រីលើ ត្រូវអនុវត្តសេចក្តីសំរេចនេះអោយមាន ប្រសិទ្ធភាពខ្ពស់ ។

ប្រការ ៦ : សេចក្តីសំរេចនេះមានអានុភាពគតិយុត្តិចាប់ពីថ្ងៃចុះហត្ថលេខាតទៅ ។

រដ្ឋលេខាធិការ

ហត្ថលេខានិងត្រា

ហឿន ចណ្ណារ័ត្ន

* * *